**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# មូលហេតុនៃការរលត់កាតព្វកិច្ច

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវឡើងដោយ

និស្សិតឈ្មោះ **លោក. ជុំ ថិរយុត្តិ**

សាស្ត្រាចារ្យណែនាំ

**លោក. ឌិន វណ្ណារ៉ា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ជុំ ទិរៈយុត្តិ** ជានិស្សិតសិក្សានៅផ្នែកនីតិសាស្ត្រជំនាន់ទី២១ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលកំពុងតែធ្វើការស្រាវជ្រាវសរសេរសារណាថ្នាក់បរិញ្ញាប័ត្រនៅក្នុងបំណងដើម្បីបញ្ចប់ការសិក្សាក្រោមប្រធានបទស្តីពី "**មូលហេតុនៃការរលត់កាតព្វកិច្ច**" ។

ខ្ញុំបាទសុំថ្លែងអំណរគុណ និងសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះ៖

លោកឪពុក **ជុំ ធីរិទ្ធ** ព្រមទាំងអ្នកម្តាយ **ទិន បញ្ញាមុនី** ដែលជាអ្នកមានគុណដ៏ធំធេងចំពោះរូបកូនដែលមិនអាចមានអ្វីមកកាត់ថ្លៃបានដោយលោកឪពុក និង អ្នកម្តាយបានផ្តល់កំណើតនិងចិញ្ចឹមបីបាច់ថែរក្សារូបកូនប្រកបដោយព្រហ្មវិហារធម៌។ លោកឪពុក និង អ្នកម្តាយបានធ្វើការទំនុកបំរុងគ្រប់បែបយ៉ាងទាំងផ្នែកសម្ភារៈ ថវិកា ស្មារតី សេចក្តីស្រឡាញ់ បានផ្តល់នូវដំបូន្មានល្អៗ និងផ្តល់ឱកាសព្រមទាំងជំរុញទឹកចិត្តរូបកូនឱ្យខិតខំសិក្សារៀនសូត្រហូតឈានដល់ការបញ្ចប់ ថ្នាក់បរិញ្ញាប័ត្រនៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ខ្ញុំបាទក៏សូមអរគុណដល់បងប្អូនដែលតែងតែស្រឡាញ់ ណែនាំ និងជាកម្លាំងចិត្តដល់រូបយើងខ្ញុំរហូតមក។

**ឯកឧត្តម សាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក និង លោកស្រី សាស្ត្រាចារ្យ និងបុគ្គលិក ការិយាល័យស្រាវជ្រាវ ការិយាល័យសិក្សា និងបណ្ណារក្ស** នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែល បានខិតខំអស់ពីកម្លាំងចិត្ត កម្លាំងកាយ ដែលបានដឹកនាំ ជួយជ្រោមជ្រែង និងបង្ហាត់បង្រៀនផ្ទេរនូវចំណេះដឹងល្អៗ គ្រប់ផ្នែកយ៉ាងច្រើន ព្រមទាំងបទពិសោធន៍នៃជីវិតនៅក្នុងសង្គមដល់រូបខ្ញុំបាទផងដែរ។

លោកគ្រូសាស្ត្រាចារ្យ **ជិន វណ្ណារ៉ា** ដែលបានបង្ហាត់បង្រៀនដល់រូបខ្ញុំបាទ ព្រមទាំងចំណាយពេលដ៏មានតម្លៃរបស់ លោកណែនាំ ផ្តល់យោបល់ បង្ហាត់បង្ហាញជំរុញលើកទឹកចិត្តខ្ញុំបាទក្នុងការស្រាវជ្រាវទៅលើអត្ថបទនេះ លោកក៏បានជួយ ណែនាំ កែសម្រួល ជួយជាគំនិត និងឯកសារពាក់ព័ន្ធដល់រូបយើងខ្ញុំ។

មិត្តភក្តិរួមថ្នាក់ L4A3 ដែលតែងតែជួយណែនាំ និងលើកទឹកចិត្តព្រួយបារម្ភចំពោះយើងខ្ញុំ។ ជាចុងក្រោយ ខ្ញុំបាទសូមគោរពជូនពរដល់លោកឪពុក និង អ្នកម្តាយទាំងពីរនាក់ ឯកឧត្តម សាកលវិទ្យាធិការ សកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រី សាស្ត្រាចារ្យ បុគ្គលិកការិយាល័យទាំងអស់ លោកសាស្ត្រាចារ្យ ជិន វណ្ណារ៉ា ឱ្យជួបតែសម្បត្តិ ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋម ខ្ញុំបាទសូមគោរពលោក-លោកស្រីសាស្ត្រាចារ្យ ព្រមទាំងសូមស្វាគមន៍ដល់មិត្តអ្នកអានគ្រប់រូបជាពិសេសសិស្ស-និស្សិតជាទីរាប់អាន។

ខ្ញុំបាទមានមោទនភាព និងសោមនស្សរីករាយដែលមានឱកាសមកធ្វើការស្រាវជ្រាវចងក្រងឯកសារ សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ក្រោមប្រធានបទស្តីពី **“មូលហេតុនៃការរលត់កាតព្វកិច្ច”** ដោយសង្កេតឃើញពីគុណប្រយោជន៍នៃការសិក្សាស្រាវជ្រាវទាក់ទងនឹងកាតព្វកិច្ចនេះ ដែលជាញឹកញាប់កើតឡើងក្នុងសង្គមសព្វថ្ងៃព្រមទាំងមានការគាំទ្រ និងមានការលើកទឹកចិត្តពីសំណាក់លោកគ្រូសាស្ត្រាចារ្យ **ខិន ខណ្ឌារ៉ា** ដែលជាសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រនៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា សារណានេះនឹងចូលរួមវិភាគទានដ៏សំខាន់នៅក្នុងការបំភ្លឺដល់ភាពដែលស្រពេចស្រពិលផ្សេងៗ ទាក់ទងនឹងមូលហេតុនៃការរលត់កាតព្វកិច្ចដែលកន្លងមកមិនទាន់បានផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅឡើយ។ ហើយខ្ញុំបាទសង្ឃឹមថា សារណានេះអាចការជួយចែករំលែកនូវចំណេះដឹងដល់អ្នកដែលចង់ដឹង ចង់ស្វែងយល់ឲ្យកាន់តែច្បាស់នូវសញ្ញាណទូទៅនៃកាតព្វកិច្ច ប្រភពកាតព្វកិច្ច និងជាពិសេសមូលហេតុនៃរលត់កាតព្វកិច្ចថា តើការរលត់កាតព្វកិច្ច អាចកើតឡើងក្នុងលក្ខខណ្ឌអ្វីខ្លះ។ ជាពិសេសសារណានេះក៏ជាឯកសារជំនួយស្មារតីសម្រាប់មិត្តនិស្សិតជំនាន់ក្រោយៗ និងបំពេញឲ្យសេចក្តីត្រូវការជាចាំបាច់ដល់មជ្ឈដ្ឋានអ្នកស្រាវជ្រាវដែលបាននឹងកំពុងជួបប្រទះនូវចន្លោះខ្វះខាតនាពេលសព្វថ្ងៃនេះ។

ហើយយើងខ្ញុំក៏សូមអរគុណចំពោះការកែលម្អរបស់មិត្តអ្នកអាន អ្នកសិក្សាគ្រប់ជំនាន់ទាំងអស់ដែល និងចូលរួមជាគំនិតយោបល់ដែរ និងធ្វើឱ្យប្រធានបទនេះកាន់តែមានភាពច្បាស់លាស់ និងកាន់តែប្រសើរ។

ជាចុងក្រោយ សូមជូនពរដល់មិត្តអ្នកអានគ្រប់រូបឲ្យជួបប្រទះតែភាពសុខដុមរមនា រុងរឿង ថ្កុំថ្កើង ជោគជ័យរាល់ភារកិច្ច និងមានសុភមង្គលជានិរន្តន៍ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម** ........................................ ០១

## ជំពូកទី ១
## ការកកើតនៃកាតព្វកិច្ច

**ផ្នែកទី១៖ កាតព្វកិច្ច** ........................................ ០៣
១. សញ្ញាណទូទៅនៃកាតព្វកិច្ច ........................................ ០៣
២. ប្រភពនៃកាតព្វកិច្ច ........................................ ០៣
**ផ្នែកទី២៖ សកម្មភាពឯកតោភាគី** ........................................ ០៥
**ផ្នែកទី៣៖ ការគ្រប់គ្រងដោយឈឺឆ្អាល** ........................................ ០៦
១. លក្ខខណ្ឌនៃការគ្រប់គ្រងដោយឈឺឆ្អាល ........................................ ០៧
២. ករណីយកិច្ច ........................................ ០៧
៣. សិទ្ធិទាមទារឱ្យសងសោហ៊ុយ និងសិទ្ធិទាមទារកម្រៃ ........................................ ០៨
**ផ្នែកទី៤៖ សេចក្ដីចម្រើនដោយឥតហេតុ** ........................................ ០៩
១. លក្ខខណ្ឌនៃសេចក្ដីចម្រើនដោយឥតហេតុ ........................................ ១០
២. ករណីយកិច្ចសងរបស់អ្នកទទួលផលប្រយោជន៍ ដោយមានគំនិតទុច្ចរិក ........................................ ១០
៣. ការសងដោយគ្មានកាតព្វកិច្ច ការសងនៅមុនពេលកំណត់ និងការសង កាតព្វកិច្ចរបស់អ្នកដទៃ ........................................ ១២
**ផ្នែកទី៥៖ អំពើអនីត្យានុកូល** ........................................ ១៣
១. កំហុស ........................................ ១៣
១.១ ភាពខុសច្បាប់ ........................................ ១៤
១.២ ការខូចខាត ឬ ព្យសនកម្ម ........................................ ១៤
១.៣ ទំនាក់ទំនងហេតុ និង ផល ........................................ ១៥
២. ប្រភេទការទទួលខុសត្រូវ (អំពើអនីត្យានុកូល) ........................................ ១៧
៣. ការទទួលខុសត្រូវចំពោះអំពើរបស់សត្វ និង វត្ថុ ........................................ ១៨
៤. អំពើអនីត្យានុកូលរួម ........................................ ១៩
៥. បញ្ញត្តិដែលទាក់ទងន័យផ្សេងទៀតស្ដីអំពីអំពើអនីត្យានុកូល ........................................ ១៩

# ជំពូកទី២
# របបគតិយុត្តនៃការរលត់កាតព្វកិច្ច


**ផ្នែកទី១៖ ការសង ការទូទាត់ ការលើកលែង នវកម្ម ឬ ព្យាកុលភាព** ........ ២០
១. ការសង ........ ២១
១.១ អ្នកដែលទទួលការសង ពេលដែលការសងត្រូវបានធ្វើឡើង និងទីកន្លែងត្រូវសង .... ២២
១.២ អ្វីដែលកូនបំណុលត្រូវធ្វើដែលជាការសង ........ ២២
១.៣ សំណើផ្តល់ការសង និងតម្កល់ ........ ២៣
២. ការទូទាត់ ........ ២៤
២.១ លក្ខខណ្ឌនៃការទូទាត់ ........ ២៤
២.១.១ មូលហេតុនៃការកម្រិតចំពោះការទូទាត់ ........ ២៦
២.១.២ កិច្ចសន្យាទូទាត់ ........ ២៦
២.១.៣ អានុភាព ........ ២៦
២.១.៤ កាតព្វកិច្ចតាមដីកាសម្រេចបង្គាប់ឱ្យរឹបអូស ........ ២៧
៣. ការលើកលែង និងព្យាកុលភាព........ ២៧
៣.១ ការលើកលែង ........ ២៧
៣.២ ព្យាកុលភាព ........ ២៧

**ផ្នែកទី២៖ អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច ដោយគ្មានកំហុសរបស់កូនបំណុល** ........ ២៩
**ផ្នែកទី៣៖ ការបំពេញលក្ខខណ្ឌនៃការរំលាយកិច្ចសន្យា ឬ ការរំលាយកិច្ចសន្យា** ........ ២៩
១. ការរំលាយកិច្ចសន្យា ........ ៣០
១.១ លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា ........ ៣២
១.២ អានុភាពនៃការរំលាយកិច្ចសន្យា ........ ៣៣

**ផ្នែកទី៤៖ ការផុតអាជ្ញាយុកាលនៃកាតព្វកិច្ច** ........ ៣៣
១. លក្ខខណ្ឌនៃអាជ្ញាយុកាលសិទ្ធិលើបំណុល ........ ៣៤
២. ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ........ ៣៥
៣. ការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ........ ៣៧

**ផ្នែកទី៥៖ ការអនុវត្តសិទ្ធិលុបចោល** ........ ៣៧

១. ការលុបចោលនូវសកម្មភាពដែលធ្វើឡើងដោយជនកម្រិតសមត្ថភាព ................................ ៣៨
២. ការលុបចោលដោយមានវិការៈ ........................................................................ ៤០
២.១ អ្នកដែលមានសិទ្ធិលុបចោល ........................................................ ៤១
២.២ អាជ្ញាយុកាលនៃការរលត់សិទ្ធិលុបចោល ........................................ ៤២
**សេចក្ដីសន្និដ្ឋាន** ........................................................................................... ៤៣
**អនុសាសន៍** ..................................................................................................... ៤៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ជាការពិតណាស់ ការរស់នៅក្នុងសង្គមសព្វថ្ងៃ តែងមានការប្រស្រ័យទាក់ទងគ្នាទៅវិញទៅមកក្នុងរូបភាពជា លក្ខណៈសីលធម៌ ការគួរសមរវាងគ្នានឹងគ្នា ទំនៀមទំលាប់ និងទំនាក់ទំនងមុខជំនួញជួញដូរអាជីវកម្មតូចធំ។ ចំពោះជំនួញ ជួញដូរអាជីវកម្មនានា គឺមានលក្ខណៈជីវភាពប្រចាំថ្ងៃរបស់ប្រជាជនទូទៅនៅក្នុងសង្គម និងជាដង្ហើមរស់សេដ្ឋកិច្ចរបស់ប្រទេសជាតិ។ យើងសង្កេតឃើញថា ទំនាក់ទំនងជួញដូរគ្រប់ទំនងរូបភាពអាចធ្វើឡើងតាមរយៈកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី ជាអាទិ៍។ ហើយសកម្មភាពទាំងនោះនឹងបង្កបានជាសិទ្ធិ និងករណីយកិច្ចហៅថា "**ម្ចាស់បំណុល**" និងអ្នកដែលមានករណីយកិច្ចហៅថា "**កូនបំណុល**"។ រាល់សកម្មភាពដែលមានរូបភាពជា ជំនួញអាជីវកម្មគឺ តែងតែកើតមានឡើងនូវកាតព្វកិច្ចចងភាគីទាំងសងខាងឱ្យមានការទទួលខុសត្រូវ។ កាតព្វកិច្ចក្នុងខ្លឹមសារដែលមានលក្ខណៈបែបអក្សរសាស្ត្រ គឺជាកិច្ចដែលបុគ្គលត្រូវបំពេញដាច់ខាត ដែលមានករណីយកិច្ចចំពោះអ្នកដែលទទួលប្រយោជន៍ពីសកម្មភាពនោះ។ ចំណែកឯតាមខ្លឹមសារគតិយុត្តវិញ កាតព្វកិច្ច គឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលទាំងពីរនាក់ដោយឱ្យបុគ្គលដែលមានករណីយកិច្ចកំណត់មួយចំនួនចំពោះបុគ្គលដែលបានកំណត់មួយទៀត។

ជាសញ្ញាណគតិយុត្តនៃកាតព្វកិច្ច គឺជាការពិចារណាទៅលើវត្ថុនៃកាតព្វកិច្ចដែលបានបញ្ញត្តិឡើងដើម្បីការពារបុគ្គល ដែលបានទទួលនូវផលប្រយោជន៍នៅក្នុងទំនាក់ទំនងគតិយុត្តនេះ គឺជាការឆ្លើយតបដ៏វិជ្ជមានមួយទៅលើការគ្រប់គ្រងសកម្មភាពទាំងនេះ។ ក្នុងគោលដៅធានាឱ្យបាននូវសុវត្ថិភាពគតិយុត្ត និងស្ថេរភាពនៃកិច្ចការជំនួញរបស់ប្រជាជនទូទៅក្នុងសង្គម។ ខ្លឹមសារនៃកាតព្វកិច្ចមានលក្ខណៈស្មុគស្មាញខ្លាំង។ បើយើងប្រៀបធៀបជាមួយបទប្បញ្ញត្តិផ្សេងៗទៀត ដោយសារតែស្ថានភាពខ្លះមានលក្ខណៈអរូបិយខ្លាំងមានរបបគំហើញគតិយុត្តថ្មី ហើយមានការបកស្រាយបញ្ច្រាស ទើបអាចក្តោបពីខ្លឹមសារទាំងនោះបាន។ ហេតុនេះហើយ នៅក្នុងការសិក្សាអំពីមេរៀនទាក់ទងកាតព្វកិច្ចនេះ ទាមទារឱ្យយើងមានការព្យាយាមសិក្សាស្វែងយល់និងករណីសិក្សាជាក់ស្តែងច្រើនក្នុងការឆ្លើយតបចំពោះលក្ខខណ្ឌទាំងអស់នេះ ដែលជាគន្លឹះដ៏សំខាន់ក្នុងការកាត់បន្ថយភាពស្មុគស្មាញ និងងាយស្រួលក្នុងការយល់ដឹង។ ម្យ៉ាងវិញទៀត នៅពេលដែលយើងសិក្សាស្វែងយល់ដឹងអំពីកាតព្វកិច្ច គឺយើងកំពុងតែពិចារណានៅលើបញ្ហានានា និងសកម្មភាពផ្សេងៗដែលជាបន្ទុកសម្រាប់អ្នកករណីយកិច្ចដោះស្រាយ របៀបនៃការដោះស្រាយ បញ្ហាប្រឈម មធ្យោបាយនៃការអនុវត្តសិទ្ធិស្ថានភាពនៃការទាមទារ និងលក្ខខណ្ឌត្រូវបំពេញ ដើម្បីឱ្យកាតព្វកិច្ចនោះរំលត់ដោយសារតែមូលហេតុគតិយុត្តដែលច្បាប់បានទទួលស្គាល់។ ហេតុនេះហើយ ការលើកឡើងនូវប្រធានបទ "**មូលហេតុនៃការរលត់កាតព្វកិច្ច**" គឺមានគោលបំណងបង្ហាញ និងវិភាគឱ្យបានច្បាស់លាស់លើមូលហេតុនីមួយៗ។ ការសិក្សាទាក់ទងលើ

ប្រធានបទនេះជាផ្នាក់មួយក្នុងការសិក្សាស្វែងយល់ពី ក្រមរដ្ឋប្បវេណី តួយ៉ាងវាបានរំលេចនូវមូលហេតុនីមួយៗ ដែលជាកត្តានាំឲ្យមានការរលត់កាតព្វកិច្ចក្នុងកិច្ចសន្យានេះ កើតឡើង។

ដើម្បីឆ្លើយតបជាមួយសារៈសំខាន់នៃការសិក្សាស្វែងយល់នៃប្រធានបទនេះ ឱ្យកាន់តែងាយស្រួលយល់ និងយល់ឱ្យបានស៊ីជម្រៅមួយកំរិតទៀតនោះ ក្នុងឱកាសនេះខ្ញុំបាទសូមធ្វើការបកស្រាយនូវប្រធានបទ ដោយបែកចែកជា ២ ជំពូកសំខាន់ៗគឺៈ

**ជំពូកទី ១៖ ការកកើតនៃកាតព្វកិច្ច**

**ជំពូកទី ២៖ របបគតិយុត្តនៃការរលត់កាតព្វកិច្ច**

# ជំពូកទី១
# ការកកើតនៃភាគព្វកិច្ច

# ជំពូកទី១

# ការកកើតកាតព្វកិច្ច

## ផ្នែកទី១៖ កាតព្វកិច្ច

### ១. សញ្ញាណទូទៅនៃកាតព្វកិច្ច

កាតព្វកិច្ច គឺជាករណីយកិច្ចដែលបុគ្គលម្នាក់មានចំពោះបុគ្គលម្នាក់ផ្សេងទៀត។ កាតព្វកិច្ច គឺជាចំណង នៃសិទ្ធិដែលបង្ខំជនណាម្នាក់ឲ្យផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិណាមួយឱ្យបំពេញនូវកិច្ចការណាមួយ ឬ ឲ្យឈប់បំពេញនូវកិច្ចការណាមួយដល់ជនម្នាក់ទៀត។[1] កាតព្វកិច្ច គឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីរនាក់ដោយឲ្យបុគ្គលម្នាក់ដែលបានកំណត់មាន ករណីយកិច្ចមួយចំនួនចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត។ បុគ្គលដែលមានករណីយកិច្ចហៅថា "**កូនបំណុល**" រីឯបុគ្គលដែលទទួលផលប្រយោជន៍ពីករណីយកិច្ចនោះហៅថា "**ម្ចាស់បំណុល**" ។[2]

### ២. ប្រភពនៃកាតព្វកិច្ច

កាតព្វកិច្ចកើតឡើងដោយកិច្ចសន្យាដែលសកម្មភាពឯកតោភាគី ដែលមានការគ្រប់គ្រងដោយការឈឺឆ្អាលដោយសេចក្តីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និងដោយបញ្ញត្តិនៃច្បាប់។[3]

កាតពកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី មានដូចជា៖

-**កិច្ចសន្យា** គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នា ព្រមបង្កើត កែប្រែ ឬ រលត់នូវកាតព្វកិច្ច។ ឧទាហរណ៍៖ នៅក្នុងកិច្ចសន្យាទិញលក់ បង្កើតឡើងចេញពីឆន្ទៈរបស់បុគ្គលពីរនាក់ដែលអ្នកលក់មានកាតព្វកិច្ចធ្វើការ ផ្ទេរកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការទិញ រីឯអ្នកទិញមានកាតព្វកិច្ចបង់ថ្លៃលក់ ។

-**សកម្មភាពឯកតោភាគី** គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬ រលត់នូវកាតព្វកិច្ចដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬ ដោយបានទទួលតាមកិច្ចសន្យា។ កិច្ចសន្យា ជាដំបូងត្រូវបានបង្កើតឡើងផ្អែកតាមការព្រមព្រៀង ជាមួយភាគីម្ខាងទៀត។ សិទ្ធិនៃការលុបចោលកិច្ចសន្យាត្រូវបានអនុវត្តផ្អែកលើការបង្ហាញឆន្ទៈឯកតោភាគីដែលមានសិទ្ធិដោយគ្មានការព្រមព្រៀងពីភាគីម្ខាងទៀត ហើយបន្ទាប់មកការលុបចោលកិច្ចនោះមានសុពលភាព។ ឧទាហរណ៍៖ សកម្មភាពឯកតោភាគី រួមមានការលើកលែងកាតព្វកិច្ច អច្ច័យទាន ការរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា និងការបង្ហាញឆន្ទៈទូទាត់។

---

[1] សទ្ទានុក្រម នៃច្បាប់ភូមិបាល, ឆ្នាំ ២០០១

[2] មាត្រា ៣០៨ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[3] មាត្រា ៣០៩ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

## ផ្នែកទី២៖ សកម្មភាពឯកតោភាគី

សកម្មភាពឯកតោភាគី គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬ រលត់នូវកាតព្វកិច្ចដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬ ដោយអនុវត្តសិទ្ធិដែលទទួលបានតាមកិច្ចសន្យា ឬ តាមបញ្ញត្តិនៃច្បាប់។ ក្នុងករណីដែលកិច្ចសន្យា ឬ កិច្ចសន្យាដំបូងត្រូវបានបង្កើតឡើងទៅតាមការព្រមព្រៀងជាមួយនឹងភាគីម្ខាងទៀតទេ។ សិទ្ធិនៃការលុបចោលកិច្ចសន្យា ត្រូវបានអនុវត្តផ្អែកលើការបង្ហាញឆន្ទៈឯកតោភាគីដោយភាគីដែលមានសិទ្ធិ ដោយគ្មានការព្រមព្រៀងពីភាគីម្ខាងទៀត ហើយបន្ទាប់មកការលុបចោលកិច្ចសន្យានោះមានសុពលភាព។[4]

-**ការលើកលែងកាតព្វកិច្ច** គឺពេលដែលម្ចាស់បំណុលបង្ហាញឆន្ទៈលើកលែងកាតព្វកិច្ចចំពោះកូនបំណុល កាតព្វកិច្ចនោះត្រូវបានរលត់។[5] ឧទាហរណ៍៖ ផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ដែលកូនបំណុលបានខ្ចីប្រាក់ពីម្ចាស់បំណុលចំនួន ២០០០ ដុល្លារ ក្នុងករណីនោះម្ចាស់បំណុលអាចលើកលែងកាតព្វកិច្ច ៦០០ ដុល្លារពីកាតព្វកិច្ច ២០០០ ដុល្លារ ឬ ម្ចាស់បំណុលអាចបង្ហាញឆន្ទៈលើកលែងកាតព្វកិច្ចបង់ការប្រាក់។

-**អច្ច័យទាន** គឺជាសំបុត្របណ្ដាំដែលផ្ដាំឱ្យចែកទ្រព្យមរតកឲ្យមនុស្សម្នាក់ ឬ ច្រើននាក់។ អច្ច័យទានគឺជាប្រទានកម្មដែលម្ចាស់បំណុលធ្វើអោយមនុស្សម្នាក់ ឬ ច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមត៌កសាសន៍។[6] ពោលមានន័យថា ម្ចាស់បំណុលឲ្យទ្រព្យសម្បត្តិតាមរយៈមត៌កសាសន៍ដោយមិនចាំបាច់មានការយល់ព្រមរបស់អច្ច័យលាភី។ ឧទាហរណ៍៖ ក្រោយពីបានរៀបការស្របច្បាប់ជាមួយនឹងពិសីបាន ២ ឆ្នាំកន្លងផុតទៅម្ដាយមីងរបស់ បញ្ញា បានស្លាប់បាត់បង់ជីវិតហើយគាត់បានបន្សល់ទុកនូវបណ្ដាំជាលាយលក្ខណ៍អក្សរមួយច្បាប់ ដែលមានខ្លឹមសារថាប្រគល់ផ្ទះ ៤ ល្វែង និងដីចម្ការទំហំ ១០ ហិចតា ឲ្យទៅបញ្ញា។ ក្នុងករណីនេះ ផ្ទះ ៤ល្វែង និងដីចម្ការ ១០ ហិចតានេះ គឺជាអច្ច័យទានមានកំណត់ដែលម្ដាយមីងបានប្រគល់ឲ្យបញ្ញា ហៅថាអច្ច័យលាភី។

-**ការរំលាយដែលបានកំណត់នៅក្នុងកិច្ចសន្យា** គឺជាសិទ្ធិរំលាយដែលបានកំណត់ក្នុងកិច្ចសន្យាជាសិទ្ធិរំលាយដែលបានផ្ដល់ឲ្យទៅភាគីនៃកិច្ចសន្យាក្នុងការរំលាយកិច្ចសន្យា ក្នុងករណីដែលបានកំណត់មួយចំនួនបើទោះបីថាមិនមានការអនុវត្តកាតព្វកិច្ចក៏ដោយ។ សិទ្ធិរំលាយដែលបានកំណត់នៅក្នុងកិច្ចសន្យានេះ ត្រូវបានអនុវត្តតាមការបង្ហាញឆន្ទៈឯកតោភាគីរបស់អ្នកដែលមានសិទ្ធិរំលាយ។ ពោលផ្ដល់ឲ្យភាគីម្ខាង ឬ ភាគីទាំងសងខាងនៅសិទ្ធិរំលាយក្នុងករណីជាក់លាក់មួយដោយផ្អែកទៅលើកិច្ចសន្យា (ទោះបីគ្មានការអនុវត្តកាតព្វកិច្ច

[4] មាត្រា ៣១២ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[5] មាត្រា ៤៧៣ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[6] សទ្ទានុក្រម នៃច្បាប់ភូមិបាល, ឆ្នាំ ២០០១

ក៏ដោយ) ។

-**ការបង្ហាញឆន្ទៈទូទាត់** គឺត្រូវធ្វើឡើងដោយការបង្ហាញឆន្ទៈទូទាត់ពីភាគីម្ខាងទៅភាគីម្ខាងមួយទៀត មានន័យថា ការទូទាត់ដោយភាគីម្ខាងដោយបង្ហាញឆន្ទៈធ្វើការទូទាត់ទៅភាគីម្ខាងទៀត។[7] ឧទាហរណ៍៖ ពូម៉ៅ និង មីងដាបានសន្យាគ្នាថា ពូម៉ៅ ត្រូវលក់គោយន្តទៅឲ្យមីងដាក្នុងតម្លៃ ៧០០ ដុល្លារដោយគ្មានធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរពិសេសណាមួយអំពី ពេលវេលានៃការសងនោះទេ។ ក្រៅពីនោះ ពូម៉ៅបានខ្ចីប្រាក់ចំនួន ៧០០ ដុល្លារពី មីងដា។ ដោយកាតព្វកិច្ចរបស់ ពូម៉ៅ ត្រូវសងប្រាក់ចំនួន ៧០០ ដុល្លារ ហើយកាតព្វកិច្ចរបស់ មីងដា ត្រូវបង់ប្រាក់ចំនួន ៧០០ ដុល្លារ និងកាតព្វកិច្ចរបស់ ពូម៉ៅ ត្រូវប្រគល់គោយន្ត។

ចំណែកឯក្រមរដ្ឋប្បវេណីបារាំង ប្រសិនបើសិទ្ធិលើបំណុលចំពោះគ្នាទៅវិញទៅមកស្ថិតនៅក្នុងស្ថានភាពសមស្របនឹងការទូទាត់ នោះការទូទាត់ត្រូវមានអនុភាពដោយស្វ័យប្រវត្តិ ទោះបីគ្មានការបង្ហាញឆន្ទៈអំពីការទូទាត់ដោយភាគីក៏ដោយ។

## ផ្នែកទី៣៖ ការគ្រប់គ្រងដោយឈឺឆ្អាល

ក្រមរដ្ឋប្បវេណី បានកំណត់អំពីកាតព្វកិច្ចចំនួន ៣ គឺការគ្រប់គ្រងដោយឈឺឆ្អាល (ការគ្រប់គ្រងកិច្ចការ) សេចក្តីចម្រើនឥតហេតុ អំពើនីត្យានុកូលដោយតម្រូវឲ្យមានការទទួលខុសត្រូវ ដែលមិនមែនកើតឡើងពីកិច្ចសន្យា។ ជាទូទៅ បុគ្គលដែលមានសេរីភាពខាងឆន្ទៈកាលណាគ្មានឆន្ទៈគឺ គ្មានកាតព្វកិច្ច។[8] ហេតុនេះគ្មាននរណាម្នាក់អាចចាប់បង្ខំបុគ្គលណាមួយឲ្យមានកាតព្វកិច្ចចំពោះអំពើមួយបានឡើយ បើគ្មានឆន្ទៈនេះបើយោងទៅតាមទ្រឹស្តីនៃស្វ័យភាពបុគ្គល។ បើបុគ្គលណាម្នាក់បានធ្វើអ្វីមួយក្នុងនាមជាអ្នកដទៃ ហើយមានឆន្ទៈក្នុងការបំពេញក្នុងន័យការពារ ឬ ធ្វើឱ្យមានប្រយោជន៍ដល់បុគ្គលនោះវិញ តាមការកំណត់របស់ច្បាប់ដែលត្រូវបានគេហៅថា ការគ្រប់គ្រងដោយឈឺឆ្អាល។[9] ឧទាហរណ៍៖ ក.) បុគ្គលម្នាក់បានដឹងថា បង្អួចរបស់អ្នកជិតខាងបានទទួលរងនូវការខូចខាតដោយសារខ្យល់ព្យុះបក់បោកខ្លាំង ខណៈពេលដែលនៅអ្នកជិតខាងមិននៅផ្ទះ។ បុគ្គលនោះមិនបានធ្វើអ្វីទេ ហើយស្របពេលនោះនៅខាងក្នុងផ្ទះរបស់អ្នកជិតខាងនោះមានការលិចទឹកជ្រាបពេញផ្ទះ។ អ្នកជិតខាងនោះបានត្រឡប់មកផ្ទះវិញ ហើយបានស្តីបន្ទោសឲ្យបុគ្គលនោះដោយគាត់បានដឹងតែមិនបានជួយឈឺឆ្អាលបាំងទឹកការពារការសាចចូល។ ខ.) បុគ្គលម្នាក់បានដឹងថា បង្អួចរបស់អ្នកជិតខាងខ្លួនបានទទួលរងនូវការខូចខាតដោយសារខ្យល់ព្យុះបោកខ្លាំង ខណៈពេលដែលអ្នកជិតខាងនៅផ្ទះ។ បុគ្គលនោះបានជួយជួសជុលបង្អួចដែលខូចខាតនោះ ដើម្បីការពារផ្ទះនោះកុំឲ្យមានការលិចទឹកចូលដោយចំណាយលើកញ្ចក់ និងកម្លាំង

[7] មាត្រា ៩៦៥ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[8] មាត្រា ៣ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[9] អ៊ុក វណ្ណារ័ត្ន, នីតិកាតព្វកិច្ច, ទំព័រទី២០

ពលកម្មរបស់គាត់។ បុគ្គលនោះបានរបួសម្រាមដៃពេលដែលគាត់ជួយបង្ហួចនោះ។ តើបុគ្គលនោះអាចទាមទារអ្វីពីអ្នកជិតខាងនោះ?

ដូចដែលបានលើកឡើងនៅក្នុងឧទាហរណ៍ខាងលើ (ចំណុច ក) គឺគ្មាននរណាម្នាក់ត្រូវបានចាប់បង្ខំឱ្យបំពេញការងារនោះទេ ដូច្នេះបុគ្គលនោះមិនត្រូវគេស្តីបន្ទោសតាមទស្សនៈវិស័យច្បាប់ឡើយ (បញ្ហាខាងសីលធម៌នឹងមាន ប៉ុន្តែនេះគឺជាបញ្ហាមួយដោយឡែកទៀត)។ ដោយឡែកនៅក្នុង (ចំណុចខ) កាលណាបុគ្គលម្នាក់ដែលបានគ្រប់គ្រងដោយឈឺឆ្អាលនោះ បើទោះបីគ្មានកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ឬ ការព្រមព្រៀងណាមួយក៏ដោយ បុគ្គលដែលត្រូវទទួលបាននូវផលប្រយោជន៍ត្រូវមានកាតព្វកិច្ចធ្វើតាមកម្រិតមួយជាក់លាក់ដែលមានករណីលើកលែងចំពោះគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជននេះ ពោលជាកាតព្វកិច្ចដែលកំណត់ដោយច្បាប់។

### **១. លក្ខខណ្ឌនៃការគ្រប់គ្រងដោយឈឺឆ្អាល**

ប្រសិនបើមានសិទ្ធិអំណាចក្នុងការគ្រប់គ្រង ដូចជាកិច្ចសន្យាអាណត្តិជាដើម ការគ្រប់គ្រងដោយឈឺឆ្អាលមិនត្រូវបានអនុវត្តទេ គឺភាគីត្រូវអនុវត្តដោយអនុលោមតាមសិទ្ធិអំណាចនៃការគ្រប់គ្រងនោះ ហើយមិនមែនជាបញ្ហានៃការគ្រប់គ្រងដោយឈឺឆ្អាលនោះទេ។ ឧទាហរណ៍៖ អ្នកមានអំណាចមេបា ឬ ក៏ស្ថិតនៅក្រោមអាណាព្យាបាលទូទៅ។ល។

ចំណែកការគ្រប់គ្រងត្រូវបានធ្វើឡើង ដើម្បីបុគ្គលដទៃទៀត។ ឧទាហរណ៍៖ ដីមួយកន្លែងដែលជាកម្មសិទ្ធិរបស់ លោក ក ត្រូវបានទុកចោល។ ហើយលោក ខ បានយកដីមួយកន្លែងនោះ បើកតារាងបាល់ទះទុកសម្រាប់ជួល។ ក្នុងករណីនេះលោក ខ មិនអាចអនុវត្តការគ្រប់គ្រងដោយឈឺឆ្អាលបានទេ ដោយមូលហេតុលោក ខ មានបំណងយកជាប្រយោជន៍ខ្លួនឯង ដោយនេះជាបញ្ហាខាងច្បាប់ស្តីពីអំពើអនីត្យានុកូល។

លើសពីនេះ អ្នកគ្រប់គ្រងចាប់ផ្តើមគ្រប់គ្រងគឺជាការចាប់ផ្តើមសកម្មភាពគតិយុត្ត និងសកម្មភាពដទៃទៀត (១) សកម្មភាពគតិយុត្ត សម្តៅលើកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី[10] និង (២) សកម្មភាពដទៃទៀតគឺជាសកម្មភាពដែលបុគ្គលម្នាក់ចាប់ផ្តើមជួសជុល ឬ បំពេញជាដើម។ ចំពោះករណីបង្ហួចខូច ប្រសិនបើភាគីបង្កើតកិច្ចសន្យាជាមួយអ្នកជួសជុលថា អ្នកជួសជុលត្រូវតែបំពេញនូវកាតព្វកិច្ចជួសជុលបង្ហួចនោះ វាអាចជាការគ្រប់គ្រងសកម្មភាពគតិយុត្ត។ ប្រសិនបើគាត់ជួសជុលបង្ហួចដោយខ្លួនគាត់ផ្ទាល់ វាមិនមែនជាសកម្មភាពគតិយុត្តនោះទេ ប៉ុន្តែវានៅតែជាការគ្រប់គ្រងដដែរ។

ចំពោះការគ្រប់គ្រងដោយធ្វើឡើងតាមវិធីដែលសមរម្យជាងគេ និងដោយផ្អែកតាមឆន្ទៈ គឺការពារដោយ

[10] មាត្រា ៣៥៦ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

សាមីខ្លួនក្នុងការបង់សោហ៊ុយច្រើនហួសហេតុដោយការគ្រប់គ្រងដោយឈឺឆ្អាលនោះ ឬ ជាការធ្វើឲ្យត្រឹមត្រូវ និងយុត្តិធម៌ក្នុងនាមជាអ្នកជួយគ្រប់គ្រងដោយភាពសុចរិតនិងឆ្លើយតប នឹងអំពើមនុស្សធម៌ប្រកបដោយសីលធម៌ និងសមធម៌រវាងបុគ្គលឯកជន។ ជារួម អ្នកគ្រប់គ្រងធ្វើការគ្រប់គ្រងឱ្យសមស្របទៅតាមលក្ខណៈនៃការគ្រប់គ្រងចំពោះវិធីដែលសមស្របជាងគេ បើសិនជាអ្នកគ្រប់គ្រងបានដឹង ឬ អាចដឹងអំពីឆន្ទៈរបស់សាមីខ្លួនអ្នកគ្រប់គ្រងនោះត្រូវគ្រប់គ្រងដោយផ្អែកតាមឆន្ទៈនោះ។[11] ប៉ុន្តែ បើអ្នកគ្រប់គ្រងមិនអាចដឹងអំពីឆន្ទៈពិតប្រាកដទេ អ្វីដែលសមស្របជាងគេនោះ គឺកំណត់ដោយសត្យានុម័ត។

### ២. ករណីយកិច្ច

ករណីយកិច្ចគ្រប់គ្រងតាមវិធីដែលសមរម្យជាងគេ ដើម្បីជាប្រយោជន៍ និងអនុវត្តតាមឆន្ទៈរបស់សាមីខ្លួន គឺត្រូវគ្រប់គ្រងដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត។ ករណីយកិច្ចជូនដំណឹង គឺអ្នកគ្រប់គ្រងត្រូវជូនដំណឹងទៅសាមីខ្លួន ដោយហេតុថាអ្នកគ្រប់គ្នានេះគ្មានការព្រមព្រៀង និងមិនអាចដឹងពីឆន្ទៈរបស់សាមីខ្លួន។ ហេតុនេះហើយអ្នកគ្រប់គ្រងត្រូវមានករណីយកិច្ចជូនដំណឹងទៅសាមីខ្លួនឱ្យដឹងពីការគ្រប់គ្រងរបស់ខ្លួន ក៏ដូចជាដើម្បីឱ្យដឹងពីឆន្ទៈរបស់សាមីខ្លួន បង្ហាញពីភាពសុចរិត និងការគ្រប់គ្រងរបស់ខ្លួនដែរ។[12]

ចំណែកឯករណីយកិច្ចបន្តការគ្រប់គ្រងគឺប្រសិនបើអ្នកគ្រប់គ្រងបានធ្វើការគ្រប់គ្រងហើយ តែសាមីខ្លួនមិនទាន់ត្រឡប់មកវិញ ឬ ក៏មិនទាន់អាចគ្រប់គ្រងបានទេ អ្នកគ្រប់គ្រងដោយឈឺឆ្អាលត្រូវបន្តការគ្រប់គ្រងនោះបន្តទៅទៀតក្នុងន័យការពារ និងធ្វើឱ្យបានប្រយោជន៍ដល់សាមីខ្លួនផងដែរ រហូតដល់ពេលសាមីខ្លួនអាចធ្វើការគ្រប់គ្រងបានវិញ។ ម្យ៉ាងទៀត ករណីយកិច្ចធ្វើសេចក្តីរាយការណ៍គឺ ការគ្រប់គ្រងដោយឈឺឆ្អាលមានលក្ខណៈស្រដៀងគ្នានឹងអាណត្តិដែរ ហើយមានកាតព្វកិច្ចដូចគ្នាត្រូវធ្វើដើម្បីប្រយោជន៍សាមីខ្លួន និងរាយការណ៍អំពីដំណើរការនៃកិច្ចសន្យាផ្សេងៗដែលខ្លួនគ្រប់គ្រង។ ចំពោះករណីយកិច្ចទាមទារសំណងចំពោះប្រាក់ដែលបានចំណាយវិញ គឺករណីយកិច្ចនេះត្រូវបានដាក់បន្ទុកដោយផ្អែកទៅលើការត្រិះរិះពិចារណាមើលដូចគ្នា និងករណីយកិច្ចធ្វើសេចក្តីរាយការណ៍ផងដែរ។

### ៣. សិទ្ធិទាមទារឱ្យសងសោហ៊ុយ និងសិទ្ធិទាមទារកម្រៃ

ចំពោះអានុភាព គឺអ្នកគ្រប់គ្រងអាចទាមទារឱ្យសងមកវិញបាននូវសោហ៊ុយចាំបាច់ ដែលបានចំណាយសម្រាប់ការគ្រប់គ្រង។ អ្នកគ្រប់គ្រងក៏អាចទាមទារពីសាមីខ្លួនឱ្យផុតពីកាតព្វកិច្ច ឬ ផ្តល់ប្រាតិភោគដែលសមរម្យបាន។ ប្រសិនបើអ្នកគ្រប់គ្រងអាចធ្វើការគ្រប់គ្រងផ្ទុយពីឆន្ទៈរបស់សាមីខ្លួនចំនួននៃសំណងគឺ ត្រូវបាន

[11] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២, ឆ្នាំ២០១៣, ទំព័រ៧៧

[12] មាត្រា ៧៣១ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

កម្រិតត្រឹមតែផលប្រយោជន៍ដែលសមីខ្លួន បានទទួលជាក់ស្តែងប៉ុណ្ណោះ។[13] ថាតើសំណងនៃការខូចខាតដែលទទួលរងក្នុងអំឡុងពេលការគ្រប់គ្រងត្រូវបានរួមបញ្ចូលនៅក្នុងសោហ៊ុយចាំបាច់ ឬ ក៏អត់នោះគឺមិនត្រូវបានបង្ហាញច្បាស់លាស់នោះទេនៅក្នុងពាក្យពេចន៍ ដូច្នេះវាគឺជាបញ្ហាលំបាកមួយ។ ឧទាហរណ៍៖ នៅពេលដែលអ្នកគ្រប់គ្រងជួសជុលដោយប្រើកញ្ចក់ ហើយបណ្តាលឲ្យរបួសដៃគាត់។ ករណីនេះចាត់ទុកថា តម្លៃព្យាបាលរបួស ៥០ ដុល្លារ គឺការខូចខាត។ ចំណែកតម្លៃកញ្ចក់ ៣០០ ដុល្លារ អ្នកគ្រប់គ្រងអាចទាមទារ ៣០០ ដុល្លារនេះជាសោហ៊ុយចាំបាច់នៃការគ្រប់គ្រង។ ថាតើថ្លៃព្យាបាលរបួសចំនួន ៥០ ដុល្លារអាចបូកបញ្ចូល ឬ អត់នោះគឺអាស្រ័យទៅលើការបកស្រាយ។

**-ចំពោះមូលហេតុដែលមិនបូកបញ្ចូលៈ** វាមិនត្រូវបានរាប់បញ្ចូលទៅក្នុងសារហ៊ុយចាំបាច់នោះទេ។ ជាងនេះទៅទៀត គឺចាំបាច់ត្រូវដកពីចេញដើម្បីរារាំងកុំឱ្យសាមីខ្លួនទទួលបន្ទុកច្រើនជាងគាត់រំពឹងទុក (សាមីខ្លួនអាចត្រៀមរៀបចំសោហ៊ុយកញ្ចក់ ប៉ុន្តែមិនមែនសម្រាប់សោហ៊ុយព្យាបាលនោះទេ) ការខូចខាតនេះមិនត្រូវអាចបានទាមទារឡើយ។

**-ចំពោះមូលហេតុបញ្ចូលគ្នាៈ** ការគ្រប់គ្រងនេះ គឺស្របទៅនឹងឆន្ទៈរបស់សមីខ្លួនហើយក្នុងពេលគ្រប់គ្រងនោះមានការខូចខាតដែលមិនអាចជៀសវាងបាន ដូច្នេះតម្លៃក៏អាចបូករួមបញ្ចូលទៅក្នុងការទាមទារនូវសោហ៊ុយចាំបាច់ដែរ (នេះគឺជាការបកស្រាយ)។ ដោយផ្អែកទៅលើគំនិតនេះ ប្រសិនបើមានការខូចខាតអាចជៀសវាងបាន នោះអ្នកគ្រប់គ្រងមិនអាចធ្វើការទាមទារសំណងនៃការខូចខាតនេះជាសោហ៊ុយចាំបាច់នៃការគ្រប់គ្រងបានទេ។

ជាទូទៅ កម្រៃមិនអាចទាមទារបានទេ ដោយសារការគ្រប់គ្រងដោយឈឺឆ្អាលត្រូវចាប់ផ្តើមឡើងដោយគ្មានការយល់ព្រម (ដែលជាមូលហេតុចម្បងសម្រាប់ការលើកឡើងនូវកាតព្វកិច្ច ដើម្បីសងកម្រៃ) របស់សាមីខ្លួន។[14] ប៉ុន្តែនៅក្នុងករណីដែលការគ្រប់គ្រងត្រូវបានបញ្ចូលទៅក្នុងវិជ្ជាជីវៈ ឬ អាជីវកម្មរបស់អ្នកគ្រប់គ្រងសាមីខ្លួននឹងដឹងអំពីបញ្ហានេះ ហើយមិនអាចបដិសេធបានទេនោះហាក់ដូចជាអយុត្តិធម៌ដែលសាមីខ្លួនត្រូវអនុវត្តកាតព្វកិច្ច ប្រសិនបើគាត់ដឹងថាការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងត្រូវបានដាក់បញ្ចូលទៅក្នុងវិជ្ជាជីវៈ ឬ អាជីវកម្មរបស់អ្នកគ្រប់គ្រង។[15]

## ផ្នែកទី៤៖ សេចក្តីចម្រើនដោយឥតហេតុ

សេចក្តីចម្រើនដោយឥតហេតុ គឺជាការទទួលផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិ ឬ ពលកម្មរបស់

[13] មាត្រា ៧៣៣ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[14] អ៊ុក វណ្ណាវ័ត្ន, នីតិកាតព្វកិច្ច, ទំព័រទី២១

[15] មាត្រា ៧៣៥ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

អ្នកដទៃដោយគ្មានមូលហេតុតាមផ្លូវច្បាប់ ហើយធ្វើឲ្យមានការបាត់បង់ផលប្រយោជន៍របស់អ្នកដទៃដោយសារការទទួលផលនោះ។ សេចក្តីចម្រើនឥតហេតុ គឺសំដៅទៅលើការដែលបុគ្គលបានផ្តល់ផលប្រយោជន៍ពីទ្រព្យសម្បត្តិ ឬ ពលកម្មរបស់អ្នកដទៃបើទោះបីគ្មានមូលហេតុទៅលើផ្លូវច្បាប់ក៏ដោយ ការទទួលផលប្រយោជន៍នោះបានធ្វើឱ្យអ្នកដទៃបាត់បង់នូវផលប្រយោជន៍។[16] បុគ្គលដែលបានទទួលផលប្រយោជន៍នោះ បានហៅថា **"អ្នកទទួលផលប្រយោជន៍"** ឬ បុគ្គលដែលទទួលរងនូវការបាត់បង់ហៅថា **"អ្នកបាត់បង់ផលប្រយោជន៍"**។ ក្នុងករណីនេះ អ្នកទទួលផលប្រយោជន៍ត្រូវសងផលប្រយោជន៍នោះទៅអ្នកបាត់បង់ផលប្រយោជន៍វិញ។[17]

ឧទាហរណ៍៖ លោកសំណាង ជំពាក់លុយ ភារម្យ ១២០០ ដុល្លារអាមេរិក។ ហើយភារម្យ និងពិសិដ្ឋ ជាបងប្អូនភ្លោះ ដែលមានមុខមាត់ស្រដៀងគ្នា។ លោកសំណាង បានសងលុយ ១២០០ដុល្លារ ទៅឱ្យពិសិដ្ឋ ដោយស្មានថាគាត់ គឺជាភារម្យ។ សេចក្តីចម្រើនឥតហេតុត្រូវបានយកមកអនុវត្តក្នុងករណីនេះ ពីព្រោះលោកសំណាងទទួលរងនូវការបាត់បង់ផលប្រយោជន៍ ខណៈលោក ភារម្យ មិនមានមូលហេតុដើម្បីរក្សាទុកផលប្រយោជន៍នោះទេ។

## ១. លក្ខខណ្ឌនៃសេចក្តីចម្រើនដោយឥតហេតុ

ការទទួលបានផលប្រយោជន៍ គឺភាគីម្ខាងទទួលបានផលប្រយោជន៍ បានមកពីភាគីម្ខាងទៀតដែលបានបាត់នូវផលប្រយោជន៍ ដែលទទួលបានដូចជាផលប្រយោជន៍ដែលបាត់បង់អាចជាផលប្រយោជន៍រូបី ឬ ផលប្រយោជន៍អរូបីផងដែរ។ ផលប្រយោជន៍រូបី នៅក្នុងករណីនៃសេចក្តីចម្រើនឥតហេតុ គឺធម្មតាជាប្រាក់ ឬ ជាទំនិញ។ ប៉ុន្តែ ទ្រព្យសម្បត្តិទាំងឡាយណាដែលមិនអាចមើលឃើញដូចជាផលប្រយោជន៍នៅក្នុងការប្រើប្រាស់ ឬ ចាត់ចែង គឺបានរាប់បញ្ចូលទៅក្នុងផលប្រយោជន៍អរូបី។[18] ចំពោះការបាត់បង់ផលប្រយោជន៍ទំហំផលប្រយោជន៍ត្រូវសមាមាត្រទៅ នឹងផលប្រយោជន៍ដែលទទួលបាន។ នេះ គឺជាគោការណ៍នៃការសងត្រឡប់មកវិញនូវផលប្រយោជន៍ ដែលទទួលបានត្រឹមកម្រិតក្នុងទំហំនៃការបាត់បង់ផលប្រយោជន៍។ ជាទូទៅ ការបាត់បង់នូវផលប្រយោជន៍គឺឆ្លើយតបទៅនឹងទស្សនៈនៃផលប្រយោជន៍នៅក្នុងករណីភាគច្រើនបំផុត។

-**ទំនាក់ទំនងហេតុ និងផល** គឺជាលក្ខខណ្ឌមិនខុសគ្នាទៅនឹងលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌដើម្បីទាមទារសំណងការខូចខាត ដោយសារអំពើអនីត្យានីកូល គឺទំនាក់ទំនងហេតុ និងផលរវាងព្យសនកម្ម និងអំពើបំពានដោយខុសច្បាប់នូវសិទ្ធិ និងផលប្រយោជន៍។ ចំពោះសេចក្តីចម្រើនឥតហេតុ ដើម្បីទទួលស្គាល់នូវសិទ្ធិ ក្នុងការទាមទារយកមកវិញនូវផលប្រយោជន៍ដែលបានបាត់បង់បញ្ហាស្ថិតនៅត្រង់ថា តើមានអ្នក

[16] មាត្រា ៧៣៦ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[17] សេចក្តីកំណត់ចំពោះក្រមមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០, មាត្រា៧៣៦

[18] អ៊ុក វណ្ណាវ័ន្ត, នីតិកាតព្វកិច្ច, ទំព័រទី២១

បានទទួលនូវ ផលប្រយោជន៍កើតមានដែរ ឬទេ? តើមានអ្នកដែលបានទទួលផលប្រយោជន៍នោះដែរ ឬយ៉ាងណា?

ជាទូទៅទំនាក់ទំនងហេតុ និងផលត្រូវទទួលស្គាល់ករណីប្រសិនបើមានការបង្ហាញថា មានអ្នកទទួលបានផលប្រយោជន៍ដោយសារការបាត់បង់ផលប្រយោជន៍ពីអ្នកបាត់បង់ផលប្រយោជន៍នោះ ដោយគ្មានផលប្រយោជន៍។ ទំនាក់ទំនងហេតុ និងផលនៅក្នុងសេចក្ដីចម្រើនដោយឥតហេតុ ករណីភាគច្រើនមិនសូវបានចោទជាបញ្ហាធំដុំនោះទេ ដោយសារតែការបាត់បង់នៅក្នុងករណីភាគច្រើនត្រូវបានតភ្ជាប់ជាមួយនឹងការទទួលស្គាល់បានផលប្រយោជន៍ស្ទើរតែមិនអាចជៀសរួច។

លើសពីនេះ ការទទួលផលប្រយោជន៍ដោយគ្មានមូលហេតុលើផ្លូវច្បាប់គឺ គ្មានមូលហេតុត្រឹមត្រូវសម្រាប់រក្សានូវផលប្រយោជន៍។ ចំណុចនេះ មិនសមហេតុផលដែលអនុញ្ញាតឱ្យបុគ្គលដែលគ្មានមូលហេតុគតិយុត្តក្នុងការទទួលនូវផលប្រយោជន៍អាចរក្សាទុកនូវផលប្រយោជន៍ ដែលបានទទួលពីភាគីម្ខាងទៀតដែលបាត់បង់ផលប្រយោជន៍ដោយមិនត្រឹមត្រូវ។

## ២. ករណីយកិច្ចសងរបស់អ្នកទទួលផលប្រយោជន៍ ដោយមានគំនិតទុច្ចរិត

នៅក្នុងករណី ដែលបុគ្គលទទួលបានផលប្រយោជន៍បានដឹងថា គ្មានមូលហេតុទៅលើផ្លូវច្បាប់ ឬ កិច្ចនោះពុំមានអនុភាព បុគ្គលដែលទទួលបាននូវផលប្រយោជន៍នោះមានករណីយកិច្ចត្រូវសងផលប្រយោជន៍ដែលមាននៅពេលដឹង និងការប្រាក់គិតចាប់ពីពេលបានរហូតដល់ពេលសង។ ជាទូទៅមានការពិតនូវទំហំករណីយកិច្ចសង គឺដើម្បីការពារបុគ្គលដែលបានទទួលផលប្រយោជន៍ដែលមិនបានដឹង។ តែចំពោះបុគ្គលដែលទទួលបាននូវផលប្រយោជន៍បានដឹងថា ផលប្រយោជន៍នោះជារបស់អ្នកដទៃ ហើយមិនមែនជារបស់ខ្លួនគឺមិនមានភាពចំបាច់ដើម្បីទទួលបាននូវការការពារនោះឡើយ។ បុគ្គលដែលទទួលបានផលប្រយោជន៍មានចេតនា ឬ កំហុសចំពោះអានុភាពនៃកិច្ចសន្យាដែលត្រូវបាត់បង់។ បុគ្គលដែលបានទទួលផលប្រយោជន៍នោះមានករណីយកិច្ចត្រូវសងផលប្រយោជន៍នោះដោយភ្ជាប់មកជាមួយនឹងការប្រាក់ផងដែរ។

## ៣. ការសងដោយគ្មានកាតព្វកិច្ច ការសងនៅមុនពេលកំណត់ និងការសងកាតព្វកិច្ចរបស់អ្នកដទៃ

ប្រសិនបើបុគ្គលណាម្នាក់ដែលគ្មានកាតព្វកិច្ចបានសងកាតព្វកិច្ចនោះ ដូចនេះបុគ្គលនោះអាចត្រូវបានចាត់ទុកថាបានរងនូវការបាត់បង់ផលប្រយោជន៍។ ផ្ទុយទៅវិញ ប្រសិនបើបុគ្គលណាម្នាក់ដែលគ្មានសិទ្ធិនៅលើបំណុលបានទទួលការសងចំពោះសិទ្ធិលើបំណុលនោះ ត្រូវចាត់ទុកថាបានទទួលផលប្រយោជន៍ដោយគ្មានមូលហេតុគតិយុត្ត។ ប៉ុន្តែ បើបុគ្គលម្នាក់សងកាតព្វកិច្ចដោយដឹងអំពីនត្ថិភាពនៃកាតព្វកិច្ចនោះសកម្មភាពរបស់

បុគ្គលម្នាក់នោះ គឺចាត់ទុកថា សកម្មភាពមិនសមហេតុផលក្នុងន័យសេដ្ឋកិច្ចទីផ្សារហើយមិនចាំបាច់ត្រូវបានការពារដោយច្បាប់ទេ។ ហេតុដូច្នេះ តុលាការនឹងមិនគាំទ្រការទាមទារឱ្យសងដោយបុគ្គលដែលបានសងដោយដឹងថាខ្លួនមិនមានកាតព្វកិច្ច។[19] ម្យ៉ាងទៀត ចំពោះករណីដែលការសងដោយតតិយជន (ដែលតតិយជនគ្មានកាតព្វកិច្ចសងកាតព្វកិច្ចរបស់កូនបំណុល) ត្រូវបានធ្វើដោយមានសុពលភាព។ ក្នុងករណីនេះ ម្ចាស់បំណុលមានសិទ្ធិលើបំណុល ដូច្នេះការទទួលការសងពីតតិយជនដោយម្ចាស់បំណុលមិនអាចចាត់ទុកថា ម្ចាស់បំណុលបានទទួលផលប្រយោជន៍ ដោយគ្មានមូលហេតុគតិយុត្តនោះទេ។

ចំណែកឯការសងនៅមុនពេលកំណត់ ទោះបីជាកូនបំណុលមិនចាំបាច់សងកាតព្វកិច្ចរហូតដល់ពេលមានកំណត់ត្រូវសងក៏ដោយ ក៏កូនបំណុលអាចសងកាតព្វកិច្ចដោយបោះបង់ផលប្រយោជន៍នៃការកំណត់ពេលបានដែរ។ ជាគោលការណ៍ បើទោះបីជាកូនបំណុលសងកាតព្វកិច្ចមុនពេលកំណត់ក៏ដោយ ក៏កូនបំណុលមិនត្រូវបានអនុញ្ញាតឱ្យទាមទារការសងនូវតាវកាលិកឡើយ។ ប៉ុន្តែក្នុងករណីយកិច្ចដែលកូនបំណុលសងកាតព្វកិច្ចដោយមិនដឹងថាពេលកំណត់មិនទាន់ដល់ឡើយ នោះកូនបំណុលទទួលបានផលប្រយោជន៍ទៅតាមការលះបង់ផលប្រយោជន៍នៃការកំណត់ពេលនោះ។[20] ហេតុដូច្នេះ ក្នុងករណីដែលកូនបំណុលបានសងកាតព្វកិច្ចដោយមិនដឹងថា កាតព្វកិច្ចមិនទាន់ដល់ពេលកំណត់សងឡើយ។ កូនបំណុលអាចទាមទារឱ្យសងផលប្រយោជន៍ដែលម្ចាស់បំណុលអាចប្រើប្រាស់តាវកាលិក ដែលខ្លួនបានទទួលមុនពេលកំណត់សងរហូតដល់ពេលកំណត់សង (ផលប្រយោជន៍នៅក្នុងចន្លោះពេលម្ចាស់បំណុលបាន)។ ចំពោះការចាត់ចែងការប្រាក់ដែលបង្ករហូតដល់ពេលកំណត់ត្រូវសង គប្បីត្រូវបានជាផលប្រយោជន៍របស់កូនបំណុល។[21]

ឧទាហរណ៍៖ ក ខ្ចីប្រាក់ពី ខ ចំនួន ៩៥០ ដុល្លារ ដោយកំណត់ពេលសង ថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០២០។ ក សងប្រាក់ ខ ចំនួន ៩៥០ ដុល្លារ ដោយកំណត់ពេលសង ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០២០។

ក្រមរដ្ឋប្បវេណី មាត្រា ៧៣៩ ជាគោលការណ៍ ក មិនអាចទាមទារឱ្យ ខ ប្រគល់ប្រាក់ដែលបានសងរួចនោះមកវិញបានឡើយ។ ប៉ុន្តែ នៅក្នុងករណី ក ជឿជាក់ដោយភាន់ច្រឡំថាដល់ពេលកំណត់សង ហើយក្រោយពេលសងទើបដឹង។ នោះ ក អាចទាមទារឱ្យ ខ សងផលប្រយោជន៍ដែលទទួលបានចន្លោះពេលមួយខែ ដែល ខ អាចប្រើប្រាស់ប្រាក់ចំនួន ៩៥០ ដុល្លារនោះ (ដូចជា ការប្រាក់) ។

នៅក្នុងករណី បុគ្គលម្នាក់ក្រៅពីកូនបំណុលបានផ្តល់តាវកាលិក នៃការសងដោយភាន់ច្រឡំកាតព្វកិច្ចរបស់អ្នកដទៃថាជា កាតព្វកិច្ចរបស់ខ្លួនអាចទាមទារតាវកាលិកនោះមកវិញបាន។ ប៉ុន្តែក្នុងករណីដែលម្ចាស់

[19] អ៊ុក វណ្ណារ័ត្ន, នីតិកាតព្វកិច្ច, ទំព័រទី២២

[20] មាត្រា ៧៣៩ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[21] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១៣, ភាគ២, ទំព័រ៨៧

បំណុលពុំបានដឹងថា ការផ្តល់តាវកាលិកនោះបណ្តាលមកពីការភ័ន្តច្រឡំរបស់បុគ្គលដែលបានផ្តល់តាវកាលិកនៃការសងនោះទេ ហើយបានបំផ្លាញលិខិតជាលាយលក្ខណ៍អក្សរដែលមានការបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើបំណុល ឬ ការបោះបង់ប្រាតិភោគចោលដោយបានជឿជាក់ថា ការសងដែលមានសុពលភាពបុគ្គលដែលបានផ្តល់តាវកាលិកនោះ មិនអាចទាមទារឱ្យសងតាវកាលិកនោះមកវិញបានឡើយ។[22]

## ផ្នែកទី៥៖ អំពើអនីត្យានុកូល

អំពើអនីត្យានុកូល គឺជារបបដែលតំរូវអោយសងនូវសំណងនៃការខូចខាត ក្នុងករណីដែលបានបំពាននូវសិទ្ធិ ឬ ផលប្រយោជន៍របស់អ្នកដទៃដោយខុសច្បាប់ទោះក្នុងទំរង់ជា កំហុសចេតនា ឬ កំហុសចេតនាក្តី។ ដូចនេះ បុគ្គលដែលមានសិទ្ធិ ឬ ផលប្រយោជន៍របស់ខ្លួនត្រូវបានគេបំពានមានសិទ្ធិទាមទារនូវសំណងនៃការខូចខាតចំពោះចារី។[23] នៅពេលដែលអំពើអនីត្យានុកូលកើតឡើង ជនរងគ្រោះអាចទាមទារសំណងការខូចខាតដែលខ្លួនបានទទួលរងពីចារីមានន័យថា ជនរងគ្រោះដោយអំពើអនីត្យានុកូលធ្វើលទ្ធកម្មនូវសិទ្ធិលើបំណុលនៃសំណងការខូចខាតចំពោះចារី។ បើមើលពីទស្សនៈម្ខាងទៀត ចារីត្រូវសងសំណងការខូចខាតដែលកើតឡើងនោះទៅជនរងគ្រោះ។ ពោល ចារីមានកាតព្វកិច្ចសងការខូចខាតចំពោះជនរងគ្រោះ។ ក្នុងករណីនេះ គឺជាការកើតឡើងនូវទំនាក់ទំនងនៃសិទ្ធិបំណុល និង កាតព្វកិច្ចដោយសារអំពើអនីត្យានុកូល។ អំពើអនីត្យានុកូល គឺជាអំពើដែលបំពានដោយខុសច្បាប់ទៅលើសិទ្ធិ ឬ ផលប្រយោជន៍អ្នកដទៃដោយកំហុសចេតនា ឬ អចេតនា។ កំហុសដោយចេតនា ឬ អចេតនាសំដៅដល់អំពើដែលត្រូវនឹងចំណុចដូចខាងក្រោម៖

-ធ្វើអំពើបំពានដោយព្យាករទុកជាមុន អំពីការកើតឡើងនៃលទ្ធផលហើយទទួលយកការកើតឡើងនៃលទ្ធផលនោះ។ ឧទាហរណ៍៖ ក និង ខ មានជម្លោះជាមួយគ្នា។ ដោយ ខ បានប្រើពាក្យសំដីមិនសមរម្យ និងធ្វើកាយវិការមិនសមរម្យចំពោះ ក។ ស្របពេលនោះ ដោយមានចិត្តក្តៅមួយពេល ក បានស្ទុះទាញកំបិតរត់សំដៅទៅចាក់ ខ បណ្តាលឱ្យរបួសដៃខាងស្តាំជាទម្ងន់ ដោយកំហុសចេតនា។

-ធ្វើអំពើបើតាមប្រក្រតីបុគ្គលដែលមានឋានៈនៃការងារ ឬ បទពិសោធន៍ស្មើគ្នានឹងអ្នកធ្វើអំពើនោះអាចព្យាករទុកជាមុន អំពើការកើតឡើងនៃលទ្ធផលក៏ដោយ ក៏អ្នកធ្វើអំពើនោះនៅតែពុំបានព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលនោះដោយសារការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ហើយទោះជាករណីយកិច្ចជៀសវាងនូវលទ្ធផលនោះក៏ដោយ ក៏នៅតែប្រព្រឹត្តផ្ទុយចំពោះករណីយកិច្ចនោះ។[24]

---

[22] មាត្រា ៧៤០ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[23] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១៣, ភាគ២, ទំព័រ៩១

[24] មាត្រា ៧៤២ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

ឧទាហរណ៍៖ ក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍មួយដែលលោក បញ្ញា បើកឡានទៅបុករបងផ្ទះលោក ពិសិដ្ឋ បណ្ដាលឲ្យបាក់ទ្វាររបងផ្ទះ ដូច្នេះអំពើលោក បញ្ញា ដែលបានបុកផ្ទះលោក ពិសិដ្ឋ បណ្ដាលឱ្យមានការខូចខាតនោះ គឺជាអំពើអនីត្យានុកូល។ ក្នុងករណីនេះលោក ពិសិដ្ឋ មានសិទ្ធិទាមទារសំណងនៃការខូចខាតពីលោក បញ្ញា វិញបាន។ លក្ខខណ្ឌនៃអំពើអនីត្យានុកូលយោងតាមអំពើអនីត្យានុកូល ដើម្បីឱ្យជនរងគ្រោះទាមទារសំណងនៃការខូចខាតពីអ្នកប្រព្រឹត្តអំពើបំពានចាំបាច់ត្រូវបំពេញនូវលក្ខខណ្ឌបានកំណត់។[25] ដើម្បីឱ្យបុគ្គលណាម្នាក់ទទួលនូវខុសត្រូវចំពោះសំណងនៃការខូចខាតដោយផ្អែកទៅលើអំពើអនីត្យានុកូល លុះត្រាតែបំពេញលក្ខខណ្ឌដែលច្បាប់បានកំណត់ដូចខាងក្រោម៖

## ១. កំហុស

កំហុស គឺជាអាកប្បកិរិយារបស់បុគ្គលម្នាក់ដោយសារការធ្វេសប្រហែស ខ្ជីខ្ជា ការមិនប្រុងប្រយត្ន័ ការមិនយកចិត្តទុកដាក់របស់ខ្លួនមិនគោរពតាមកិច្ចសន្យា **"កំហុសនៅក្នុងកិច្ចសន្យា"** ឬ មិនបំពេញករណីយកិច្ចរបស់ខ្លួន ដែលមិនត្រូវបង្កអោយមានការខូចខាតដល់អ្នកដទៃ **"កំហុសរដ្ឋប្បវេណី"** ឬ ហៅម្យ៉ាងទៀតថា **"កំហុសទោសកម្ម ឬ កំហុសឧបាទោសកម្ម"** ។ កំហុសទោសកម្ម គឺផ្ទុយពីកំហុសនៅក្នុងកិច្ចសន្យាដោយវាស្ថិតនៅក្រៅវង្វង់នៃកិច្ចសន្យា។ ផ្ទុយពីកំហុសឧបទោសកម្ម គឺជាអំពើខុសច្បាប់ខុសពីសីលធម៌ប្រព្រឹត្តឡើងក្នុងគំនិតចង់បង្កឲ្យមានអន្តរាយដល់អ្នកដទៃ។

**-កំហុសដោយចេតនា** គឺជាកំហុសដែលបង្កើតឡើងពីឆន្ទៈរបស់ចារីហើយចង់បង្កឱ្យមានព្យសនកម្មដែលជនរងគ្រោះ។ កំហុសនេះអាចជាទង្វើបង្កជា បទល្មើសព្រហ្មទណ្ឌ ឬ ទង្វើដែលមិនត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌដែរ។ អំពើដែលមានកំហុសចេតនា សំដៅទៅលើអំពើដែលជាអំពើបំពានដោយព្យាករទុកជាមុន អំពីការកើតឡើងនៃលទ្ធផលហើយដោយទទួលយកការកើតឡើងនៃលទ្ធផលនោះ។[26]

**-កំហុសដោយអចេតនា** គឺជាកំហុសដែលកើតឡើង ដោយសារការធ្វើធ្វេសប្រហែស ការខ្ជីខ្ជា ឬ ការខ្វះការប្រុងប្រយ័ត្នរបស់ចារីនៃការខូចខាត ដូចជាកំហុសរបស់អ្នកបើកបរដែលបានបើកលឿនហួសកំណត់នៅក្នុងទីប្រជុំជន ហើយបានជ្រុលទៅបុកអ្នកកំពុងធ្វើដំណើរនៅលើដងផ្លូវបណ្ដាលឱ្យមានរបួស ឬ បាត់បង់ជីវិត។ អ្នកបើកបរលឿនហួសនោះខុសច្បាប់ពិតមែនប៉ុន្តែគាត់គ្មានបំណងចង់បុកនោះឡើយ។[27]

### ១.១ ភាពខុសច្បាប់

បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍របស់ជនដទៃទៀតដោយកំហុសចេតនា ឬ

[25] មាត្រា ៧៤៣ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[26] មាត្រា ៧៤២ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[27] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១៣, ភាគ២, ទំព័រ៩៣

កំហុសអចេតនាក្តីត្រូវទទួលខុសត្រូវដោយសងការខូចខាតដែលកើតឡើងដោយអំពើនោះ។[28] ការបំពាននៅក្នុងទីនេះគឺមានន័យថា មិនត្រឹមតែការបំពានច្បាប់ព្រហ្មទណ្ឌតែប៉ុណ្ណោះទេ។ ប៉ុន្តែថែមទាំងជាអំពើមួយដែលផ្ទុយជាមួយនឹងវិន័យសង្គម។ ដូច្នេះករណីយកិច្ចដែលត្រូវចៀសវាងគឺ ស្ទើរតែជាន់គ្នាជាមួយនឹងភាពខុសច្បាប់ពោលមូលហេតុដែលករណីកិច្ចត្រូវចៀសវាងនោះបានដាក់បន្ទុក ពីព្រោះវាផ្ទុយជាមួយនឹងវិន័យសង្គម។[29] លើសពីនេះទៅទៀត បុគ្គលដែលបំពានសិទ្ធិ ឬ ផលប្រយោជន៍របស់អ្នកដទៃហើយបង្កឱ្យមានអន្តរាយដោយសារអំពើនោះ គឺជាការប្រើប្រាស់សិទ្ធិដោយបំពាន ជាអាទិ៍។ សកម្មភាពនៃការបំពានអាចស្តែងចេញជា ២ រូបភាពគឺៈ ទីមួយ គឺសកម្មភាពជាក់ស្តែងក្នុងការប្រព្រឹត្ត និងទីពីរ គឺជារូបភាពអកម្មដោយបុគ្គលនោះមិនអាចធ្វើអំពើណាមួយដែលជាកាតព្វកិច្ចរបស់ខ្លួន ឬ ជាការកំណត់របស់ច្បាប់ដែលបណ្តាលឱ្យខូចខាតប្រយោជន៍របស់អ្នកដទៃ ហើយកម្មវត្ថុនៃការបំពានអាចជាសិទ្ធិលើទ្រព្យសម្បត្តិ ឬ សិទ្ធិក្រៅពីទ្រព្យសម្បត្តិ។ អំពើរំលោភបំពានត្រូវចែកចេញជា ៤ រូបភាពដូចជាៈ អំពើបំពានលើបទបញ្ញត្តិច្បាប់ អំពើបំពានលើសណ្តាប់ធ្នាប់សាធារណៈ ការអន្តរាយដល់តតីយជនដោយសារវិការៈនៃវត្ថុ និង ការប្រើប្រាស់សិទ្ធិដោយបំពាន។ អំពើបំពានទៅលើបទបញ្ញត្តិច្បាប់ គឺជាការបំពានសិទ្ធិ និងផលប្រយោជន៍របស់អ្នកដទៃដែលត្រូវបានការពារ។ រីឯអំពើបំពានលើសណ្តាប់ធ្នាប់សាធារណៈ ឬ ហៅម្យ៉ាងទៀតថាសីលធម៌សង្គមវិញ គឺជាស្ថានភាពជាក់ស្តែងនៃការបំពាននោះដោយនៅក្នុងច្បាប់មិនមានបញ្ញត្តិ ប៉ុន្តែសង្គមចាត់ទុកថាជាអំពើមួយដែលមិនត្រឹមត្រូវផ្ទុយពីច្បាប់។ ហើយចំពោះការអន្តរាយដល់តតីយជនបង្កឡើងដោយវិការៈវត្ថុ ដូចជាការទទួលខុសត្រូវរបស់ ផលិតផលចំពោះវត្ថុដែលមានគ្រោះថ្នាក់បង្កឲ្យមានគ្រោះថ្នាក់ដល់តតីយជន ដូចជាឧបករណ៍ប្រើប្រាស់ គ្រឿងចក្រជាដើមដែលបង្កឲ្យការខូចខាតដល់អ្នកប្រើប្រាស់ ជាអាទិ៍។ រីឯការប្រើប្រាស់សិទ្ធិដោយបំពាន គឺជាស្ថានភាពនៃសិទ្ធិទទួលបានពន្លឺព្រះអាទិត្យ ទទួលបាននូវបរិស្ថានជុំវិញខ្លួន និងអគារខ្ពស់ៗ ចំណតយានយន្ត ជាដើម។

### **១.២ ការខូចខាត ឬ ព្យសនកម្ម**

ព្យសនកម្ម គឺជាការខូចខាតសម្ភារៈ (ដូចជាការបាត់បងនូវទ្រព្យសម្បត្តិនូវស្ថានភាពវិជ្ជាជីវៈ ឬ ខូចខាតខាងផ្លូវចិត្ត ដែលបុគ្គលណាម្នាក់បានទទួលរងបណ្តាលមកពីអំពើរបស់ជនដទៃទៀត។ ដោយក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ មិនបានប្រើពាក្យព្យសនកម្មទេដោយប្រើពាក្យថាការ ខូចខាតជំនួសវិញ។ ជាពិសេស ការខូចខាតដោយបំពានទៅលើរូបកាយ (មាត្រា ៧៦០ & មាត្រា ៧៦១) និង ការទាមទារសំណងនៃការខូចខាតផ្នែកដោយសតិអារម្មណ៍ (មាត្រា ៧៦២) ។

[28] មាត្រា ៧៤៣ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[29] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១៣, ភាគ២, ទំព័រ៩៦

### ១.៣ ទំនាក់ទំនងហេតុ និង ផល

ទំនាក់ទំនងហេតុ និងផលមានន័យថា ជាទំនាក់ទំនងនៃហេតុផលនៃការកើតឡើងនូវការខូចខាតរបស់ជនរងគ្រោះ និងចេតនា ឬ កំហុសរបស់ចារី។ វាជារឿងធម្មតាទេដែលត្រូវចាំបាច់មានអត្ថិភាពនៃទំនាក់ទំនងហេតុនិងផល ដើម្បីកំណត់ថាចារីបានបង្កឱ្យមានការខូចខាតដល់ជនរងគ្រោះ។[30] ឧទាហរណ៍ ១៖ អ្នកបើកបរមិនបានមើលភ្លើងសញ្ញាចរាចរណ៍ ក៏បានទៅជ្រុលទៅបុកអ្នកថ្មើរជើងដែលកំពុងដើរឆ្លងកាត់គំនូសផ្លូវ ថ្នល់ និងបង្កឱ្យមានរបួស។ ករណីបែបនេះ គឺជាទំនាក់ទំនងហេតុផលរវាងអ្នកថ្មើរជើងដែលទទួលរងគ្រោះជាមួយនឹងការធ្វេសប្រហែសរបស់អ្នកបើកបរ គឺវាមានភាពច្បាស់លាស់ដែលមិនមានចម្ងល់អ្វីឡើយ។ ដើម្បីឱ្យជនណាម្នាក់ទទួល ខុសត្រូវការសងសំណងការខូចខាតនោះ ត្រូវតែមានទំនាក់ទំនងហេតុផលរវាងអំពើ និងការខូចខាតដែលបញ្ជាក់ថាការខូចខាតទាំងនោះ ពិតជាបានកើតចេញអំពីអំពើអនីត្យានុកូលយ៉ាងពិតប្រាកដ មែនអ្នកដែលទាមទារការខូចខាតមានករណីកិច្ចបញ្ជាក់ពីភស្តុតាងនេះផងដែរ។[31] ឧទាហរណ៍ ២៖ លោក ក បានប្ដឹងទាមទារសំណងការខូចខាត ដោយខ្លួនត្រូវរបួសពីលោក ខ។ ក្នុងករណីនេះ លោក ក ត្រូវបានធ្វើការបង្ហាញថា លោក ខ គឺជាអ្នកបានធ្វើឱ្យខ្លួនរងរបួសបណ្ដាលមានការខូចខាត។ និយាយម្យ៉ាងទៀត ការខូចខាតគឺត្រូវតែសងខាងក្នុងករណីដែលការខូចខាតនោះមិនបានកើតឡើងទេ។ ប៉ុន្តែការខូចខាតនោះកើតឡើងដោយសារអំពើអនីត្យានុកូល។

## ២. ប្រភេទការទទួលខុសត្រូវ (អំពើអនីត្យានុកូល)

ជាដំបូង ការទទួលខុសត្រូវចំពោះខ្លួនឯងគឺ បុគ្គលដែលបំពានដោយច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍របស់ជនដទៃដោយកំហុសចេតនា ឬ កំហុសអចេតនាត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ។ ជនដែលនៅក្រោម អាយុ ១៤ (ដប់បួន) ឆ្នាំមិនត្រូវទុកឲ្យត្រូវចំពោះអំពើអនីត្យានុកូលទេ។ បុគ្គលដែលស្ថិតនៅក្នុងស្ថានភាពដែលមិនអាចយល់ដឹង និងវិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួននៅពេលដែលខ្លួនបានប្រព្រឹត្តអំពើបំពាននោះ ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារត ឬ មូលហេតុផ្សេងទៀតមិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលឡើយ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលមានស្ថានភាពនោះបណ្ដាលមកដោយកំហុសចេតនា ឬ កំហុសអចេតនា។[32]

ចំណែកឯការទទួលខុសត្រូវចំពោះអំពើអ្នកដទៃគឺ ការទទួលខុសត្រូវចំពោះអំពើអ្នកដទៃ ជាការទទួលខុសត្រូវចំពោះការខូចខាតដែលបង្កឡើងដោយអ្នកដទៃដោយផ្អែកផ្អែកលើទំនាក់ទំនងគតិយុត្ត ហើយយើងជា

[30] សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១៣, ភាគ២, ទំព័រ១០៣

[31] សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១៣, ភាគ២, ទំព័រ១០០

[32] មាត្រា ៧៤៥ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

អ្នកទទួលខុសត្រូវជំនួសឱ្យបុគ្គលនោះ។ ប្រភេទនៃការទទួលខុសត្រូវចំពោះអំពើរបស់អ្នកដទៃ មានដូចជា៖

-**ការទទួលខុសត្រូវ ចំពោះអ្នកមានករណីយកិច្ចត្រួតពិនិត្យ** គឺអ្នកដែលមានករណីយកិច្ចត្រួតពិនិត្យ ដោយសំដៅទៅលើឪពុកម្តាយ អាណាព្យាបាល ឬ ហិតូបត្ថម្ភ (ហិតូបត្ថម្ភ គឺការគ្រប់គ្រងទៅលើជនដែលមាន សមត្ថភាពតិចតួចពេកក្នុងការយល់ដឹង ឬ វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារ មានវិបត្តិផ្នែកបញ្ញាស្មារតី)។ បុគ្គលដែលមានករណីយកិច្ចដែល ច្បាប់បានកំណត់ក្នុងការត្រួតពិនិត្យអនីតិជន ដែលមានអាយុ ក្រោម ១៤ (ដប់បួន) ឆ្នាំ ឬ បុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង ឬ វិនិច្ឆ័យ បានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ដោយសារការវិបត្តិផ្នែកបញ្ញាស្មារតី ឬ ហេតុផ្សេងទៀតមាន ករណីយកិច្ចត្រូវសងការខូចខាតរបស់អ្នកដទៃ ដែលកើតឡើងដោយអំពើបំពានរបស់បុគ្គលនៅក្រោមការត្រួត ពិនិត្យរបស់ខ្លួននេះ។ ហើយបុគ្គលដែលមានករណីកិច្ចនេះត្រូវទទួលខុសត្រូវដោយសាមគ្គីភាពជាមួយនឹង អនីតិជនចំពោះការខូចខាតរបស់អ្នកដទៃ ដែលបានកើតឡើងដោយអំពើអនីត្យានុកូលរបស់អនីតិជននោះ។[33]

-**ការទទួលខុសត្រូវរបស់និយោជក** គឺនិយោជកជាអ្នកប្រើនិយោជិតឱ្យពង្រីកសកម្មភាពដើម្បីរកផល ចំណេញឱ្យខ្លួន។ ហេតុនេះ ចំពោះអំពើអនីត្យានុកូលដែលបង្កឡើងដោយនិយោជិត **"ក្នុងការអនុវត្តកិច្ចការ"** និយោជកត្រូវទទួលខុសត្រូវជំនួសនិយោជិត។ គេបានដាក់បន្ទុកឱ្យនិយោជក ទទួលខុសត្រូវនូវអំពើ អនីត្យានុកូលដែលបានធ្វើឡើងដោយនិយោជិត។ ប្រសិនបើអំពើនោះត្រូវបានបំពេញ លក្ខខណ្ឌនៃអំពើ អនីត្យានុកូល ទោះបីជានិយោជកនោះគ្មានកំហុសក៏ដោយ។ ការទទួលខុសត្រូវនេះ គឺជាការទទួលខុសត្រូវ ដោយឧបាទេសកម្ម។ ផ្ទុយទៅវិញ ប្រសិនបើនិយោជកអាចបញ្ជាក់ថា ខ្លួនពុំមានកំហុសក្នុងការជ្រើសតាំង ឬ ត្រួតពិនិត្យនិយោជិតនេះទេ គឺនិយោជកនោះអាចរួចផុតពីការទទួលខុសត្រូវនោះបាន។ ក៏ប៉ុន្តែ ដោយសារតែការ ចាំបាច់ត្រូវសង្គ្រោះអ្នករងគ្រោះ ពុំសូវមានយុទ្ធសាស្ត្រដែលបានអនុគ្រោះឱ្យនិយោជករួចផុតពីការទទួលខុស ត្រូវនោះទេ។ ហើយមូលហេតុនៃការទទួលខុសត្រូវរបស់និយោជកត្រូវបានពន្យល់ថា ជាការទទួលខុសត្រូវ ចំពោះការទទួលផល (អ្នកដែលទទួលផលប្រយោជន៍) ត្រូវទទួលខុសត្រូវចំពោះការខូចខាតផងដែរ ឬ ការទទួល ខុសត្រូវចំពោះហានិភ័យ (ការទទួលខុសត្រូវចំពោះការនាំមកនូវហានិភ័យដល់សង្គម ក្នុងការធ្វើសកម្មភាពរបស់ សហគ្រាស)។[34]

-**អំពើអនីត្យានុកូលរបស់នីតិបុគ្គល និងអំពើអនីត្យានុកូលរបស់មន្ត្រីរាជការ** គឺការទទួលខុសត្រូវរបស់ នីតិបុគ្គលបានកំណត់ថា នីតិបុគ្គលត្រូវទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាតដែលសមាជិកគណៈ កម្មាធិការនាយក ឬ តំណាងបានធ្វើអោយខូចខាតដល់ប្រយោជន៍របស់អ្នកដទៃ ដោយអំពើអនីត្យានុកូល។

[33] មាត្រា ៧៤៦ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[34] សេចក្តីកំណត់ចំពោះក្រមមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០, មាត្រា៧៤៧

លក្ខខណ្ឌនៃការទទួលខុសត្រូវរបស់និយោជកត្រូវយកមកអនុវត្តដូចគ្នាផងដែរដែរ។ ក្នុងករណីដែលនីតិបុគ្គលត្រូវទទួលខុសត្រូវក្នុងការ សងសំណងនៃការខូចខាត ដែលកើតឡើង ដោយសារអំពើរបស់អ្នកតំណាងខ្លួន។[35] ក្នុងករណី នីតិបុគ្គលបានសងសំណងនៃការខូចខាតឱ្យទៅជនរងគ្រោះរួចហើយ នីតិបុគ្គលអាចទាមទារសំណងពីតំណាងដែលបានប្រព្រឹត្តអំពើអនីត្យានុកូលនោះ នូវទឹកប្រាក់ចំនួនដែលខ្លួនបានសង។ មន្ត្រីរាជការដែលទទួលបាននូវអំណាចសាធារណៈរបស់រដ្ឋ ឬ ស្ថាប័នសាធារណៈបានបង្កឱ្យមានការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ដោយកំហុសចេតនា ឬ អចេតនាក្នុងការអនុវត្តភារកិច្ចរបស់ខ្លួននោះរដ្ឋ ឬ ស្ថាប័នសាធារណៈត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាតនេះ។

ក្នុងករណី កម្រិតនៃការបំពានករណីកិច្ចរបស់មន្ត្រីរាជការក្នុងការជ្រើសរើសនូវលទ្ធផលមានភាពធ្ងន់ធ្ងរនោះរដ្ឋ ឬ ស្ថាប័នសាធារណៈអាចទាមទារសំណងពីមន្ត្រីរាជការមកបាន។[36] អ្នករាជការសាធារណៈគឺ ជាបុគ្គលដែលបម្រើនៅក្នុងស្ថាប័ននីតិបញ្ញត្តិ ឬ ស្ថាប័ននីតិប្រតិបត្តិ ឬ ស្ថាប័នតុលាការដែលបានតែងតាំង ដោយលិខិតបទដ្ឋានគតិយុត្តទោះបីជាអចិន្ត្រៃយ៍ ឬ បណ្តោះអាសន្នក្តី ហើយទោះជាទទួល ឬ មិនទទួលប្រាក់ឈ្នួលក្តីដោយមិនគិតពីឋានៈអាយុរបស់បុគ្គលនោះឡើយ។

### ៣. ការទទួលខុសត្រូវចំពោះអំពើរបស់សត្វ និង វត្ថុ

**-ការទទួលខុសត្រូវអំពើសត្វរបស់អ្នកកាន់កាប់សត្វ** គឺបុគ្គលដែលបានកាន់កាប់សត្វត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលបានកើតឡើងដល់អ្នកដទៃដោយសត្វដែលខ្លួនកាន់កាប់។ ដោយបានកំណត់អំពីការទទួលខុសត្រូវដោយគ្មានកំហុសរបស់អ្នកកាន់កាប់សត្វ។ នៅក្នុងនេះ ពុំមានការអនុញ្ញាតឱ្យរួចផុតពីការទទួលខុសត្រូវទេ ដោយយោងតាមក្រមរដ្ឋប្បវេណីបារាំងផងដែរ។ នេះ គឺជាឧទាហរណ៍នៃការទទួលខុសត្រូវចំពោះវត្ថុដែលមានគ្រោះថ្នាក់។

**-ការទទួលខុសត្រូវចំពោះផលិតផលរបស់អ្នកផលិតវត្ថុ** គឺផលិតករនៃចលនវត្ថុត្រូវទទួលខុសត្រូវសងការខូចខាតដោយសារចលនវត្ថុរបស់ខ្លួនបណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃ ដែលមានវិការៈនោះនាំឱ្យមានគ្រោះថ្នាក់ដោយមិនសមហេតុផល។ អ្នកដែលផលិតចលនវត្ថុដែលផ្សំដោយគ្រឿង ឬ វត្ថុធាតុដើមដែលមានវិការៈត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតក្នុងនាមជាផលិតករផងដែរ។ ចំពោះអ្នកនាំចូលចលនវត្ថុត្រូវចាត់ទុកជា "**ផលិតករ**" ហើយបុគ្គលដែលបានដាក់ សញ្ញាណនៃនាមករណ៍របស់ខ្លួនជាផលិតករ ឬ ជាអ្នកលក់នូវចលនវត្ថុត្រូវចាត់ទុកជាផលិតករនៃចលនវត្ថុនោះ។[37] លើសពីនេះទៀត កម្មវត្ថុនៃការទទួលខុសត្រូវ

[35] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១៣, ភាគ២, ទំព័រ១១៣

[36] មាត្រា ៧៤៩ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[37] មាត្រា ៧៥១ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

ចំពោះផលិតផលដោយអ្នកផលិតគឺជា ចលនវត្ថុដែលត្រូវបានផលិត។ ហើយបញ្ញត្តិនេះមិនត្រូវយកមកអនុវត្ត ចំពោះអចលនវត្ថុឡើយ។ ចំពោះចលនវត្ថុដែលមិនបានកែច្នៃ ដូចជាត្រីដែលស្ទូចបានក៏មិនអនុវត្តតាមមាត្រានេះដែរ។ ក្នុងចំណុចនេះមានការលើកឡើងនូវ **"វិការៈដែលនាំឱ្យមានគ្រោះថ្នាក់មិនសមហេតុផល"** ដែលជាលក្ខខណ្ឌនៃការទទួលខុសត្រូវ។[38]

-**ការទទួលខុសត្រូវចំពោះវត្ថុគ្រោះថ្នាក់** គឺបុគ្គលជាកម្មសិទ្ធិករ ឬ អ្នកគ្រប់គ្រងរថយន្ត គ្រឿងចក្រសំរាប់ដឹកជញ្ជូនផ្សេងទៀត គ្រឿងផ្ទុះ វត្ថុធាតុ វិទ្យុសកម្ម ឬ វត្ថុធាតុគីមីដែលមានជាតិពុល អតិសុខុមប្រាណឧត្បាត ឬ គ្រឿងដែលមានកម្រិតគ្រោះថ្នាក់ខ្ពស់ទៀតផ្សេងទៀត គឺត្រូវទទួលខុសត្រូវក្នុងការ សងការខូចខាតដែលបង្កដល់អ្នកដទៃដោយសារវត្ថុគ្រោះថ្នាក់នៅខ្លួនមានកម្មសិទ្ធិ ឬ គ្រប់គ្រងនោះ។ ដោយការទទួលខុសត្រូវចំពោះវត្ថុដែលមានគ្រប់គ្រងដោយបុគ្គលដែល ជាកម្មសិទ្ធករ ឬ អ្នកគ្រប់គ្រងរថយន្ត ឬ វត្ថុដែលមានគ្រោះថ្នាក់ផ្សេងទៀត។ ហេតុនេះហើយគឺមានភាពធំ ទូលាយណាស់។ លក្ខខណ្ឌនៃការទទួលខុសត្រូវមិនតម្រូវឱ្យមានកំហុសទេ ប៉ុន្តែ (១) ចំពោះក្នុងករណីដែលមានការខូចខាតដោយប្រធានសក្តិ ឬ (២) ក្នុងករណី ដែលពុំមានវិការៈក្នុងការគ្រប់គ្រងហើយការខូចខាតបានកើតឡើងដោយជនរងគ្រោះ ឬ តតិយជន ម្ចាស់វត្ថុ ឬ អ្នកគ្រប់គ្រងវត្ថុនោះអាចផុតពីការទទួលខុសត្រូវបាន។[39]

-**ការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដី** គឺក្នុងករណីដែលមានការសាងសង់សំណង់ជាប់នឹងដី ឬ ការគ្រប់គ្រងសំណង់នោះមានវិការៈហើយបណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃ។ អ្នកគ្រប់គ្រងសំណង់ និងកម្មសិទ្ធករនៃសំណង់នោះត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតនោះ។ ដោយបន្ទុករបស់កម្មសិទ្ធករនៃសំណង់ដែលជាប់នឹងដី និងអ្នកគ្រប់គ្រងសំណង់នោះត្រូវកំណត់តាមកម្រិតនៃការបង្កឱ្យមានវិការៈនៃការសាងសង់ ឬ គ្រប់គ្រង។[40]

### ៤. អំពើអនីត្យានុកូលរួម

ប្រសិនបើការខូចខាតបានកើតឡើងដោយសារអំពើរបស់បុគ្គលច្រើននាក់រួមគ្នា អ្នកប្រព្រឹត្តអំពើនីមួយៗត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព។ ចំពោះទំហំនៃសំណងនៃការខូចខាតវិញ ប្រសិនបើជាអំពើរួមគ្នាពាក់ព័ន្ធជិតស្និទ ដូចជា ករណីការសមគំនិតគ្នាជាដើមចារីម្នាក់ៗត្រូវទទួលខុសត្រូវដោយសាមគ្គីនូវសំណងនៃការខូចខាតទាំងអស់។ ក៏ប៉ុន្តែក្នុងករណីដែលទំនាក់ទំនងមិនសូវស្និទ្ធទេ អ្នកប្រព្រឹត្តអំពើបំពាន

[38] សេចក្តីកំណត់ចំពោះក្រមមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០, មាត្រា៧៥១

[39] សេចក្តីកំណត់ចំពោះក្រមមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០, មាត្រា៧៥២

[40] មាត្រា ៧៥៣ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

អាចទទួលខុសត្រូវក្នុងការសងការខូចខាតតាមសមាមាត្រនៃភាគដែលខ្លួនបានបង្កនោះ។[41] សូម្បីនៅក្នុងករណីដែលគ្មានទំនាក់ទំនងគ្នាជិតស្និទ្ធ ប៉ុន្តែអ្នកប្រព្រឹត្តអំពើបំពានមិនអាចបញ្ជាក់អំពីភាពនៃអំពើដែលខ្លួនបានបង្កឱ្យមានការខូចខាតនោះទេ ជននោះមិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការសងការខូចខាតទាំងអស់បានឡើយ។

## ៥. បញ្ញត្តិដែលទាក់ទងន័យផ្សេងទៀតស្តីអំពីអំពើអនីត្យានុកូល

ទារកដែលនៅក្នុងគភ៌នាពេលដែលមានអំពើអនីត្យានុកូល បើទារកនេះមានកំណើតនៅក្រោយអាចទាមទារនូវសំណងនៃការខូចខាតដែលបានកើតឡើងពេលដែលខ្លួននៅក្នុងគភ៌ ដោយអំពើអនីត្យានុកូលនោះបានតាមបញ្ញត្តិមាត្រា ៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។ ជាពិសេសជាងនេះទៅទៀត ទារកដែលនៅក្នុងគភ៌អាចទាមទារសំណងការខូចខាតខាងផ្លូវចិត្ត ដោយយោង តាមមាត្រា ៧៦៣ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

**-អាជ្ញាយុកាលនៃការរំលត់គឺ** បានកំណត់ក្នុងមាត្រា ៧៦៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ សិទ្ធិទាមទារនូវសំណងនៃការខូចខាតដោយអំពើអនីត្យានុកូលត្រូវរំលត់ ប្រសិនបើផុតក្នុងអំឡុងពេល ដូចខាងក្រោម៖ (១) អំឡុងពេល ៣ ឆ្នាំ បានកន្លងហួស បន្ទាប់ពីពេលដែល ជនរងគ្រោះបានដឹងថាអាចទាមទារ សំណងការខូចខាតខាងចំពោះអ្នកប្រព្រឹត្តអំពើបំពាន និង (២) អំឡុងពេល ១០ ឆ្នាំ បានកន្លងផុតទៅ បន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្តឡើង បញ្ញត្តិនេះត្រូវបញ្ញត្តិឡើងជាប្រយោជន៍នៃស្ថិរភាពគតិយុត្ត។

[41] មាត្រា ៧៥៤ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

# ជំពូកទី២

# ប្រព័ន្ធគតិយុត្តនៃការលក់ភាគហ៊ុន

# ជំពូកទី២

# របបគតិយុត្តនៃការរលត់កាតព្វកិច្ច

កាតព្វកិច្ច គឺជាចំណងគតិយុត្តដែលមានទំនាក់ទំនងទ្រព្យសម្បត្តិដ៏ស្មុគស្មាញនៅពេលដែលកើតឡើងហើយត្រូវតែមានបទដ្ឋាន ដែលច្បាស់លាស់មួយសម្រាប់គ្រប់គ្រង។ លើសពីនេះទៀត ការរលត់កាតព្វកិច្ច ដោយសារសកម្មភាពភាគីមានន័យថា កត្តាសំខាន់ៗដូចជា៖ (១) ការសង ការទូទាត់ ការលើកលែង នវកម្ម ឬ ព្យាកុលភាព (២) អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចដោយគ្មានកំហុសរបស់កូនបំណុល (៣) ការបំពេញលក្ខខណ្ឌនៃការរំលាយកិច្ចសន្យា ឬ ការរំលាយកិច្ចសន្យា (៤) ផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល និង (៥) ការអនុវត្តសិទ្ធិលុបចោល។

## ផ្នែកទី១៖ ការសង ការទូទាត់ ការលើកលែង នវកម្ម ឬ ព្យាកុលភាព

### ១. ការសង

ការសង គឺជាវិធីសាមញ្ញមួយសម្រាប់ការបញ្ចប់នូវកាតព្វកិច្ចរវាងម្ចាស់បំណុល និងកូនបំណុលហើយវាបានស្តែងអំពីឆន្ទៈនៃការព្រមព្រៀងគ្នាដោយត្រឹមត្រូវ ច្បាស់លាស់ និងពិតប្រាកដដែលកើតចេញពីឆន្ទៈភាគី។ ម្យ៉ាងទៀតវាជាមានអានុភាព ប្រសិនបើការសងកើតឡើងរវាងភាគីដែលពាក់ព័ន្ធនៅកិច្ចសន្យានោះ។ ជាទូទៅ អ្នកសង គឺកូនបំណុល។ ប្រសិនបើអ្នកសងមិនមែនជាម្ចាស់កម្មសិទ្ធិ ឬ មិនមែនជាសកម្មភាពចាត់ចែងចំពោះវត្ថុដែលជាកម្មសិទ្ធិនៃការសងរបស់អ្នកសងនោះមិនមានសុពលភាពឡើយ។[42] ការសងអាចធ្វើឡើងដោយតតិយជនបានដោយនិយមន័យតតិយជនគឺ អ្នកដែលគ្មានផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់ចំពោះកិច្ចសន្យានៃភាគីដែលពាក់ព័ន្ធដូចជា មិត្តភក្តិ បងប្អូន ឬ ឪពុកម្តាយ ជាដើម។[43] ឧទាហរណ៍៖ អ្នកដែលចេញមុខធានាមិនមែនជាតតិយជនទេ ព្រោះអ្នកធានាទីនេះមានផលប្រយោជន៍ ត្រឹមត្រូវតាមច្បាប់ចំពោះការសងដោយសារអ្នកធានានោះត្រូវជៀសពីការទទួលត្រូវក្នុងការធានា។

ចំពោះអានុភាពនៃការសងដោយក្នុងករណីដែលកូនបំណុល និងតតិយជនបានសងដោយត្រឹមត្រូវនាំឱ្យកាតព្វកិច្ចដើមត្រូវរលត់ ហើយតតិយជនអាចទាមទារការសងពីកូនបំណុលដើម (សេចក្តីដោយចម្រើនឥតហេតុ) និងតតិយជនស្នងម្ចាស់ បំណុលដោយឧបទោសកម្មចំពោះសិទ្ធិលើបំណុល និងសិទ្ធិផ្សេងទៀតដែលម្ចាស់បំណុលនោះធ្លាប់មាន។

---

[42] មាត្រា ៤៣៥ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[43] មាត្រា ៤៣៤ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

ហើយករណីលើកលែង ដោយមានករណីខ្លះដែលគោលបំណងនៃកាតព្វកិច្ចមិនអាចសម្រេចដោយសារការសងរបស់តតិយជនបានទេ។ តតិយជននោះមិនអាចសងបានឡើយ លើកលែងតែមានការយល់ព្រមពីម្ចាស់បំណុល។ ម្យ៉ាងទៀត ម្ចាស់បំណុល និងកូនបំណុលបានព្រមគេងគ្នាមិនទទួលស្គាល់ការសងដោយតតិយជន។[44] ឧទាហរណ៍៖ នៃកាតព្វកិច្ចដែលមានគោលបំណងល្អ វាមិនអាចសម្រេចបានដោយសារការសាងសង់របស់តតិយជនមានកាតព្វកិច្ចគូររូបភាពកាតព្វកិច្ចសម្តែងលើឆាក កាតព្វកិច្ចមិនបង្កសំឡេងឡូឡាជាដើម។ ដូចដែលបានឃើញ កាតព្វកិច្ចជាច្រើនដែលមានខ្លឹមសារឱ្យធ្វើសកម្មភាពណាមួយ ឬ មិនឱ្យធ្វើសកម្មភាពណាមួយតាមខ្លឹមសាររបស់វា កាតព្វកិច្ចដែលមិនអនុញ្ញាតឱ្យតតិយជនសងព្រោះចរិតលក្ខណៈរបស់កូនបំណុល គឺមានសារៈសំខាន់ណាស់។

### ១.១ អ្នកដែលទទួលការសង ពេលដែលការសងត្រូវបានធ្វើឡើង និងទីកន្លែងត្រូវសង

បើកូនបំណុលបានសងដល់អ្នកគ្មានសិទ្ធិទទួលការសងកូនបំណុល នោះត្រូវសងម្ចាស់បំណុលជាថ្មីម្តងទៀតតាមការទាមទារពីម្ចាស់បំណុលនោះ។ ប៉ុន្តែក្នុងករណីដែលអ្នកទទួលការផ្សងមិនមែនជាអ្នកសិទ្ធិទទួលទេតែមើលទៅហាក់ដូចជា មានសិទ្ធិទទួលការសងវាគឺជា បញ្ហាសម្រាប់កូនបំណុលព្រោះគោលបំណងអាចបាត់បង់នូវអ្វីដែលត្រូវធ្វើ ពោលប្រសិនបើគាត់សងហើយអ្នកទទួលមិនមានសិទ្ធិទទួលទេ កូនបំណុលត្រូវសងម្តងទៀត។ ហើយការសងទៅអ្នកដែលគ្មានសិទ្ធិទទួលការសង មានសុពលភាពដោយករណីលើកលែង ក្នុងករណីដែលកូនបំណុលជាជនសុចរិត និងគ្មានកំហុស។ ហើយក្នុងករណីដែលការសងដែលបានធ្វើចំពោះឧបភាគីនៃសិទ្ធិលើបំណុលត្រូវបានចាត់ទុកថា សុពលភាពម្ចាស់សិទ្ធិពិតប្រាកដដោយមិនអាចទាមទារអោយកូនបំណុលសងម្តងទៀតបានទេ ប៉ុន្តែអាចទាមទារឲ្យអ្នកទទួលការសងប្រគល់វត្ថុមកវិញ។[45]

ជាទូទៅ ចំពោះពេលដែលការសងត្រូវបានធ្វើឡើងគឺ កូនបំណុលត្រូវបានបង្ខំឱ្យសងរហូតដល់កាលបរិច្ឆេទនៃការសង។ ហើយត្រូវទទួលខុសត្រូវចំពោះសំណងការខូចខាត ក្នុងករណីដែលកូនបំណុលបានអនុវត្តយឺតយ៉ាវ។ ចំពោះការយឺតយ៉ាវក្នុងការអនុវត្ត គឺកូនបំណុលត្រូវបានចាត់ទុកថា មានការយឺតយ៉ាវក្នុងការអនុវត្តក្នុងករណីដែលខ្លួន មិនបានអនុវត្តកាតព្វកិច្ច។ ការយឺតយ៉ាវក្នុងការអនុវត្តនឹងកើតឡើង ប្រសិនបើកំណត់ពេលវេលាត្រូវអនុវត្តដែល ជាពេលវេលាដែលកូនបំណុលត្រូវដល់តាវកាលិកកន្លងហួស។ លើសពីនេះកូនបំណុលត្រូវសងនៅក្នុងម៉ោងធ្វើការធម្មតា។[46] ដូច្នេះវាអាចជាការយឺតយ៉ាវ ប្រសិនបើកូនបំណុលសង

---

[44] មាត្រា ៤៣៨ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[45] មាត្រា ៤៣៩ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[46] មាត្រា ៤៤៤ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

បំណុលចំពោះធនាគារនៅពេលពាក់កណ្តាលអាជ្ញាតនៃកាលបរិច្ឆេទនៃការសង។ ការកំណត់ពេលវេលាត្រូវបានសន្មតថា បានជាប្រយោជន៍របស់កូនបំណុល។ ហេតុដូច្នេះ កូនបំណុលអាចបោះបង់ការកំណត់ពេលវេលានោះចោលដោយឯកតោភាគីបាន។[47] ហើយកូនបំណុលអាចសងនៅមុនកាលបរិច្ឆេទបាន។

ចំណែកឯទីកន្លែងត្រូវសងគឺប្រសិនបើគ្មានការព្រមព្រៀងផ្សេងអំពីទីកន្លែងអ្នកត្រូវសងទេ ការប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ត្រូវបានធ្វើឡើងនៅទីកន្លែង ដែលវត្ថុនោះបានស្ថិតនៅនាពេលសិទ្ធិលើបំណុលកើតឡើង។ ចំពោះកាតព្វកិច្ច ក្រៅពីនេះការសងត្រូវបានធ្វើឡើងនៅលំនៅឋានបច្ចុប្បន្នរបស់ម្ចាស់បំណុល។ ហើយជាការពិតណាស់ ការព្រមព្រៀងត្រូវបានយកមកអនុវត្តករណីប្រសិនបើមាន។

### ១.២ អ្វីដែលកូនបំណុលត្រូវធ្វើដែលជាការសង

ការសងត្រូវធ្វើឡើងតាមខ្លឹមសារនៃកាតព្វកិច្ច និងតាមគោលការណ៍នៃភាពស្មោះត្រង់ ហើយសុចរិត។ ការសងត្រូវសងគ្រប់ចំនួន ហើយម្ចាស់បំណុលមិនត្រូវបានបង្ខំឲ្យទទួលបានការសងមួយភាគនោះទេ។ ជាទូទៅសោហ៊ុយនៃការសងជាបន្ទុករបស់កូនបំណុល។ ម្យ៉ាងទៀត កូនបំណុលអាចទាមទារឱ្យចេញលិខិតបញ្ជាក់នូវការទទួលការសងបាន និងទាមទារឱ្យប្រគល់លិខិតបញ្ជាក់សិទ្ធិនៅបំណុលបាន។[48] ចំពោះការសងដោយវត្ថុជំនួស គឺជាការសងទៅធ្វើឡើងដោយខ្លឹមសារកាត់នៃកាតព្វកិច្ច។ ឧទាហរណ៍៖ លោក ក បានឲ្យអចលនវត្ថុគឺមិនមែនជាការសងចំនួន ៥០០០ ដុល្លារ ជាប្រាក់នោះទេ។ ទោះបីជាវត្ថុនោះមានតម្លៃច្រើន ៥០០០ ដុល្លារក៏ដោយ។ ដើម្បីឱ្យកូនបំណុលសងដោយវត្ថុជំនួសមានសុពលភាពនោះកូនបំណុលត្រូវធ្វើការព្រមព្រៀង ឬ ការទទួលការយល់ព្រមពីម្ចាស់បំណុល។

### ១.៣ សំណើផ្តល់ការសង និងតម្កល់

សំណើផ្តល់ការសង និងតម្កល់៖សំណើផ្តល់ការសង គឺជាស្ថានភាពដែលកូនបំណុលបានរៀបចំសព្វគ្រប់នូវតាវកាលិកសម្រាប់សង និងទាមទារឱ្យម្ចាស់ទទួលការសងដោយត្រូវស្នើតាវកាលិកជាក់ស្តែងតាមខ្លឹមសារនៃកាតព្វកិច្ច។ ប្រសិនបើកូនដែលបានធ្វើសំណើផ្តល់ការសង ប៉ុន្តែម្ចាស់បំណុលមិនអាចធ្វើសកម្មភាពចាំបាច់ដើម្បីទទួលការសង កូនបំណុលមិនទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ។ ហើយប្រសិនបើកាតព្វកិច្ចទាំងនោះជាប្រាក់ និងតម្រូវឱ្យបង់ការប្រាក់ កូនបំណុលមិនចាំបាច់បង់ការប្រាក់សម្រាប់ពេលក្រោយពេលនោះទៀតឡើយ។ ករណីដែលម្ចាស់បំណុលបដិសេធចំពោះសំណើផ្តល់ការសងកូនបំណុលគ្រាន់តែជូនដំណឹងអំពីការបញ្ចប់នូវការរៀបចំសង និងដាស់តឿនឱ្យម្ចាស់បំណុលទទួលការសងនោះតែ

---

[47] មាត្រា ៣៣០ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[48] មាត្រា ៤៤៨ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

ប៉ុណ្ណោះ។[49] ក្នុងករណីដែលម្ចាស់បំណុលបដិសេធ ចំពោះសំណើផ្តល់ការសងរបស់កូនបំណុលនាំឱ្យមាន អានុភាពដូចជា៖ (១) ដោយមានបន្ទុកហានិភ័យនៅក្នុងកិច្ចសន្យា ត្រូវបានផ្ទេរទៅឱ្យម្ចាស់បំណុល (២) សិទ្ធ តវ៉ាឱ្យអនុវត្តព្រមគ្នាដែលម្ចាស់បំណុលមានត្រូវបាត់បង់ (៣) កូនបំណុលអាចរួចផុតពីកាតព្វកិច្ចដោយការ តម្កល់ (៤) កូនបំណុលមិនទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច។

ករណីម្ចាស់បំណុលបដិសេធចំពោះសំណើកូនបំណុល ដោយមានកំហុសរបស់ម្ចាស់បំណុលនិង បណ្តាលឱ្យមានការខូចខាតចំពោះកូនបំណុល នាំឱ្យកូនបំណុលអាចទាមទារសំណងនៃការខូចខាតពីម្ចាស់ បំណុលបាន និងប្រសិនបើគ្មានការបដិសេធរបស់ម្ចាស់បំណុលចំពោះសំណើផ្តល់ការសង គឺជាការបំពាន ករណីយកិច្ចធ្ងន់ធ្ងរនាំឱ្យកូនបំណុលអាចរំលាយកិច្ចសន្យាបាន។ ការរំលាយកិច្ចសន្យា គឺធ្វើឡើងតែចំពោះ កិច្ចសន្យាអញ្ញមញ្ញតែប៉ុណ្ណោះ ពីព្រោះការរំលាយកិច្ចសន្យា គឺនាំឱ្យភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរួចផុតពី កាតព្វកិច្ចរបស់ខ្លួន ដោយយកការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាងទៀតមកធ្វើជាមូលហេតុ។[50] មួយវិញទៀត កូនបំណុលអាចតម្កល់កម្មវត្ថុនៃកាតព្វកិច្ចបាននៅកន្លែងតម្កល់ ដើម្បីរួចផុតពីកាតព្វកិច្ចបាន ដូចជាទី ១ អ្នក សងបានផ្តល់ការសង ប៉ុន្តែម្ចាស់សំណងបដិសេធមិនទទួល ទី ២ កូនបំណុលមិនដឹងថា នរណាជាម្ចាស់ បំណុលដែលមិនមែនជាកំហុសរបស់ខ្លួន។ ដោយឡែកប្រសិនបើវត្ថុដែលជាកម្មវត្ថុនៃការតម្កល់មិនសមស្រប សម្រាប់ការតម្កល់ ឬ បារម្ភថាបាត់បង់ ឬ ខូចខាត ឬ ការរក្សាទុកវត្ថុនាំឱ្យមានការចំណាយសោហ៊ុយច្រើនហួស ហេតុដោយមានការអនុញ្ញាតពីតុលាការ អ្នកសងអាចលក់វត្ថុដោយដេញថ្លៃហើយតម្កល់ប្រាក់ដែលបានលក់ នោះនៅតុលាការ។

## ២. ការទូទាត់

ការទូទាត់ សំដៅលើការរលត់កាតព្វកិច្ចដែលធ្វើឡើងដោយយោងចំនួនប្រាក់ស្មើគ្នា ករណីដែលបុគ្គល ពីរនាក់ទទួលបន្ទុកនូវកាតព្វកិច្ច ដែលមានគោលបំណងប្រភេទដូចគ្នាទៅវិញទៅមក។ ភាគីម្ខាងអាចរលត់ កាតព្វកិច្ចទៅវិញទៅមកបានដោយយកប្រាក់ស្មើគ្នាដោយបង្ហាញឆន្ទៈឯកតោភាគី ហើយការទូទាត់ក៏អាចធ្វើ បានដែរ ទោះបីជាកាតព្វកិច្ចទាំងពីរនោះមានគោលបំណងផ្សេងគ្នាក៏ដោយ ប៉ុន្តែការទូទាត់នេះមិនអាចធ្វើឱ្យ ខូចប្រយោជន៍តតិយជននោះទេ។[51] ម្យ៉ាងវិញទៀត អ្នកធានាមិនអាចអោយទូទាត់បំណុល ដែលម្ចាស់បំណុល មានលើកូនបំណុលដែលខ្លួនធានានោះទេ។ ហើយកូនបំណុលក៏មិនអាចជំទាស់អោយទូទាត់បំណុល ដែល ម្ចាស់បំណុលមានលើអ្នកធានាខ្លួននោះទេ។ លើសពីនេះទៀត កូនបំណុលសាមគ្គីក៏មិនអាចជំទាស់មិនឱ្យ

[49] មាត្រា ៤១៦ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[50] មាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[51] មាត្រា ៤៦៤ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

ទូទាត់បំណុលដែលម្ចាស់បំណុលមានលើកូនបំណុលរួមបាននោះទេ។

**២.១ លក្ខខណ្ឌនៃការទូទាត់**

យោងតាមមាត្រា ៤៦៤ ដែលបានចែងអំពីអត្ថន័យ និងលក្ខខណ្ឌរួវនៃការទូទាត់ដែលច្បាប់បានកំណត់។ ការទូទាត់ ដែលត្រូវបានធ្វើឡើងគឺមានៈ

**ក.** បុគ្គលពីរនាក់ទទួលបន្ទុកកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកមានន័យថា ទោះជាគ្មានការព្រមព្រៀងគ្នាអំពីការទូទាត់ខាងភាគីទាំងពីរក៏ដោយ ក៏ការទូទាត់អាចធ្វើបានដោយការបង្ហាញឆន្ទៈឯកតោភាគីអំពី "**ការទូទាត់**" របស់ភាគីម្ខាង។

**ខ.** កាតព្វកិច្ចទាំងពីរមានគោលបំណងប្រភេទដូចគ្នា គឺការទូទាត់អាចធ្វើបានចំពោះកាតព្វកិច្ចដែលជាកាតព្វកិច្ចជាប្រាក់ ឬ កាតព្វកិច្ចដែលមានកម្មវត្ថុជំនួសប្រភេទដូចគ្នា (ឧទាហរណ៍៖ ស្រូវ) បើកាតព្វកិច្ចជាប្រាក់គឺត្រូវតែអនុវត្តនូវការទូរទាត់ជាប្រាក់។

**គ.** កាតព្វកិច្ចទាំងពីរ ត្រូវដល់ពេលកំណត់សង ក្នុងករណីនេះ គឺជាការដល់ពេលវេលា ដែលត្រូវកំណត់សងនូវសិទ្ធិលើបំណុល ដែលភាគីម្ខាងបានបង្ហាញឆន្ទៈអំពីការទូទាត់មានចំពោះភាគីម្ខាងទៀត។ ហើយការទូទាត់ដែលរំលត់សិទ្ធិលើបំណុលចំពោះគ្នាទៅវិញទៅមករបស់ភាគីទាំងពីរ ហេតុនេះចំពោះសិទ្ធិលើបំណុលរបស់ភាគីដែលបានធ្វើការទូទាត់ហើយនោះមានអានុភាពនៃសិទ្ធិលើបំណុលដែលត្រូវបានសង។

**ឃ.** ការបង្ហាញឆន្ទៈទូទាត់ពីភាគីម្ខាង គឺមានន័យថា ការទូទាត់ដោយភាគីម្ខាងបានបង្ហាញឆន្ទៈធ្វើការទូទាត់ទៅដល់ភាគីម្ខាងទៀត។[52]

ទោះជាយ៉ាងណាក៏ដោយ គូភាគីក៏អាចធ្វើកិច្ចសន្យាទូទាត់ដែលរលត់កាតព្វកិច្ចទៅវិញទៅមកបាន ទោះបីជាកាតព្វកិច្ចទាំងពីរនោះគ្មានគោលបំណងប្រភេទដូចគ្នាទៅវិញទៅមកក៏ដោយ។ ប៉ុន្តែ មិនត្រូវឱ្យមានការខូចផលប្រយោជន៍របស់តតីយជន ដោយសារការទូទាត់របស់គូភាគីនោះទេ។ តាមធម្មតា សិទ្ធិលើបំណុលចំពោះគ្នាទៅវិញទៅមកនោះ គឺស្ថិតក្នុងស្ថានភាពសមស្របនឹងការទូទាត់ គឺអាចរលត់ដោយកិច្ចសន្យាទូទាត់។ ទោះជាកម្មវត្ថុនៃកាតព្វកិច្ចខុសគ្នាក៏ដោយដូចជា សិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ និងសិទ្ធិលើបំណុលទាមទារឱ្យប្រគល់ស្រូវ ជាដើមក៏ជាការទូទាត់អាចធ្វើបានតាមកិច្ចសន្យាទូទាត់ដែរ។

**២.១.១ មូលហេតុនៃការហាមឃាត់ចំពោះការទូទាត់**

លើសពីនេះ នៅមានមូលហេតុមួយចំនួនសំរាប់កំរិតចំពោះការទូទាត់ដូចជា៖

**ក.** កាតព្វកិច្ច មិនអនុញ្ញាតឱ្យធ្វើការទូរទាត់ដោយហាមមិនឱ្យធ្វើការទូទាត់ ក្នុងករណីមិនសុំអនុញ្ញាត

[52] មាត្រា ៤៦៥ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

ឱ្យធ្វើការទូទាត់ ដោយសារសិទ្ធិលើបំណុលណាមួយ ឬ ទាំងពីរ គឺជាសិទ្ធិលើបំណុល ពិសេសដែលភាគីចាំបាច់ត្រូវទទួលការបង់ប្រាក់ ។

**ខ.** សិទ្ធិលើបំណុលរបស់ភាគីម្ខាងទៀត ភ្ជាប់នឹងសិទ្ធិតវ៉ាគឺ ក្នុងករណីដែលភាគីមួយទៀត មានសិទ្ធិតវ៉ានឹងសិទ្ធិលើបំណុលរបស់ភាគីដែលបង្ហាញឆន្ទៈទូទាត់ ទោះបីជាលក្ខខណ្ឌសំរាប់ទូទាត់ត្រូវបានបំពេញក៏ដោយក៏មិនអាចធ្វើការទូទាត់បានដែរ។[53]

**គ.** កាតព្វកិច្ច កើតឡើងដោយអំពើអនីត្យានុកូលគឺជាការកម្រិតនូវការទូទាត់ ដោយចារីនៃអំពើអនីត្យានុកូល។ ក្នុងករណីដែល X មានសិទ្ធិលើបំណុល ចំពោះ Y ហើយ Y មានសិទ្ធិលើបំណុលចំពោះសំណងការខូចខាតដែលកើតឡើង ដោយសារអំពើអនីត្យានុកូលរបស់ X នោះ X មិនអាចអះអាងអំពីការរលត់កាតព្វកិច្ចចំពោះសំណងការខូចខាត ដែលកើតឡើងដោយសារអំពើអនីត្យានុកូលនោះតាមការអះអាងអំពីការទូទាត់បានឡើយ ។

**ឃ.** មានការសន្យាថាហាមមិនឱ្យធ្វើការទូរទាត់ គឺជាគោលការណ៍គូភាគីមានសិទ្ធិក្នុងការកំណត់នូវលក្ខខណ្ឌសម្រាប់ការអនុវត្តបាន។ ដូចនេះ ចំពោះការទូទាត់ភាគីក៏អាចចែងហាមមិនឱ្យធ្វើការទូទាត់បានដូចគ្នា ប៉ុន្តែមិនមានអានុភាពអះអាងចំពោះតតិយជនដែលសុចរិតបានឡើយ។

**ង.** សិទ្ធិលើបំណុល ត្រូវបានហាមឃាត់មិនឱ្យរឹបអូស គឺជាការហាមមិនឱ្យធ្វើការទូទាត់នូវសិទ្ធិលើបំណុល ដែលហាមមិនឱ្យរឹបអូស។[54]

មូលហេតុមិនឱ្យធ្វើការទូទាត់ដោយសារថា មានភាពចាំបាច់ដល់ការទ្រទ្រង់ជីវភាពរស់នៅ ។

**-ស្តីពីចំណុច ក** ឧទាហរណ៍៖ បើសិនជាអ្នកជិតខាងសន្យាថា ពួកគេទទួលបន្ទុកកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកមិនចាក់ភ្លេងទេ បន្ទាប់ពីម៉ោង ៩ យប់នោះនឹងគ្មានន័យទេសំរាប់ភាគីម្ខាងទៀត ចាក់ភ្លេងបន្ទាប់ពីម៉ោង ៩ យប់ដោយបង្ហាញឆន្ទៈទូទាត់ ។

**-ស្តីពីចំណុច ខ** ឧទាហរណ៍ នៅក្នុងចំណោមឧទាហរណ៍យ៉ាងសាមញ្ញ ជាច្រើននៃសិទ្ធិតវ៉ា។

ករណីសិក្សា១: X និង Y បានសន្យាគ្នាថា X ត្រូវលក់រថយន្តទៅឱ្យ Y ក្នុងតម្លៃ ៥០០០ ដុល្លារ ដោយពុំបានធ្វើការសន្យាពិសេសណាមួយអំពីពេលវេលានៃការសងនោះទេ។ ក្រៅពីនោះ X បានខ្ចីប្រាក់ចំនួន ៥០០០ ដុល្លារ ពី Y ។ តើ X អាចធ្វើការទូរទាត់បានទេ?

សន្និដ្ឋាន: នៅក្នុងករណីនេះ Y មានកាតព្វកិច្ចបង់ប្រាក់ចំនួន ៥០០០ ដុល្លារទៅឱ្យ X ចំណែក X ជំពាក់

[53] មាត្រា ៤៦៨ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[54] មាត្រា ៤៧០ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

បំណុលចំនួន ៥០០០ ដុល្លារ ។ ប៉ុន្តែ វាមិនអាចទៅរួចនោះទេក្នុងការទូទាត់កាតព្វកិច្ចទាំងពីរនេះ ពីព្រោះ Y អាចទាមទារឱ្យប្រគល់រថយន្តដែលជាការតវ៉ាឱ្យអនុវត្តព្រមគ្នា។

**២.១.២ កិច្ចសន្យាទូទាត់**

កិច្ចសន្យាទូទាត់ គឺជាកិច្ចសន្យាដែលរលត់កាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក តាមការព្រមព្រៀងរបស់គូភាគី ទោះបីជាកាតព្វកិច្ចទាំងពីរនោះគ្មានគោលបំណងប្រភេទដូចគ្នាទៅវិញទៅមកក៏ដោយ។ ជាទូទៅ ភាគីតែម្ខាងអាចបង្ហាញឆន្ទៈឯកតោភាគីដើម្បីធ្វើការទូទាត់បាន នៅពេលណាដែលលក្ខខណ្ឌការទូទាត់ដែលច្បាប់បានកំណត់ត្រូវបានបំពេញ។ ប៉ុន្តែ ទោះបីជាលក្ខខណ្ឌនៃការទូទាត់ដែលច្បាប់បានកំណត់មិនត្រូវបានបំពេញក៏គូភាគីនៃកិច្ចសន្យាទូទាត់ អាចព្រមព្រៀងគ្នាធ្វើការរលត់កាតព្វកិច្ចតាមរយៈការទូទាត់បាន ដែលជាឧទាហរណ៍មួយនៃគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។ ប៉ុន្តែ សិទ្ធិរបស់តតិយជនដែលមិនបានដឹងអំពីការបង្កើតកិច្ចសន្យាជាក់លាក់បែបនោះ មិនត្រូវបំពានតាមរយៈការបង្កើតកិច្ចសន្យាទូទាត់បែបនេះទេ។

**២.១.៣ អានុភាព**

ករណីដែលលក្ខខណ្ឌការទូទាត់ត្រូវបានបំពេញ ហើយនៅពេលដែលឆន្ទៈនៃការទូទាត់ត្រូវបានបង្ហាញ នោះអានុភាព ២ នឹងកើតមានឡើងគឺៈ កាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកត្រូវរលត់ត្រឹមក៏រិតដែលចំនួននីមួយៗមានតម្លៃស្មើគ្នា និងអានុភាពដែលរលត់កាតព្វកិច្ចដោយការទូទាត់នោះត្រូវកើតឡើងដោយមានប្រតិសកម្មតាំងពីពេល ដែលកាតព្វកិច្ចទាំងពីរនោះសមស្របនឹងការទូទាត់មានន័យថា កាតព្វកិច្ចទាំងពីរនោះត្រឡប់ទៅជារលត់នៅកាលបរិច្ឆេទដែលកាតព្វកិច្ចទាំងពីរដល់កំណត់សង។

**២.១.៤ កាតព្វកិច្ចតាមដីកាសម្រេចបង្គាប់ឱ្យរឹបអូស**

តាមមាត្រា ៤៧១ នៃក្រមរដ្ឋប្បវេណី បានអនុញ្ញាតឱ្យគូភាគីធ្វើការទូទាត់សិទ្ធិលើបំណុលដែលមានចំពោះគ្នាទៅវិញទៅមក ប៉ុន្តែក្នុងករណីមួយចំនួន ភាគីមិនត្រូវបានអនុញ្ញាតឱ្យធ្វើការទូទាត់នោះទេ។

ជាដំបូង កូនបំណុលត្រូវធ្វើលទ្ធកម្មនូវសិទ្ធិលើបំណុលរបស់ខ្លួន ចំពោះម្ចាស់បំណុលនៃការរឹបអូសសិទ្ធិលើបំណុលចំពោះសិទ្ធិលើបំណុល ចំពោះកូនបំណុលជាមុនសិន ដើម្បីធ្វើការទូទាត់សិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ជាមួយនឹងសិទ្ធិលើបំណុលរបស់កូនបំណុល ។ ជាទូទៅកាលបរិច្ឆេទនៃការកំណត់សងនៃសិទ្ធិលើបំណុលរបស់កូនបំណុល ត្រូវមកដល់មុនកាលបរិច្ឆេទនៃការកំណត់សងនៃសិទ្ធិលើបំណុលរបស់កូនបំណុល។ នេះគឺ ដោយសារកូនបំណុលមិនត្រូវរំពឹងធ្វើការទូទាត់កាតព្វកិច្ច ដែលមានចំពោះគ្នាទៅវិញទៅមកដោយមិនបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោយកាលបរិច្ឆេទនៃការកំណត់សង នៅក្នុងករណីដែលកាលបរិច្ឆេទនៃការកំណត់សងនៃសិទ្ធិលើបំណុល ដែលត្រូវបានរឹបអូសបានមកដល់មុន។[55] ប៉ុន្តែ ការសន្យាពិសេសអាចធ្វើកូន

[55] មាត្រា ៤៧១ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

បំណុលទូទាត់ដោយមិនចាំបាច់គិតពីកាលបរិច្ឆេទនៃការកំណត់សងសិទ្ធិលើបំណុលទាំងពីរ។

## ៣. ការលើកលែង និងព្យាកុលភាព

### ៣.១ ការលើកលែង

ការលើកលែង គឺជាមូលហេតុមួយដែលនាំឱ្យកាតព្វកិច្ចរលត់ និងជាសកម្មភាពឯកតោភាគី។ ដូច្នេះ ម្ចាស់បំណុលអាចបង្ហាញឆន្ទៈឯកតោភាគី ដើម្បីលើកលែងឱ្យកូនបំណុលរួចផុតពីកាតព្វកិច្ច ។ ម្ចាស់បំណុលអាចបង្ហាញឆន្ទៈលើកលែងកាតព្វកិច្ចទាំងអស់ ដើម្បីឱ្យកូនបំណុលរួចផុតពីកាតព្វកិច្ចបាន ហើយក៏អាចបង្ហាញឆន្ទៈលើកលែងតែមួយផ្នែកក៏បាន។[56]

ឧទាហរណ៍៖ ផ្អែកលើកិច្ចសន្យាខ្ចីបរិភោគដែលកូនបំណុលបានខ្ចីប្រាក់ពីម្ចាស់បំណុលចំនួន ៦០០០ ដុល្លារ។ ក្នុងករណីនេះ ម្ចាស់បំណុលអាចលើកលែងកាតព្វកិច្ច ៣០០ ដុល្លា ពីកាតព្វកិច្ច ៦០០០ ដុល្លារបាន ឬ ម្ចាស់បំណុលអាចបង្ហាញឆន្ទៈលើកលែងកាតព្វកិច្ចត្រូវបង់ការប្រាក់ជាដើម ។

ម្ចាស់បំណុល អាចបង្ហាញឆន្ទៈលើកលែងអោយកូនបំណុលរួចផុតពីកាតព្វកិច្ចបាន លុះត្រាតែម្ចាស់បំណុលមានសិទ្ធិចាត់ចែងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន។ ម្ចាស់បំណុលដែលមានសិទ្ធិចាត់ចែងបែបនេះភាគច្រើន គឺជាម្ចាស់បំណុលធម្មតា។ ក៏ប៉ុន្តែ ជួនកាលម្ចាស់បំណុលប្រភេទនេះ មិនអាចធ្វើការចាត់ចែងបានទេ ដោយសារតែគាត់បាត់បង់នូវសិទ្ធិចាត់ចែងនេះ ក្នុងករណីដែលសិទ្ធិលើបំណុលរបស់គាត់ត្រូវបានរឹបអូសជាដើម ។ ដូច្នេះ ម្ចាស់បំណុលនេះមិនអាចធ្វើការលើកលែងបានទេ។[57]

### ៣.២ ព្យាកុលភាព

ក្នុងករណីដែល សិទ្ធិលើបំណុល ឬ កាតព្វកិច្ចធ្លាក់ទៅលើបុគ្គលតែម្នាក់គ្មានន័យអ្វីដែលត្រូវអនុញ្ញាតឱ្យសិទ្ធិលើបំណុល ឬ កាតព្វកិច្ចរបស់បុគ្គលតែម្នាក់បន្តឱ្យមានអត្ថិភាពឡើយ ។ ហេតុដូច្នេះ វាជារឿងសមហេតុសមផលក្នុងការពិចារណាថា កាតព្វកិច្ចត្រូវរលត់ដូចក្នុងករណីដែលកាតព្វកិច្ចនេះត្រូវបានសង។ នេះ គឺជាមូលហេតុដែលយកព្យាកុលភាពមកធ្វើជាមូលហេតុនៃការរលត់កាតព្វកិច្ច ។

សិទ្ធិលើបំណុលជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន សិទ្ធិនោះមិនត្រូវរលត់ដោយព្យាកុលភាពឡើយ។ ឧទាហរណ៍៖ នៃករណីលើកលែងនេះ គឺករណីដែលកាតព្វកិច្ច ត្រូវរលត់ជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំរបស់តតិយជន ឬ កម្មវត្ថុនៃការរឹបអូសរបស់តតិយជន ឬ កម្មវត្ថុនៃសិទ្ធិផ្សេងទៀតរបស់តតិយជន ប្រសិនបើកាតព្វកិច្ចត្រូវរលត់ដោយព្យាកុលភាព វានឹងប៉ះពាល់ដល់ផលប្រយោជន៍របស់តតិយជននោះ ហេតុដូច្នេះ ចាំបាច់ត្រូវបញ្ញត្តថា សិទ្ធិលើបំណុល ឬ កាតព្វកិច្ច មិនត្រូវរលត់ក្នុងករណីបែបនេះនោះឡើយ។

---

[56] មាត្រា ៤៧៤ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[57] មាត្រា ៤៧៥ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

## ផ្នែកទី២៖ អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច ដោយគ្មានកំហុសរបស់កូនបំណុល

ការរលត់កាតព្វកិច្ចដែលកើតឡើងដោយអលទ្ធភាព ដែលជាការទទួលបន្ទុកហានិភ័យ។ ពោលបើការអនុវត្តកាតព្វកិច្ចក្លាយជាអលទ្ធភាព ហើយកូនបំណុលគ្មានកំហុសចំពោះអលទ្ធភាព នោះកាតព្វកិច្ចត្រូវរលត់ ហើយម្ចាស់បំណុលមិនអាចទាមទារតាវកាលិកបានទេ។[58] ប៉ុន្តែក្នុងករណីដែល អលទ្ធភាពមានកំហុសរបស់កូនបំណុលវិញនោះ កាតព្វកិច្ចនឹងមិនត្រូវបានរលត់ទេ។

ចំពោះកិច្ចសន្យាទ្វេភាគី ភាគីទាំងសងខាងមានកាតព្វកិច្ច និងសិទ្ធិទាមទារចំពោះគ្នាទៅវិញទៅមក។ ឧទាហរណ៍៖ "A" ជាអ្នកលក់ មានកាតព្វកិច្ចផ្ទេរកម្មវត្ថុ និងសិទ្ធិទាមទារឲ្យបង់ប្រាក់។ ចំណែកឯ "B" វិញជាអ្នកទិញ មានកាតព្វកិច្ចបង់ប្រាក់ និងសិទ្ធិទាមទារឲ្យផ្ទេរកម្មវត្ថុ។ យើងឃើញថា ក្នុងទំនាក់ទំនងនេះកាតព្វកិច្ចផ្ទេរ និងសិទ្ធិទាមទារឲ្យផ្ទេរ ហើយកាតព្វកិច្ចបង់ប្រាក់ និងសិទ្ធិទាមទារឲ្យបង់ប្រាក់ គឺដូចជាមុខពីរនៅលើកាក់តែមួយ។ ដូចនេះ ប្រសិនបើកាតព្វកិច្ចផ្ទេរត្រូវរលត់នោះ សិទ្ធិទាមទារក៏ត្រូវរលត់ដែរ។ ក្នុងករណីដែលកូនបំណុលគ្មានកំហុសចំពោះអលទ្ធភាពក្នុងការអនុវត្ត កាតព្វកិច្ចនោះកាតព្វកិច្ចត្រូវរលត់ ហើយម្ចាស់បំណុលមិនអាចទាមទារតាវកាលិកបានទេ។ កូនបំណុលនៅពេលនេះ សំដៅលើបុគ្គលដែលមានកាតព្វកិច្ចផ្ទេរកម្មវត្ថុ និងម្ចាស់បំណុល សំដៅលើ បុគ្គលដែលមានសិទ្ធិទាមទារឲ្យផ្ទេរកម្មវត្ថុ។ ដូច្នេះប្រសិនបើកម្មវត្ថុនៃកិច្ចសន្យាលក់ទិញត្រូវបានខូចខាត ដោយគ្មានកំហុសរបស់ "A" នោះកាតព្វកិច្ចផ្ទេរត្រូវបានរលត់ ហើយ "B" មិនអាចទាមទារការផ្ទេរកម្មវត្ថុបានទេ។ បន្ទាប់មក តើ "A" អាចទាមទារ "B" ឲ្យបង់ប្រាក់បានដែរឬទេ នៅក្នុងករណីខាងលើ? បញ្ហានៃបន្ទុកហានិភ័យ គឺសំដៅលើបុគ្គលណាជាអ្នកទទួលបន្ទុកហានិភ័យ ប្រសិនបើកាតព្វកិច្ចផ្ទេរក្លាយជាអលទ្ធភាព? តើជាកូនបំណុល ឬ ជាម្ចាស់បំណុលដែលត្រូវទទួល? ហើយចំពោះករណីដែលកម្មវត្ថុ ដែលត្រូវធ្វើការផ្ទេរត្រូវបានខូចខាត ដោយគ្មានកំហុសរបស់ភាគីទាំងសងខាង នោះកាតព្វកិច្ចតបត្រូវរលត់ ឬ អត់?

-**គោលគំនិតដែលតាវកាលិកតបត្រូវរលត់** គឺក្នុងករណីខាងលើ ប្រសិនបើកាតព្វកិច្ចបង់ប្រាក់ របស់ "B" ត្រូវបានរលត់នោះ "B" មិនត្រូវបង់ប្រាក់ថ្លៃទិញទៀតទេ។ បានន័យថា "A" ជាអ្នកបាត់បង់ ផលប្រយោជន៍ នោះ "A" ត្រូវទទួលបន្ទុកហានិភ័យ។

-**គោលគំនិតដែលតាវកាលិកតបមិនត្រូវរលត់** គឺប្រសិនបើតាវកាលិកតបមិនត្រូវបានរលត់ "B" នៅតែមានកាតព្វកិច្ចបង់ប្រាក់ ទោះបីជាកម្មវត្ថុនៃកិច្ចសន្យាត្រូវបានធ្វើឲ្យខូចខាត និងអលទ្ធភាពក្នុងការផ្ទេរ។ បានន័យថា ម្ចាស់បំណុលត្រូវទទួលបន្ទុកហានិភ័យ។

[58] មាត្រា ៤១៥ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

គោលគំនិតទាំងពីរខាងលើអាចអនុវត្តបាន វាអាស្រ័យទៅលើប្រភេទនៃកម្មវត្ថុ។

ក្នុងកិច្ចសន្យាអញ្ញមញ្ញ ឬ កិច្ចសន្យាផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់ នៅពេលដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬ បាត់បង់ដោយគ្មានកំហុសរបស់ភាគីទាំងសងខាងទេ នោះកូនបំណុលត្រូវទទួលបន្ទុកហានិភ័យ។ ជាងនេះទៅទៀត ចំពោះកិច្ចសន្យាអញ្ញមញ្ញ ដែលមានគោលបំណងផ្ទេរកម្មសិទ្ធិលើវត្ថុដែលមិនបានកំណត់ជាក់លាក់ ក្នុងករណីវត្ថុដែលត្រូវផ្តល់មិនទាន់បានកំណត់ ទោះបីជាវត្ថុដែលខ្លួនបានរៀបចំដើម្បីអនុវត្តបាត់បង់ដោយគ្មានកំហុសរបស់ខ្លួនក៏ដោយ ក៏កាតព្វកិច្ចនោះមិនត្រូវបានរលត់ដែរ។ បានន័យថានៅក្នុងករណីនេះកូនបំណុលត្រូវទទួលបន្ទុកហានិភ័យ។[59]

លើកលែងតែមានការកំណត់ផ្សេងនៅក្នុងកិច្ចសន្យា ហានិភ័យដោយសារការបាត់បង់ ឬ ខូចខាតវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ត្រូវផ្ទេរទៅឲ្យម្ចាស់បំណុលនៅពេលណាមួយក្នុងចំណោមពេលដែលបានកំណត់គឺៈ (១) ពេលដែលប្រគល់វត្ថុដែលជាកម្មវត្ថុទៅម្ចាស់បំណុល ឬពេលដែលចុះបញ្ជីផ្ទេរអចលនវត្ថុ ឬ ពេលផ្សេងទៀតដែលយល់ឃើញថា ការគ្រប់គ្រងជាក់ស្តែងលើវត្ថុជាកម្មវត្ថុត្រូវបានផ្ទេរទៅម្ចាស់បំណុល (២) ពេលដែលកូនបំណុលបានស្នើផ្តល់ការអនុវត្តកាតព្វកិច្ចត្រឹមត្រូវ (៣) ពេលដែលម្ចាស់បំណុលប្រកែកមិនព្រមទទួលអនុវត្តរបស់កូនបំណុល ដោយគ្មានមូលហេតុត្រឹមត្រូវ។[60]

ដោយឡែក បើម្ចាស់បំណុលត្រូវទទួលបន្ទុកហានិភ័យ គឺនៅពេលដែលអលទ្ធភាពក្នុងការអនុវត្តដោយកំហុសរបស់ម្ចាស់បំណុល ហើយកូនបំណុលមិនត្រូវបាត់បង់នូវតាវកាលិកពីម្ចាស់បំណុលទេ។ ប៉ុន្តែប្រសិនបើកូនបំណុលបានទទួលផលប្រយោជន៍ដោយការរួចផុតពីកាតព្វកិច្ចរបស់ខ្លួន កូនបំណុលត្រូវប្រគល់ផលប្រយោជន៍នេះទៅម្ចាស់បំណុលវិញ។

## ផ្នែកទី៣ៈ ការបំពេញលក្ខខណ្ឌនៃការរំលាយកិច្ចសន្យា ឬ ការរំលាយកិច្ចសន្យា

កាតព្វកិច្ចត្រូវរលត់ដោយកូនបំណុលបានសងបំណុលទៅឲ្យម្ចាស់បំណុល ឬ តតិយជនបានសងជំនួសកូនបំណុល ឬការសម្តែងឆន្ទៈលើកលែងនូវបំណុលដោយម្ចាស់បំណុលមាន ការអាណិតអាសូរ ឬ ដោយសកម្មភាពណាមួយផ្សេងទៀត។ ប៉ុន្តែគូភាគីក៏អាចរលត់កាតព្វកិច្ចផងដែរ ដោយសារភាគីទាំងសងខាង ឬ តែម្ខាងមានកំហុសនៅក្នុងកិច្ចសន្យាដែលច្បាប់បានកំណត់។ ក្នុងនោះការរលត់កាតព្វកិច្ចតាមច្បាប់កំណត់រួមមានៈ ការរំលាយកិច្ចសន្យា ការផុតអាជ្ញាយុកាល និងការអនុវត្តសិទ្ធិលុបចោល។

### ១. ការរំលាយកិច្ចសន្យា

កិច្ចសន្យាត្រូវបានបង្កើតឡើងដោយមានគូភាគី គឺម្ចាស់បំណុល និងកូនបំណុលដែលក្នុងនោះការរលត់

[59] មាត្រា ៤១៦ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[60] សេចក្តីកំណត់ចំពោះក្រមមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០, មាត្រា៤១៦

កាតព្វកិច្ចត្រូវបានកើតឡើងដោយកូនបំណុលនៃកិច្ចសន្យាមិនអនុវត្តកាតព្វកិច្ច ដែលកើតឡើងពីកិច្ចសន្យានោះ។ តាមរយៈកិច្ចសន្យាអញ្ញមញ្ញភាគីម្ខាងនៃកិច្ចសន្យាអាចរំលាយកិច្ចសន្យានោះបានភ្លាមៗ ក្នុងករណីដែលភាគីម្ខាងទៀតបំពានយ៉ាងធ្ងន់ធ្ងរ។[61] ទាក់ទងទៅនឹងការបំពានធ្ងន់ធ្ងរ សំដៅលើការមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាដោយការបំពាន អំពីភាគីម្ខាងនៃកិច្ចសន្យា។ ក្នុងន័យនេះផងដែរ ប្រសិនបើការបំពាននោះមានលក្ខណៈស្រាលមិនធ្ងន់ធ្ងរ ឬមិនបានអនុវត្តកាតព្វកិច្ចបន្តិចបន្តួចនោះ ភាគីម្ខាងទៀតមិនអាចធ្វើការរំលាយកិច្ចសន្យាបាននោះទេ។ វាក៏មិនមានលក្ខណៈដាច់ខាតនោះទេ ភាគីម្ខាងដែលមិនបានអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួន ភាគីម្ខាងទៀតអាចទាមទារអោយភាគីម្ខាងដែលជាប់កាតព្វកិច្ចនោះអនុវត្តកាតព្វកិច្ចនោះ ម្តងទៀតបាន ដោយផ្តល់អោយនូវពេលវេលាដែលសមរម្យណាមួយ ប៉ុន្តែបើភាគីម្ខាងទៀតនៅតែមិនអនុវត្តកាតព្វកិច្ចទៀតនោះ ភាគីម្ខាងទៀតអាចទាមទារឲ្យរំលាយកិច្ចសន្យាបាន។ ភាគីម្ខាងអាច ធ្វើការរំលត់កាតព្វកិច្ចដោយតាមរយៈការរំលាយកិច្ចសន្យា ដោយយោងតាមលក្ខខណ្ឌមួយចំនួន ហើយវានិងបង្កើតអានុភាពផងដែរ។

### ១.១. លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា

លក្ខខណ្ឌដែលអាចធ្វើការរំលាយកិច្ចសន្យា ដោយមូលហេតុនៃការបំពានធ្ងន់ធ្ងរគឺ[62]៖

-ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀត ដែលមិនបានអនុវត្តកាតព្វកិច្ចតាមការកំណត់ដោយ អំឡុងពេលសមរម្យ ដើម្បីធ្វើការអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេល នោះ។ ក្នុងន័យនេះ ម្ចាស់បំណុលបានធ្វើការដាស់តឿនភាគីដែលមិនអនុវត្តកាតព្វកិច្ច តាមកាលកំណត់ ហើយបានអោយភាគីដែលមិនអនុវត្តកាតព្វកិច្ចអនុវត្តម្តងទៀតក្នុងរយៈពេលមួយសមរម្យ ប៉ុន្តែកូនបំណុលនៅតែមិនអនុវត្តតាមការកំណត់របស់ខ្លួនទៀត នោះម្ចាស់បំណុលអាចធ្វើការរំលាយកិច្ចសន្យាបានភ្លាម។

-ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមការកំណត់នោះ។ បានន័យថា ភាគីម្ខាងមិនបានអនុវត្តទៅតាមកាតព្វកិច្ចដែលខ្លួនត្រូវអនុវត្ត. ដែលភាគីដែលជាម្ចាស់បំណុលមាន បំណងធ្វើក្នុងអំឡុងពេលកំណត់មួយ ដែលក្នុងនោះប្រសិនបើផុតអំឡុងពេលនោះ កម្មវត្ថុនៃកិច្ចសន្យានឹងបាត់បង់នូវប្រយោជន៍ ឬ ខុសពីគោលបំណងរបស់ម្ចាស់បំណុល។

-ភាគីមិនអាចអនុវត្តករណីកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួនបានទេ។ បានន័យថា ភាគីម្ខាង ដែលជាកូនបំណុលមិនអាចអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនទៅតាមគោលបំណង នៃកម្មវត្ថុរបស់កិច្ចសន្យានាំឲ្យម្ចាស់បំណុលអាចធ្វើការរំលាយកិច្ចសន្យាបាន។ ឧទាហរណ៍៖ លោក "ក" និងលោក "ខ" បង្កើតកិច្ចសន្យាទិញលក់

---

[61] មាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[62] មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

ទូរស័ព្ទមួយគ្រឿងដោយកំណត់ពេលវេលា។ ថ្ងៃប្រគល់វត្ថុ ស្រាប់តែទូរសព្ទ័ របស់លោក "ក" ដែលជាអ្នកលក់ នោះបានបាត់ដោយចោរលួច នោះលោក "ក" មិនអាចប្រគល់នូវ កម្មវត្ថុនៃកិច្ចសន្យាឲ្យទៅលោក "ខ" នោះទេ។ ដូចនេះលោក "ខ" អាចធ្វើការរំលាយកិច្ចសន្យាបាន ដោយសម្លឹងហេតុផល លោក "ក" មិនអាចប្រគល់ទូរស័ព្ទ ដែលជាតាវកាលិកចម្បងនៃកិច្ចសន្យាទិញ លក់ទៅអោយខ្លួន។

-ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើអោយបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់បាននឹងអនុវត្តកាតព្វកិច្ចនោះទៅថ្ងៃអនាគតបាន។ បានន័យថា ភាគីទាំងពីរបង្កើតកិច្ចសន្យាដែលមានលក្ខណៈយូរ ឬ បន្តបន្ទាប់ក្នុងការអនុវត្តករណីកិច្ច និងកាតព្វកិច្ច។ ប៉ុន្តែភាគីម្ខាងនៃកិច្ចសន្យាអនុវត្តកាតព្វកិច្ចដោយបំពានភាគីម្ខាងទៀត ម្តងហើយម្តងទៀតរហូតដល់ភាគីម្ខាងនៃកិច្ច សន្យានោះអស់ជំនឿនិងទំនុកចិត្តក្នុងការអនុវត្តកាតព្វកិច្ច។ ឧទាហរណ៍៖ លោក "ក" និង លោក "ខ" បានបង្កើតកិច្ចសន្យាផ្គត់ផ្គង់សំណង់ ដោយលោក "ខ" ជាអ្នកផ្គត់ផ្គង់សម្រាប់លោក "ក" ប្រចាំខែ។ លោក "ខ" បានអនុវត្តកាតព្វកិច្ចរបស់ខ្លួនដំបូងមានលក្ខណៈត្រឹមត្រូវតាមកម្មវត្ថុនៃកិច្ចសន្យាដោយ ប្រគល់គ្រឿងសំណង់ឲ្យទាន់កាលកំណត់។ មិនយូរលោក "ខ" បានផ្គត់ផ្គង់គ្រឿងសំណង់ដោយ យឺតយ៉ាវថ្ងៃកំណត់ម្តងហើយម្តងទៀតនោះនាំអោយលោក "ក" ខាតបង់ប្រាក់កាក់។ ក្នុងករណីនេះ លោក "ក" អាចធ្វើការរំលាយកិច្ចសន្យាដោយមូលហេតុ លោក "ខ" បំពានកិច្ចសន្យាមានលក្ខណៈហួសហេតុ។

ដូចដែលបានរៀបរាប់នូវករណីខាងលើ បើមានករណីណាមួយកើតឡើងក្នុងពេលអនុវត្តកាតព្វកិច្ចនោះចាត់ទុកថាជាការបំពានកាតព្វកិច្ចធ្ងន់ធ្ងរ ហើយដែលបាត់បង់ប្រយោជន៍អាចធ្វើការរំលាយកិច្ចសន្យា។ ភាគីម្ខាងដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យា ដោយបង្ហាញឆន្ទៈរំលាយ ចំពោះភាគីម្ខាងទៀតបាន ហើយម្យ៉ាងទៀតការបង្ហាញឆន្ទៈនេះមិនអាចដកវិញបានទេ ដោយសារការបង្ហាញឆន្ទៈនេះអាចមានភាពមិនច្បាស់លាស់ធ្វើអោយកិច្ចសន្យាដែលបានរំលាយហើយមាន អានុភាពឡើងវិញ។[63] ប៉ុន្តែភាគីដែលបង្ហាញឆន្ទៈក្នុងការរំលាយនេះ អាចដាក់លក្ខខណ្ឌបង្អង់បាន ដោយដាស់តឿនឲ្យភាគីអនុវត្តកាតព្វកិច្ចម្តងទៀត ប្រសិនបើនៅតែមិនអនុវត្តខ្លួននឹងរំលាយកិច្ចសន្យានោះ។

សិទ្ធិក្នុងការរំលាយកិច្ចសន្យានឹងត្រូវរលត់ ក្នុងករណីដែលអ្នកដែលទទួលបានសិទ្ធិរំលាយនោះ បានធ្វើឲ្យខូចខាត ឬបាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬ មិនអាចសងវត្ថុនោះវិញបាន ឬ វត្ថុនោះត្រូវបាគេកែច្នៃឲ្យក្លាយជាវត្ថុអ្វីផ្សេងមួយទៀត។ ប្រសិនបើកម្មវត្ថុនោះមានកំណត់តម្លៃ ភាគីបង្កត្រូវសងមកវិញសមស្របទៅនិងតម្លៃនៃវត្ថុនោះ។ ក្នុងករណីដែលការខូចខាតនៃវត្ថុនោះ ត្រូវបានប្រព្រឹត្តិឡើងដោយភាគីម្ខាង ដែលភាគីនោះ

[63] មាត្រា ៤០៩ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

មានសិទ្ធិក្នុងការរំលាយកិច្ចសន្យាមិនចាំបាច់ធ្វើការសងការខូចខាតនៃវត្ថុនោះទេ។ ម្យ៉ាងវិញទៀតអ្នកដែលមានសិទ្ធិក្នុងការរំលាយកិច្ចសន្យាត្រូវបានបាត់បង់សិទ្ធិ នៅពេលដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬបាត់បង់ដោយទង្វើរបស់ខ្លួន។[64]

អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា ដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ចមានអំឡុងពេលប្រាំឆ្នាំ ក្រោយពីពេលដែលមិនបានអនុវត្តកាតព្វកិច្ច។ ការកំណត់អំឡុងពេលក្នុងការទទួលសិទ្ធិ ដើម្បីរំលាយកិច្ចសន្យា ដោយគិតចាប់ពីថ្ងៃដែលទទួលបានសិទ្ធិនោះ ប្រសិនបើហួសរយៈពេលនេះ សិទ្ធិក្នុងការរំលាយកិច្ចសន្យាក៏ត្រូវបានរលត់ផងដែរ។ ក្នុងការរំលាយកិច្ចសន្យានេះផងដែរ ភាគីទាំងពីរនៃកិច្ចសន្យាអាចធ្វើការព្រមព្រៀងគ្នា ដោយមិនចាំបាច់ក្នុងករណីដែលមានកំហុសរបស់ភាគីដែលអនុវត្តកិច្ចសន្យានោះទេ។

### ១.២. អានុភាពនៃការរំលាយកិច្ចសន្យា

ការរំលត់កាតព្វកិច្ចតាមរយៈការរំលាយកិច្ចសន្យា បណ្តាលអោយកើតមានអានុភាពចំពោះគូភាគី និងចំពោះតតិយជន។

**-អានុភាពចំពោះគូភាគី** គឺការរំលាយកិច្ចសន្យាបណ្តាលអោយរាល់កាតព្វកិច្ចទាំងឡាយរបស់គូភាគីដែលកើតឡើងដោយកិច្ចសន្យានឹងត្រូវរលត់ ហើយធ្វើអោយគូភាគីនៃកិច្ចសន្យារួចផុតពីកិច្ចសន្យានោះបាន។ ប៉ុន្តែក្នុងករណីមានសំណងការខូចខាតដែលកើតមានពីការរំលាយកិច្ចសន្យានោះ អានុភាពនៃការសងការខូចខាតរបស់កូនបំណុលនៅតែមាន។ ភាគីដែលទទួលបានតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬ ទាំងអស់ត្រូវមានករណីកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឱ្យភាគីនោះទទួលបដិទានឡើងវិញដោយសារការរំលាយ។ ចំណែកក្នុងករណីដែលភាគីទាំង សងខាង មានករណីកិច្ចធ្វើបដិទានទៅវិញទៅមក ករណីយកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា។ បដិទាន សំដៅលើការស្តារឡើងវិញនូវស្ថានភាពដើម ឬ ការប្រគល់ត្រឡប់វិញ។ ការរំលាយកិច្ចសន្យា គឺនាំឲ្យមានករណីកិច្ចធ្វើបដិទាន និងមានទំនាក់ទំនងជាមួយនឹងការអនុវត្តករណីកិច្ចក្នុងពេលជាមួយគ្នា។ បន្ថែមពីលើនេះផងដែរ ក្នុងករណីដែលគូភាគីមានករណីកិច្ចសងជាប្រាក់ដោយការរំលាយកិច្ចសន្យាពេលនោះអានុភាពរបស់វាគឺ ភាគីត្រូវសងជាមួយនឹងការប្រាក់ដោយគិតចាប់តាំងពីថ្ងៃដែលបានទទួលប្រាក់ដើម។ ចំពោះភាគីដែលមានករណីកិច្ចបង្វិលជាវត្ថុ ឬ ជាតាវកាលិកផ្សេងៗដែលខ្លួនបានទទួលទទួលទៅភាគីម្ខាងទៀត ដោយសារការរំលាយត្រូវសងទាំងផលដែលទទួលបានពីវត្ថុ ឬ តាវកាលិកនោះផងដែរ។

**-អានុភាពចំពោះតតិយជន** គឺជាអានុភាពដែលកើតចេញពីការរំលាយកិច្ចសន្យា មិនត្រឹមតែគូភាគីនោះ

[64] មាត្រា ៤១២ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

ទេ តែវាក៏មានអានុភាពចំពោះតតិយជនផងដែរ។ ចំពោះការរំលាយកិច្ចសន្យាមិនអាចធ្វើឲ្យខូចខាតប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើយ។ ក្នុងន័យនេះ ការការពារផលប្រយោជន៍របស់តតិយជន ក្នុងករណីដែលតតិយជននោះ គឺជាជនសុចរិត និងគ្មានកំហុសតែប៉ុណ្ណោះ។ ចំណែកឯ តតិយជនដែលជាជនទុច្ចរិត ឬ សុចរិតតែមានកំហុសមិនត្រូវបានការពារឡើយ ព្រោះគាត់មិនមានផលប្រយោជន៍ត្រឹមត្រូវទេ។[65]

## ផ្នែកទី៤៖ ការផុតអាជ្ញាយុកាលនៃកាតព្វកិច្ច

អាជ្ញាយុកាលនៃការរលត់កាតព្វកិច្ច សំដៅទៅលើការរលត់សិទ្ធិលើបំណុលដោយផ្អែកលើការដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិលើក្នុងអំឡុងពេលដែលត្រូវបានកំណត់។ កូនបំណុល ត្រូវបានការពារដោយវិធាននៃការផុតអាជ្ញាយុកាលនេះ ដោយរឹតត្បិតនូវសិទ្ធិរបស់ម្ចាស់បំណុលមានប្រសិទ្ធិភាពតាមកាលកំណត់មួយជាក់លាក់។ ក្នុងនោះផងដែរ ដើម្បីធ្វើឲ្យរំលត់សិទ្ធិណាមួយ ការកំណត់ អំឡុងពេលនៃអាជ្ញាយុកាលត្រូវសមល្មមសក្តិសមសម្រាប់ឲ្យម្ចាស់បំណុលមានពេលគ្រប់គ្រាន់ក្នុងការអនុវត្ត។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិ ត្រូវបានគិតចាប់តាំងពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលនោះបាន។

### ១. លក្ខខណ្ឌនៃអាជ្ញាយុកាលសិទ្ធិលើបំណុល

លក្ខខណ្ឌនៃអាជ្ញាយុកាលសិទ្ធិលើបំណុល គឺជាលក្ខខណ្ឌដែលកំណត់ថា រយៈពេលប៉ុន្មានដែលសិទ្ធិលើបំណុលត្រូវបានរំលត់ និងនៅពេលដែលរយៈពេលដែលសិទ្ធិលើបំណុលត្រូវបានរំលត់ហើយ តើវានឹងមានអានុភាពកើតឡើងយ៉ាងដូចម្តេចដែរ?

អំឡុងពេលអាជ្ញាយុកាល គឺជារយៈពេលសម្រាប់ភាគីដែលទទួលការខូចខាតអាចធ្វើបណ្តឹងទាមទារសំណងចំពោះកិច្ចសន្យាណាមួយបាន។ ជាគោលការណ៍អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមានរយៈពេល ២ ឆ្នាំ។ ប៉ុន្តែទាក់ទងនឹងសិទ្ធិលើបំណុលថ្លៃទិញទំនិញ ឬ សេវារវាងផលិតករ ឬ ពាណិជ្ជករលក់ទៅឲ្យអ្នកមិនមែនជាពាណិជ្ជករ គឺរយៈពេលនៃអាជ្ញាយុកាលមានត្រឹមតែ ២ ឆ្នាំ ប៉ុណ្ណោះ ពីព្រោះសិទ្ធិលើបំណុលចំពោះអ្នកប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការរបស់អ្នកប្រើប្រាស់មានការពិបាកនឹងរក ព្រមទាំងការរក្សាទុកនៃភស្តុតាងក្នុងការសង។ ឧទាហរណ៍៖ លោក "ក" បានទិញទំនិញនៅហាងរបស់លោក "ខ" នៅថ្ងៃ ០១ ខែ មីនា ឆ្នាំ ២០២០ ប៉ុន្តែអត់បានឱ្យប្រាក់។ ដូចនេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល គឺមានរយៈពេលតែ ២ ឆ្នាំ គិតចាប់ពីថ្ងៃ ០១ ខែ មីនា ឆ្នាំ២០២០។ ម្យ៉ាងវិញទៀត ចំពោះសិទ្ធិលើបំណុលដែលបានចូលជាស្ថាពរដោយអានុភាពសាលក្រម ឬ សាលដីកាស្ថាពរ ឬ ការផ្សះផ្សារតាមផ្លូវតុលាការ ឬ វិធីផ្សេងទៀតដែលមានអានុភាពដូចនឹងសាលក្រមស្ថាពរ រយៈពេលនៃអាជ្ញាយុកាលត្រូវមានអំឡុងពេល ៥ ឆ្នាំ គិតចាប់ពីថ្ងៃដែលសិទ្ធិ

[65] សេចក្តីកំណត់ចំពោះក្រមមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០, មាត្រា៤១១

លើបំណុលដើមចូលជាស្ថាពរដែរ។ ផ្ទុយមកវិញ ប្រសិនបើនៅពេលដែលលិខិតទាំងនោះចូលជាស្ថាពរមុនពេលកំណត់ត្រូវអនុវត្តមិនទាន់មកដល់រយៈពេលនៃអាជ្ញាយុកាលគឺមានរយៈពេល ៥ ឆ្នាំ ឬ ២ ឆ្នាំ គិតចាប់ពីពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចមកដល់។ ក្រៅឡេកទៅសិទ្ធិលើទ្រព្យសម្បត្តិ ដែលក្រៅពីសិទ្ធិលើបំណុលវិញមានរយៈពេល ១០ ឆ្នាំសម្រាប់ការធ្វើបណ្តឹងទាមទារសំណង តែបើរយៈពេលនេះបានកន្លងផុត នោះសិទ្ធិលើបំណុលនឹងត្រូវរំលត់ដោយការផុតអាជ្ញាយុកាល។

តុលាការមិនអាចលើកឡើងនូវអាជ្ញាយកាលនៃការរលតសិទ្ធិលើបំណុលដោយខ្លួនឯងបានទេ ទោះបីជាបានដឹងពីអាជ្ញាយុកាលនៃការរំលត់សទ្ធិលើបំណុលក៏ដោយ ពីព្រោះបើអនុញ្ញាតឱ្យតុលាការអាចលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល គឺបំពាននូវគោលការណ៍ស្វ័យភាពនៃ បុគ្គលឯកជន។ លើសពីនេះទៀត បញ្ហានៃការលើកឡើងនេះជាផលប្រយោជន៍របស់ភាគីទេ នោះការលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរបសភាគីដែលមានប្រយោជន៍នេះ គឺជាភាពចាំបាច់មួយ ដើម្បីឱ្យតុលាការធ្វើការវិនិច្ឆ័យដើម្បីចេញសាលក្រមដោយផ្អែកលើអាជ្ញាយុកាល នៃការរំលត់សិទ្ធិលើបំណុល។ ជាគោលការណ៍ បុគ្គលដែលអាចលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល គឺមានតែកូនបំណុល កូនបំណុលសាមគ្គី អ្នកធានា អ្នកធានាដោយវត្ថុ និងតតិយជនដែលបានធ្វើលទ្ធកម្មទេ។ ប៉ុន្តែក្នុងច្បាប់បានអនុញ្ញាតឱ្យបុគ្គលដែលមានផលប្រយោជន៍ត្រឹមត្រូវតាមផ្លូវច្បាប់អាចលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានផងដែរ។ ផ្អែកលើគោលការណ៍នៃភាពបន្ទាប់បន្សំនៃសិទ្ធិប្រាតិភោគប្រត្យក្ស ក្នុងករណីដែលកូនបំណុលបានលើកឡើងនូវអាជ្ញាយុកាលនៃការរលត់កាតព្វកិច្ចសិទ្ធិលើបំណុលចំពោះម្ចាស់បំណុល ដែលនាំឲ្យផលប្រយោជនដែលកើតចេញពីការលើកឡើងនេះ ក៏ត្រូវកើតមានចំពោះតតិយជនដែរ។ ផ្ទុយទៅវិញ បើបុគ្គលដែលមិនមែនជាកូនបំណុលដែលមានសិទ្ធិលើកឡើងនូវអាជ្ញាយុកាល ហើយបានលើកឡើងធ្វើឱ្យកាតព្វកិច្ចនោះរលត់វិសាលភាពនៃការលើកឡើងនេះ មានតែរវាងបុគ្គលដែលបានលើកឡើង និងម្ចាស់បំណុលទេ មិនមានវិសាលភាពដល់កូនបំណុល ឬ បុគ្គលផ្សេងទៀតទេ។

### ២. ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ការផ្អាកអាជ្ញាយុកាល គឺជាការបញ្ឈប់ដំណើរការនៃអាជ្ញាយុកាលក្នុងករណីមានហេតុនៃការផ្អាក។ ការផ្អាកនូវអាជ្ញាយុកាល គឺមិនត្រឹមតែផ្អាកដំណើរការនៃអាជ្ញាយុកាលនោះមួយរយៈពេលទេ គឺចាត់ទុកថាអំឡុងពេលនៃអាជ្ញាយុកាលដែលមានដំណើរការកន្លងមកនេះ ពុំមានអត្ថន័យតាមផ្លូវច្បាប់។ ដូចនេះហើយពេលដែលហេតុនៃការផ្អាកនោះរលត់ទៅអំឡុងពេលនៃអាជ្ញាយុកាល នឹងចាប់ផ្តើមគិត ឬ ចាប់ផ្តើមរាប់ជាថ្មីម្តងទៀត។ ចំណុចនេះ វាផ្ទុយគ្នានឹងការបង្អង់អាជ្ញាយុកាល ដែលត្រូវចាប់ផ្តើមរាប់រយៈពេលនៃអាជ្ញាយុកាលបន្តបន្តទៀតគិតចាប់ពីពេលដែលហេតុនៃការបង្អង់នោះបានរលត់ ។

-មូលហេតុនៃការផ្អាកមាន បីប្រភេទគឺ

**ក.** ការទាមទារតាមផ្លូវតុលាការ ការចូលរួមក្នុងនីតិវិធីធនក្ស័យ ឬ ការអនុវត្តសិទ្ធិលើបំណុលប្រហាក់ប្រហែល ។

**ខ.** សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងរក្សាការពារ

**គ.** ការទទួលស្គាល់កាតព្វកិច្ចដោយសងមួយផ្នែកការបង់ការប្រាក់ ការដាក់ប្រាតិភោគ ឬ វិធីផ្សេង។

ហេតុដែលការផ្អាកក្នុងចំណុច ក និង ខ គឺជាហេតុនៃការផ្អាកពីព្រោះថា វាច្បាស់ណាស់ថាម្ចាស់បំណុល មានឆន្ទៈក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន ហេតុដូច្នេះ គេចាត់ទុកថា ម្ចាស់បំណុលមានភាពវៀសវៃគ្រប់គ្រាន់ ។ ការអនុវត្តសិទ្ធិនេះ សំដៅទៅលើការអនុវត្តសិទ្ធិរបស់អ្នកមានសិទ្ធិតាមរយៈតុលាការ។ នៅពេលដែលលក្ខខណ្ឌនៃ ការអនុវត្តសិទ្ធិបានរំលត់ដោយសារការលើកចោលបណ្តឹង ការដកបណ្តឹង និងការលុបចោលការរឹបអូស ជាដើម នោះមានអានុភាពនៃការផ្អាកអាជ្ញាយុកាលមិនកើតមានឡើងទេ។ ក៏ប៉ុន្តែ ប្រសិនបើអ្នកមានសិទ្ធិបានធ្វើការទាមទារក្រៅផ្លូវតុលាការទៅភាគីម្ខាងទៀត គឺតាមវិធីដាស់តឿនហើយមិនបានចាត់វិធានការទាមទារច្បាស់លាស់តាមផ្លូវតុលាការក្នុងអំឡុងពេល ០៦ ខែ នោះអានុភាពនៃការផ្អាកអាជ្ញាយុកាលមិនកើតមានឡើងទេ។[66] ហេតុនេះ ការដាស់តឿនដែលមានចែងក្នុងមាត្រា ៤៩៥ នៃក្រមរដ្ឋប្បវេណី ពុំមែនជាហេតុនៃការផ្អាកទេ តែជាហេតុនៃការបង្អង់អាជ្ញាយុកាលទៅវិញ។ ហេតុក្នុងចំណុច (គ) គឺការទទួលស្គាល់ជាវិជ្ជមានពីខាងកូនបំណុលនូវអត្ថិភាពនៃសិទ្ធិលើបំណុល។ ហេតុនេះ ចាំបាច់ត្រូវការពារផលប្រយោជន៍របស់ម្ចាស់បំណុលដែលអាចរង់ចាំហើយមិនអនុវត្តសិទ្ធិដោយមានជំនឿទៅលើសកម្មភាពកូនបំណុលនោះ។

**-អានុភាពនៃការផ្អាកអាជ្ញាយុកាល** គឺបើហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលកើតឡើងចំពោះកូនបំណុលនោះ ការផ្អាកនេះក៏កើតមានឡើងចំពោះអ្នកដទៃដែរ។ ប៉ុន្តែ បើហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលកើតឡើងចំពោះភាគីដទៃផ្សេងទៀតក្រៅពីកូនបំណុល នោះការផ្អាកមានអានុភាពតែរវាងម្ចាស់បំណុល និងភាគីនោះតែប៉ុណ្ណោះ។ លើកលែងករណីមានជាសកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងរក្សាការពារត្រូវបានធ្វើឡើងចំពោះភាគីដទៃផ្សេងទៀត (ក្រៅពីកូនបំណុល) ក៏ដោយ ប្រសិនបើសកម្មភាពនោះ ត្រូវបានជូនដំណឹងទៅកូនបំណុលក៏អានុភាពនៃការផ្អាកអាជ្ញាយុកាល នៃការរំលត់សិទ្ធិលើបំណុល នឹងកើតឡើងចំពោះកូនបំណុលដែរ។[67]

[66] មាត្រា ៤៩៥ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[67] មាត្រា ៤៩០ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

## ៣. ការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ការបង្អង់ គឺជាការបញ្ឈប់នៃដំណើរការនៃអាជ្ញាយុកាល តែក្នុងអំឡុងពេលដែលត្រូវបង្អង់នោះប៉ុណ្ណោះ។ ការបង្អង់នូវអាជ្ញាយុកាល គឺគ្រាន់តែជាការធ្វើកុំឱ្យអាជ្ញាយុកាលបានសម្រេចប៉ុណ្ណោះ។ វាមានន័យថា គ្រាន់តែជាការបញ្ឈប់នូវដំណើរការនៃអាជ្ញាយុកាលនៅដំណាក់កាលចុងក្រោយ ដែលជាពេលបញ្ចប់នៃអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។ ករណីការបង្អង់នៃការបញ្ចប់អាជ្ញាយុកាលមាន៖ (១) ការដាស់តឿន (២) អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ (៣) ការបង្អង់អាជ្ញាយុកាលរំលត់សិទ្ធិលើបំណុលរវាងប្ដីប្រពន្ធ និង (៤) មហន្តរាយធម្មជាតិ។

-**ការដាស់តឿន** គឺនៅអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលជិតកន្លងផុតទៅ ប្រសិនបើអ្នកមានសិទ្ធិ ពុំមានពេលវេលា ដើម្បីចាត់ចែងឱ្យផ្អាកអាជ្ញាយុកាលដូចជា ការធ្វើបណ្ដឹង ពេលនោះអ្នកមានសិទ្ធិអាចទទួលនូវការព្យួរពេលវេលា ៦ ខែ នៃការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ដោយការដាស់តឿនកូនបំណុល (ការទាម ទារក្រៅតុលាការ) ។ ហេតុនេះ ការដាស់តឿន គឺជាហេតុមួយនៃការបង្អង់ការសម្រេចអាជ្ញាយុកាល តែអាចដាស់តឿនបាន តែម្ដងប៉ុណ្ណោះ ។ ទោះបីមានការលើកចោលបណ្ដឹង ឬ ការដកបណ្ដឹងតាមផ្លូវតុលាការ ក៏ដោយ ក៏ត្រូវចាត់ទុកថា អ្នកប្ដឹង បានដាស់តឿនជាបន្តចាប់ពីពេលដែលពាក្យបណ្ដឹងត្រូវបានបញ្ជូនទៅភាគីម្ខាងទៀត។ ក្នុងករណីនេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវបានបង្អង់ក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីការលើកចោលបណ្ដឹង ឬ ការដកពាក្យបណ្ដឹង។ មានករណីមួយទៀត ដែលត្រូវចាត់ទុកថាជាការដាស់តឿនបន្តក្នុងអំឡុងពេលបណ្ដឹងកំពុងចាត់ការ ប្រសិនបើម្ចាស់បំណុលអះអាងសិទ្ធិរបស់ខ្លួនជាចុងចំលើយ។[68]

-**អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ** គឺការបង្អង់អាជ្ញាយុកាលក្នុងករណីអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅនេះបានលើកឡើង ដើម្បីការពារផលប្រយោជន៍របស់អនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅពីការដែលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវបានសម្រេចដោយសារតែជនទាំងនោះ ពុំបានចាត់វិធានការឱ្យផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបាន ព្រោះខ្លួនជាអនីតិជន ឬ ជននៅក្រោមអាណាព្យាលបាលទូទៅ គ្មានអ្នកតំណាងដែលច្បាប់បានកំណត់នៅក្នុងអំឡុងពេល ៦ ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាល។ ហេតុនេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល នឹងមិនត្រូវបានសម្រេចទេក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីពេលជន នោះក្លាយជាសមត្ថជន ឬ មានអ្នកតំណាងដែលច្បាប់កំណត់ ប្រសិនបើអនីតិជន ឬ ជននៅក្រោម អាណាព្យាបាលទូទៅគ្មានអ្នកតំណាងដែលច្បាប់កំណត់ក្នុងអំឡុងពេល

[68] មាត្រា ៤៩៥ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

៦ ខែមុនពេលផុតអំឡុង ពេលនៃ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ។

-**ការបង្អង់អាជ្ញាយុកាលរំលត់សិទ្ធិលើបំណុលរវាងប្តីប្រពន្ធ** គឺការចាត់វិធានការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរវាងប្តីប្រពន្ធជាការពិបាកមួយ ហេតុនេះច្បាប់បានទុកពេលវេលាមួយសមស្របក្រោយពីការរំលាយអាពាហ៍ពិពាហ៍ ដើម្បីបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។ ករណីនេះបានកំណត់ថា **"ចំពោះសិទ្ធិដែលសហព័ទ្ធម្ខាងមានលើសហព័ទ្ធម្ខាងទៀត អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ ខែ ក្រោយពីការរំលាយអាពាហ៍ពិពាហ៍ឡើយ"** ។[69]

-**ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយសារមហន្តរាយធម្មជាតិ** គឺសំដៅករណីដែលអ្នកមានសិទ្ធិមិនអាចចាត់វិធានការឱ្យផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដោយសារការជួបប្រទះនូវគ្រោះមហន្តរាយធម្មជាតិដូចជា ខ្យល់ព្យុះ រញ្ជួយផែនដី ទឹកជំនន់ ប្រធានសក្តិផ្សេងៗ ជាដើម។ នៅពេលណាមួយក្នុង ៦ ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីប្រធានសក្តិនោះបានកន្លងផុតឡើយ។[70]

## ផ្នែកទី៥៖ ការអនុវត្តសិទ្ធិលុបចោល

ជាទូទៅ កិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរវាងគូភាគី មានកម្មវត្ថុស្របច្បាប់ ហើយធ្វើឡើងដោយសមត្ថជននោះកិច្ចសន្យានឹងមានអានុភាពក្នុងការអនុវត្ត។ ប៉ុន្តែ ក្នុងករណីមួយចំនួន កិច្ចសន្យាត្រូវបានគេលុបចោល ដោយសារកិច្ចសន្យានោះបង្កើតឡើងដោយ ជនកម្រិតសមត្ថភាព និង កិច្ចសន្យាដែលបានបង្កើតឡើងរវាងគូភាគីមានភាពមិនប្រក្រតី និងមានភាពមិនត្រឹមត្រូវណាមួយតាមរយៈការសម្តែងឆន្ទៈ និងនៅក្នុងករណីដែលមានវិការៈក្នុងការបង្ហាញឆន្ទៈ។

### ១. ការលុបចោលនូវសកម្មភាពដែលធ្វើឡើងដោយជនកម្រិតសមត្ថភាព

សកម្មភាពដែលធ្វើឡើងដោយជនកម្រិតសមត្ថភាពអាចលុបចោលបាន ដោយជនទាំងនោះរួមមាន អនីតិជន ជនក្រោមអាណាព្យាបាលទូទៅ និងជនស្ថិតក្រោមហិតូបត្ថម្ភ។

-**អនីតិជន** សំដៅលើជនដែលមានអាយុក្រោម ១៨ឆ្នាំ។ ហើយសកម្មភាពដែលអនីតិជនបានធ្វើដោយមិនមានការទទួលយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះទេ សកម្មភាពទាំងនោះអាចលុបចោលបាន។[71] ការលុបចោលសកម្មភាពនេះ ដើម្បីការពារផលប្រយោជន៍របស់

[69] មាត្រា ៤៩៧ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[70] មាត្រា ៤៩៨ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[71] មាត្រា ១៨ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

នីតិជននោះ បានន័យថា អនីតិជន គឺជាបុគ្គលដែលស្ថិតក្នុងវ័យ ដែលមិនចេះគិតគូរអោយបានវែងឆ្ងាយ និងឲ្យបានល្អិតល្អន់ ដែលងាយនិងភាន់ច្រឡំ ឬងាយនឹង ជឿគេ។ ប៉ុន្តែសកម្មភាពមួយចំនួនដែលបានធ្វើដោយអនីតិជន ក៏អាចមានអានុភាពបានដែររួមមាន សកម្មភាពទទួលបានសិទ្ធិ សកម្មភាពដែលទាក់ទងនឹងសកម្មភាពប្រចាំថ្ងៃ ការចាត់ចែងទ្រព្យសម្បត្តិ ដែលអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះបានអនុញ្ញាតឲ្យចាត់ចែងនិងសកម្មភាពទាក់ទងនឹងអាជីវកម្មដែលអនីតិជន ត្រូវបានអនុញ្ញាតអោយធ្វើអោយអ្នកមានសិទ្ធិ អំណាចមេបា ឬ អាណាព្យាបាល។

-**ជនក្រោមអាណាព្យាបាលទូទៅ** សំដៅលើជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះ សមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។[72] ចំពោះសកម្មភាពរបស់ជនក្រោមអាណាព្យាបាលទូទៅបានធ្វើ អាចធ្វើការលុបចោលបាន។ ទោះបីជាសកម្មភាពដែលជននោះបានធ្វើអោយមានការយល់ព្រមដោយអាណាព្យាបាលទូទៅក៏ដោយ ក៏សកម្មភាពនោះអាចធ្វើការលុបចោលបានដែរ ព្រោះជននៅក្រោមអាណាព្យាបាលទូទៅ ជាជនដែលស្ថិតក្នុងស្ថានភាពជានិរន្តន៍ដែលខ្វះសមត្ថភាពក្នុងការសំដែងឆន្ទៈ ឬ ចុះកិច្ចព្រមព្រៀងផ្សេងៗ។ ចំពោះសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ មិនអាចធ្វើការលុបចោលបានទេ។[73]

-**ជននៅក្រោមហិតូបត្ថម្ភ** សំដៅលើជនដែលមានសមត្ថភាពតិចតួចក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។[74] លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ សកម្មភាពដែលបានធ្វើឡើងដោយជនក្រោមហិតូបត្ថ ម្ភដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈ អាចធ្វើការលុបចោលបានរួមមាន៖ ការទទួល ឬ ការប្រើប្រាស់ទុន ការខ្ចីទ្រព្យ ឬ ការធ្វើសកម្មភាពបណ្តឹង។ល។

## ២. ការលុបចោលដោយមានវិការៈ

កិច្ចសន្យា ត្រូវបានបង្កើតឡើងដោយបានបំពេញលក្ខខណ្ឌដែលបានកំណត់ ប៉ុន្តែគេអាចធ្វើការលុបចោល ដោយសារមានវិការៈតាមរូបភាពរួមមាន ការភាន់ច្រឡំ ការឆបោក ព័ត៌មានមិនពិត ការគំរាមកំហែង អំពើកេងចំណេញហួសហេតុ ការរំលោភបំពានលើស្ថានភាព។ ប៉ុន្តែទោះបីជាកិច្ចសន្យាបានប្រព្រឹត្តរួចហើយ និងមានអានុភាពក្នុងការអនុវត្តក៏ដោយ ក៏កិច្ចសន្យាទាំងនោះត្រូវបានលុបចោលដែរ ដោយការបង្ហាញមានវិការៈ។

[72] មាត្រា ២៤ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[73] មាត្រា ២៦ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[74] មាត្រា ២៨ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

ការភាន់ច្រឡំ គឺជាសកម្មភាពនៃការសម្ដែងឆន្ទៈ ដែលមានលក្ខណៈខុសគ្នាទៅនឹងឆន្ទៈ ពិតរបស់ខ្លួន ហើយគេក៏មិនបានដឹងអំពីភាពខុសគ្នានេះ នៅពេលបង្ហាញឆន្ទៈឡើយ។ ក្នុងករណីនេះ ប្រសិនបើគូភាគីបាន ដឹងពីការភាន់ច្រឡំ នោះមិននាំឲ្យការចុះកិច្ចសន្យានោះទេ។ ក្នុងករណីដែល ភាគីដែលមានការភាន់ច្រឡំអំពី ចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតក្នុងស្ថានភាព ដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគី ដែលបានភាន់ច្រឡំអាចធ្វើការលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។ រីឯ ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការ ភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬចំណុចដែលខ្លួនយល់ថា សំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការ ភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ។[75] ចំណែក ការឆបោកវិញ គឺជាឧបាយកលដោយភាគីម្ខាង ឬ តតិយជនយកមកប្រើដើម្បីអោយភាគីម្ខាងទៀតមាន ការភាន់ច្រឡំ រួចភាគីដែលមានការភាន់ច្រឡំនោះក៏សម្ដែងឆន្ទៈចុះកិច្ចសន្យា។ បុគ្គល ដែលបានធ្វើការបង្ហាញ ឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀតអាចលុបចោលបាននូវកិច្ចសន្យា ដោយហេតុថាការបង្ហាញឆន្ទៈ នោះមានវិការៈ។ ម៉្យាងវិញទៀត ក្នុងករណីដែលការបង្ហាញឆន្ទៈអាច លុបចោលនូវកិច្ចសន្យា ដោយហេតុថាការ បង្ហាញឆន្ទៈនោះមានវិការៈលុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈបានដឹង ឬ អាចដឹងអំពី ការឆបោកនោះ។ ការលុបចោលនូវកិច្ចសន្យា ដោយការឆបោក ក្រៅពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយ ជនបាន ប៉ុន្តែប្រសិនបើតតិយជន ជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាព នៃការលុបចោលចំពោះ តតិយជនបានឡើយ។[76] មួយវិញទៀត ចំពោះពត៌មានមិនពិតវិញ គឺហេតុដែលត្រូវបាន លើកឡើងដោយភាគី សម្រាប់ជាមូលដ្ឋាននៅក្នុងការបង្កើតកិច្ចសន្យា គឺខុសពីការគិត។ ទន្ទឹមនឹងនេះ ប្រសិនបើអ្នកបង្ហាញឆន្ទៈបានដឹងថា ហេតុនោះមិនមែនជាការពិត នោះខ្លួននឹងមិនបង្ហាញនោះទេ ហើយភាគី នោះអាចលុបចោលកិច្ចសន្យា បានដោយសារការបង្ហាញឆន្ទៈនោះមានវិការៈ។ ក្នុងករណីដែលពត៌មានមិនពិត គឺតម្រូវឲ្យភាគីម្ខាងទៀតមិនបានដឹងថាហេតុដែលគាត់បានលើកឡើងនោះមិនមែនជាការពិត។ ប្រសិនបើគាត់ បានដឹងថា ហេតុនោះខុសពីការគិតវាត្រូវបានគេចាត់ទុកថាជាការបោក។ ម្យ៉ាងទៀត ប្រសិនបើភាគីដែលបាន បង្ហាញការមិនពិតនោះមានកំហុសក្នុងការបង្ហាញពត៌មានមិនពិតនេះ ភាគីនោះត្រូវទទួលខុសត្រូវក្នុងការសង សំណងការខូចខាត។[77]

[75] មាត្រា ៣៤៦ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[76] មាត្រា ៣៤៧ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[77] មាត្រា ៣៤៨ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

លើសពីនេះ ការគំរាមកំហែងក្នុងនេះ គឺការបង្ហាញឆន្ទៈដែលផ្ទុយទៅនឹងគោលបំណងរបស់ខ្លួន ដោយសារមានការភ័យខ្លាចពីភាគីម្ខាងទៀត ឬ តតិយជន។ ការបង្ហាញឆន្ទៈនោះមានវិការៈ ហើយបញ្ញត្តិច្បាប់អនុញ្ញាតឲ្យអ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន។[78] ផ្ទុយទៅវិញ វាមិនមានបញ្ញត្តិច្បាប់ណាការពារតតិយជនទេ ទោះបីជាតតិយជននោះបានបង្កើតទំនាក់ទំនងក្នុងកិច្ចសន្យាដោយផ្អែកលើកិច្ចសន្យាដែលអាចត្រូវបានគេលុបចោលនោះ។ ដូច្នេះ អ្នកបង្ហាញឆន្ទៈអាចអះអាងពីអានុភាពនៃការលុបចោលចំពោះតតិយជន ទោះបីជាតតិយជននោះជាសុចរិតក៏ដោយ។ រីឯ អំពើកេងចំណេញ គឺករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាសដែល ភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ខ្លៅ ឬ ការខ្វះបទពិសោធន៍ ហើយបានកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ហើយភាគីម្ខាងទៀតនោះអាចលុបចោលកិច្ចសន្យាដោយហេតុការបង្ហាញឆន្ទៈមានវិការៈ។ ច្បាប់ក៏បានការពារភាគីម្ខាងនៃកិច្ចសន្យាដែលជាអ្នកប្រើប្រាស់ពីអ្នកផលិតនូវផលិតផលជាច្រើន ដែលប៉ុនប៉ងកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ដោយឆ្លៀតឱកាសកេងយកផលប្រយោជន៍ពីអតិថិជនដែលមានភាពល្ងង់ខ្លៅ ឬ ខ្វះបទពិសោធន៍។ យើងឃើញថាអ្នកបង្ហាញឆន្ទៈ គឺជាសាធារណជនដែលប្រើប្រាស់ផលិតផលជាទូទៅ និងភាគីម្ខាងទៀត គឺជាផលិតករដែលផលិតផលិតផលនៅក្នុងទ្រង់ទ្រាយធំ។ ទោះបីជាភាគីម្ខាងបានកេងចំណេញហួសហេតុពីកិច្ចសន្យា គេមិនអាចចាត់ទុកថាគ្រប់កិច្ចសន្យាបែបនេះទាំងអស់ទេ ត្រូវចាត់ទុកថាជា អំពើកេងចំណេញហួសហេតុទេ វាតម្រូវឲ្យភាគីម្ខាងទៀតបង្កើតកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ខ្លៅ ឬ ការខ្វះបទពិសោធន៍។ លក្ខខណ្ឌមួយចុងក្រោយនៃចំណុចនេះ គឺការរំលោភបំពានលើស្ថានភាព ពោលករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះនូវការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ សង្គម ឬ បានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀត ដែលភាគីម្ខាងទៀត មិនអាចប្រឆាំងតបបានទេ។ ក្នុងករណីនេះ ភាគីដែលបានរំលោភបំពានលើស្ថានភាពមិនត្រូវបានគេចាត់ទុកថាបានគំរាមកំហែងឡើយ ព្រោះគាត់មិនបានប្រើវិធានការបង្ខំ។ ដើម្បីកំណត់ថាជាការរំលោភបំពានលើស្ថានភាព វាមានភាពចាំបាច់ដែលភាគីម្ខាងទៀតឆ្លៀតឱកាសនៃស្ថានភាពទន់ខ្សោយរបស់អ្នកបង្ហាញឆន្ទៈ។ ដូចនេះភាគី ម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[79]

### ២.១ អ្នកដែលមានសិទ្ធិលុបចោល

សកម្មភាពដែលអាចលុបចោលបានដោយមូលហេតុថា មានវិការៈក្នុងការបង្ហាញឆន្ទៈ ដែលបាន

---

[78] មាត្រា ៣៥០ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[79] មាត្រា ៣៤៩ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

រៀបរាប់ខាងលើ អ្នកដែលបង្ហាញឆន្ទៈដោយវិការៈ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះ អាចលុបចោលនូវសកម្មភាពនោះបាន។ សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈ ឬ អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ។ ចំពោះការលុបចោលដោយមូលហេតុគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈអនីតិភាព ឬ ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ក្នុងការធ្វើសកម្មភាពផ្សេងទៀត សាមីខ្លួន អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈនៃជននោះអាចលុបចោលនូវសកម្មភាពបាន។ សន្តតិជន ឬ អចិ្ឆយលាភី សកលរបស់សាមីខ្លួន ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ។ ការលុបចោលដែលធ្វើឡើងដោយជនដែលគ្មានសមត្ថភាព ឬ ត្រូវបានគេកម្រិតសមត្ថភាពមិនត្រូវបានគេចាត់ទុកថាជាសកម្មភាព ដែលអាចលុបចោលបាននោះទេ ព្រោះជាទូទៅការបដិសេធនូវអានុភាពនៃសកម្មភាពត្រូវបានចាត់ទុកថាជាការការពារនូវជននោះ។[80]

អ្នកមានសិទ្ធិលុបចោល អាចធ្វើសច្ចានុមតិចំពោះសកម្មភាពដែលអាចលុបចោលបាន។ ប៉ុន្តែ ក្នុងករណីដែលលុបចោលសកម្មភាព ដោយយកការបង្ហាញឆន្ទៈដោយមានវិការជាមូលហេតុ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន ចាប់តាំងពីពេលដែលអ្នកមានសិទ្ធិលុបចោលនោះ បានដឹងអំពីមូលហេតុនៃការលុបចោល។[81] រីឯ សកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពវិញ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន នៅក្រោយពេលដែលស្ថានភាពដែលជា មូលហេតុនៃការលុបចោលអាចផ្តល់សច្ចានុមតិបាន នៅក្រោយពេលដែលស្ថានភាពដែលជាមូលហេតុនៃការលុបចោលត្រូវបានរលត់។ សច្ចានុមតិ សំដៅលើសកម្មភាពដែលបុគ្គលដែល មានសិទ្ធិលុបចោលបង្ហាញជាស្ថាពរថា ខ្លួនមិនអនុវត្តសិទ្ធិលុបចោលដោយផ្អែកលើបុរេលក្ខខណ្ឌដែលបានដឹងថា សកម្មភាពរបស់ខ្លួនអាចលុបចោលបាន។ ការលុបចោលសកម្មភាពដោយមូលហេតុមានវិការៈអាចផ្តល់សច្ចានុមតិ បាននៅពេលដែលជនមានសិទ្ធិលុបចោលនោះ បានដឹងពីមូលហេតុនៃការលុបចោល បានន័យថា ទោះបីជនដែលមានសិទ្ធិលុបចោលនោះ បានដឹងថាខ្លួនមានសិទ្ធិលុបចោលនូវសកម្មភាពនោះ ប៉ុន្តែនៅតែយល់ព្រមអនុវត្ត។ ជនដែលបានកម្រិតសមត្ថភាព អាចអនុវត្តសិទ្ធិលុបចោលនូវសកម្មភាព មុនពេលដែលជននោះមានសមត្ថភាពធ្វើការឡើងវិញ ឬ មុនការឈានចូលនីតិភាព ប៉ុន្តែមិនអាចផ្តល់សច្ចានុមតិបានទេ។ ក្នុងករណីដែលមានការអនុវត្តកាតព្វកិច្ចទាំងមូល ឬ មួយផ្នែកនៃកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ត្រូវចាត់ទុកថាបានផ្តល់សច្ចានុមតិ ហើយមិនអាចធ្វើការលុបចោលនូវសកម្មភាពនោះវិញបានទេ។

---

[80] មាត្រា ៣៥៩ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[81] មាត្រា ៣៦១ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

## ២.២ អាជ្ញាយុកាលនៃការរលត់សិទ្ធិលុបចោល

ប្រសិនបើអ្នកដែលមានសិទ្ធិលុបចោលមិនអនុវត្តសិទ្ធិនោះក្នុងរយៈពេល ៣ ឆ្នាំ ចាប់តាំងពីពេលដែលខ្លួនក្លាយទៅជាអ្នកដែលអាចផ្តល់សច្ចានុមតិនោះសិទ្ធិលុបចោល និងសិទ្ធិទាមទារឲ្យសងសេចក្តីចម្រើនដោយឥតហេតុដែលកើតឡើងដោយសារការលុបចោលនោះត្រូវរលត់។ ការផ្អាកអាជ្ញាយុកាល មិនត្រូវបានយកមកអនុវត្តឡើយ។ យ៉ាងណាមិញ សិទ្ធិលុបចោលត្រូវរលត់ផងដែរ ប្រសិនបើហួសអំឡុងពេល ១០ ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាពនោះ។ ក្រោយពេលអាជ្ញាយុកាលរំលត់ត្រូវបានបញ្ចប់ នោះជនដែលមានសិទ្ធិលុបចោល មិនអាចលុបចោលសកម្មភាពនោះទៀតទេ នាំឲ្យសកម្មភាពនោះត្រូវបានចាត់ទុកថាមានសុពលភាពជាស្ថាពរ។[82]

នៅក្រោយពេលដែលអាចផ្តល់សច្ចានុមតិ សកម្មភាពដែលអាចលុបចោលបានត្រូវចាត់ទុកថា បានផ្តល់សច្ចានុមតិរួចហើយក្នុងករណីគឺ៖ (១) ការអនុវត្តកាតព្វកិច្ចទាំងមូល ឬ មួយផ្នែក ចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាព ដែលអាចលុបចោលបាន ឬការដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចនោះ (២) ការអនុវត្តសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ឬ ការទាមទារឲ្យភាគីម្ខាងទៀតអនុវត្ត។ (៣) អនុប្បទាន ឬ ការចាត់ចែងផ្សេងទៀតនូវសិទ្ធិទាំងមូល ឬ មួយផ្នែក ចំពោះសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន។[83]

[82] មាត្រា ៣៦៣ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

[83] មាត្រា ៣៦២ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧

# សេចក្តីសន្និដ្ឋាន

ជាចុងក្រោយអាចសន្និដ្ឋានបានថា សារៈសំខាន់ដែលកើតចេញពីការយល់ដឹងអំពីប្រធានបទ **"មូលហេតុនៃការរលត់កាតព្វកិច្ច"** សម្រាប់សង្គមដោយជាកត្តាសំខាន់ក្នុងទំនាក់ទំនងប្រចាំថ្ងៃដោយបានការពារនូវប្រយោជន៍សាធារណៈ។ លើសពីនេះ ការសិក្សាស្រាវជ្រាវនូវប្រធានបទនេះបានឱ្យខ្ញុំដឹងថា ច្បាប់បានសម្របសម្រួលនូវទំនាក់ទំនងក្នុងសង្គម ដោយបង្កើននូវការជួយគ្នាទៅវិញទៅមកភាពយោគយល់គ្នា និងលើកលែងឲ្យគ្នាទៅវិញទៅមក។ ម្យ៉ាងវិញទៀត ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នក៏មានការបញ្ញត្តិច្បាប់អំពីកាតព្វកិច្ចសម្រាប់អនុវត្តក្នុងទំនាក់ទំនងគតិយុត្តរវាងម្ចាស់បំណុល និងកូនបំណុលដោយបង្ហាញយ៉ាងច្បាស់នូវសិទ្ធិ និងករណីយកិច្ចចំពោះគូភាគី ហើយក៏រឹតបណ្តឹងនូវការអនុវត្តដោយសុចរិត និងជៀសវាងការគេចវេះមិនព្រមអនុវត្តនូវកាតព្វកិច្ចនោះ។

ចំពោះការរលត់កាតព្វកិច្ចតាមគូភាគី គឺជាការបង្ហាញនូវឆន្ទៈរបស់គូភាគីក្នុងការរលត់នូវកាតព្វកិច្ចដោយភាពព្រមព្រៀង ក្នុងនោះយើងឃើញថាវាជាដំណោះស្រាយមួយដែលមានភាពយោគយល់សន្តោសប្រណីចំពោះគ្នាដើម្បីរក្សានូវទំនាក់ទំនងរបស់គូភាគី។ ដោយឡែកគូភាគីអាចធ្វើការរលត់នូវកាតព្វកិច្ចដោយ ការសងការទូទាត់ ការលើកលែងរបស់ម្ចាស់បំណុល នវកម្ម ឬ ព្យាកុលភាព និងការទទួលបន្ទុកហានិភ័យ។ ការរលត់កាតព្វកិច្ចតាមច្បាប់កំណត់គឺជាការរលត់នូវកាតព្វកិច្ចដោយភាគីនៃកិច្ចសន្យា ឬ ភាគីណាម្ខាងបង្ហាញឆន្ទៈក្នុងការរលត់នូវកាតព្វកិច្ចនោះ។ តាមរយៈកំហុសរបស់ភាគីម្ខាងនៃកិច្ចសន្យាមិនអនុវត្ត ឬអនុវត្តដោយបំពានទៅលើកិច្ចសន្យាធ្ងន់ធ្ងរបណ្តាលឲ្យមិនអាចសម្រេចតាមគោលបំណងនៃកិច្ចសន្យា។ មួយផ្នែកទៀត ទាក់ទងនឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ក៏បានកំណត់អំពីអាជ្ញាយុកាលកំណត់ផងដែរ សម្រាប់ការពារដល់ភាគីដែលអនុវត្តនូវកាតព្វកិច្ចនោះ ហើយវាបានបង្ហាញអោយភាគីដែលជាម្ចាស់បំណុល ត្រូវយកចិត្តទុកដាក់ទៅលើសិទ្ធិដែលខ្លួនមានជៀសវាងភាពធ្វេសប្រហែសបណ្តាលឲ្យបាត់បង់សិទ្ធិនោះ។ កាតព្វកិច្ចនឹងត្រូវរលត់ក្នុងករណីដែលគូភាគីនៃកិច្ចសន្យាអាចធ្វើការរំលត់កាតព្វកិច្ចដោយមានការព្រមព្រៀងគ្នា ដោយអនុវត្តតាមវិធានមួយចំនួនខាងលើ។ ការអនុវត្តនូវការរលត់កាតព្វកិច្ច ច្បាប់បានទុកនូវសិទ្ធិឲ្យភាគីធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសវិធានណាមួយដែលគ្មានការបង្ខំ និងស្របទៅតាមឆន្ទៈរបស់ភាគី។ តាមរយៈនេះផងដែរ អ្នកអនុវត្តច្បាប់មានការយកចិត្តទុកដាក់ក្នុងការសម្របសម្រួល និងទុកឱកាសឲ្យភាគីបានសម្រេចចិត្តដោយខ្លួនឯងមុនពេលបញ្ចប់នូវកាតព្វកិច្ច និងមិនឲ្យភាគីណាមួយបាត់បង់ផលប្រយោជន៍របស់ខ្លួន។

# អនុសាសន៍

# អនុសាសន៍

ការសិក្សាស្រាវជ្រាវលើប្រធានបទ **"មូលហេតុនៃកការរលត់កាតព្វកិច្ច"** បានស្តែងឲ្យយើងដឹងអំពីចំណុចជាច្រើនជាមូលហេតុនៃវិវាទ ទោះបីហេតុផលទាំងនោះផ្តើមចេញពីឆន្ទៈ ឬ ក្រៅឆន្ទៈរបស់ភាគីក្តី។ ក្នុងការរួមចំណែកជម្រុញ និងលុបបំបាត់ភាពអសកម្មនានាក្នុងជីវភាពគតិយុត្តទាក់ទងទៅនឹងបញ្ហាខាងលើ ខ្ញុំបាទសូមអនុញ្ញាតធ្វើការលើកឡើងនូវអនុសាសន៍ដូចខាងក្រោម៖

គូភាគីចាំបាច់ត្រូវសម្តែងនូវឆន្ទៈដោយពិតប្រាកដ និងសេរីភាព សុចរិតទៀងត្រង់ក្នុងអំឡុងពេលចុះកិច្ចសន្យាជាមួយគ្នាដើម្បីជៀសវាងមានភាពមិនប្រក្រតីទាក់ទងនឹងការបង្ហាញឆន្ទៈ នាំឲ្យមានវិការៈកើតឡើងដូចជា៖ ការភាន់ច្រឡំ ការឆបោក និងការកេងចំណេញហួសហេតុ។ គូភាគីចាំបាច់ត្រូវពិនិត្យឲ្យបានច្បាស់លាស់នូវកម្មវត្ថុនៃកិច្ចសន្យា ព្រមទាំងបង្ហាញអំពីមូលហេតុច្បាស់លាស់ក្នុងការចុះកិច្ចសន្យា។ ភាគីត្រូវយល់ដឹងពីផលប៉ះពាល់ ដែលបណ្តាលមកពីកម្មវត្ថុនៃកិច្ចសន្យា ដែលមិនត្រូវប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អក្នុងសង្គម។ គូភាគីត្រូវអនុវត្តកាតព្វកិច្ចដែលកើតចេញពីឆន្ទៈរបស់ខ្លួនដោយសុចរិតស្មោះត្រង់រវាងគ្នាទៅវិញទៅមក។ ក្នុងករណីដែលភាគីណាមួយមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួននោះ ភាគីត្រូវមានទំនួលខុសត្រូវចំពោះកំហុសរបស់ខ្លួន ហើយហ៊ានអះអាងដោយភាពពេញចិត្ត និងមិនស្ទាក់ស្ទើរក្នុងការជួសជុលនូវសំណងការខូចខាតនោះ។ ចំពោះភាគីដែលជាម្ចាស់បំណុលទាក់ទងទៅនឹងអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មិនត្រូវធ្វេសប្រហែស មិនយកទុកដាក់ទៅនឹងការទាមទាររបស់ខ្លួនដែលមានទំនាក់ទំនងជាមួយកូនបំណុលឡើយ។

អ្វីដែលខ្ញុំសង្ឃឹមនោះគឺ ចំណងគតិយុត្តិដែលបានបង្កើតឡើងដោយភាគី និងប្រព្រឹត្តទៅដោយគោរពតាមច្បាប់កំណត់ និងដោយឆន្ទៈរបស់ភាគីពិតប្រាកដ។ ក្នុងគោលបំណងឆ្ពោះទៅរកទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងជៀសវាងភាពមិនប្រក្រតីកើតឡើងក្នុងសង្គម។

# ឯកសារយោង

# ឯកសារយោង

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើនៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣

២. ក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ៖ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

៣. ក្រមរដ្ឋប្បវេណី ជប៉ុន

៤. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៦

៥. សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១៣

៦. ក្រឹត្យច្បាប់ លេខ៣៨ ក្រ. ច, ២៨ តុលា ១៩៨៨

៧. មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, បោះពុម្ពលើកទី១, នៅភ្នំពេញ ខែធ្នូ ឆ្នាំ ២០១៥

៨. ញឹក វុទ្ធី, នីតិកាតព្វកិច្ច, ភាគ១, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច

៩. ជិន វណ្ណារ៉ា, មេរៀននីតិកាតព្វកិច្ច, ឆ្នាំ ២០១៤

១០. អៀង សំណាង, ក្រមរដ្ឋប្បវេណីស្តីពីកាតព្វកិច្ច, ភាគ២, បោះពុម្ពលើកទី១, នៅខែមីនា ឆ្នាំ២០១២

# ឧបសម្ព័ន្ធទី១

# ក្រមរដ្ឋប្បវេណី

# គន្ថីទី ៤
# កាតព្វកិច្ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១
### ប្រភពនៃកាតព្វកិច្ច និង និយមន័យនៃទស្សនៈផ្សេងៗ

**មាត្រា ៣០៨.-** និយមន័យនៃកាតព្វកិច្ច

១-កាតព្វកិច្ចគឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីរនាក់ ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់មានករណីយកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត ។

២-បុគ្គលដែលមានករណីយកិច្ចហៅថា កូនបំណុល រីឯបុគ្គលដែលទទួលផលប្រយោជន៍ពីករណីយកិច្ចនោះហៅថា ម្ចាស់បំណុល ។

៣-ម្ចាស់បំណុលមានសិទ្ធិត្រូវផ្គាទៅនឹងករណីយកិច្ចរបស់កូនបំណុល ។

**មាត្រា ៣០៩.-** ប្រភពនៃកាតព្វកិច្ច

១-កាតព្វកិច្ចកើតមានឡើងដោយកិច្ចសន្យា ដោយសកម្មភាពឯកតោភាគី ដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្តីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និង ដោយបញ្ញត្តិនៃច្បាប់ ។

២-កាតព្វកិច្ចដែលកើតឡើងដោយកិច្ចសន្យា និង ដោយសកម្មភាពឯកតោភាគី គឺជាកាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី ។

៣-កាតព្វកិច្ចដែលកើតឡើងដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្តីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និង ដោយបញ្ញត្តិនៃច្បាប់ គឺជាកាតព្វកិច្ចដែលកំណត់ដោយច្បាប់ ។ បញ្ញត្តិពីជំពូកទី ៣ (ការអនុវត្តកិច្ចសន្យា) ដល់ជំពូកទី ៧ (ការរលត់កាតព្វកិច្ច) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះកាតព្វកិច្ចដែលកំណត់

៣-ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៤-ការលុបចោលនូវកិច្ចសន្យាដោយការភាន់ច្រឡំ ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំ មិនអាចអះអាងនូវការលុបចោលចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៧.–** ការឆបោក

១-បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះ បានដឹង ឬ អាចដឹងអំពីការឆបោកនោះ ។

៣-ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៨.–** ព័ត៌មានមិនពិត

១-នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែ ប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមាន

វិការៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងភាគីដែលបានបង្ហាញឆន្ទៈក្នុងការទាមទារសំណងនៃការខូចខាតពីបុគ្គលដែលបានបង្ហាញការណ៍មិនពិតនោះទេ ក្នុងករណីដែលបុគ្គលនេះមានកំហុស ។

៣-ការលុបចោលនូវកិច្ចសន្យាដោយព័ត៌មានមិនពិត ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មានមិនពិត មិនអាចអះអាងនូវអានុភាពនៃការលុបចោល ចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៩.-** ការរំលោភបំពានលើស្ថានភាព

១-នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ការលុបចោលនូវកិច្ចសន្យាដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាពបានឡើយ ។

**មាត្រា ៣៥០.-** ការគម្រាមកំហែង

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

**មាត្រា ៣៥១.-** អំពើកេងយកចំណេញហួសហេតុ

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ ហើយ

**មាត្រា ៣៥៧.- អត្ថន័យនៃមោឃភាព**

ប្រសិនបើអត្ថន័យនៃសកម្មភាព ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន ។ ក្នុងករណីដែលសកម្មភាពត្រូវចាត់ទុកជាមោឃៈ ដោយសារសកម្មភាពនោះផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារឱ្យមាន ដោយក្រមនេះ ឬ ច្បាប់ផ្សេង ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន ។

**មាត្រា ៣៥៨.- សកម្មភាពដែលអាចលុបចោលបាន**

១-សកម្មភាពដែលអាចលុបចោលបាន មានសុពលភាព រហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ ។

២-ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង ។

៣-ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានផ្តល់សច្ចានុមតិលើសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវមានសុពលភាពជាស្ថាពរ ។

**មាត្រា ៣៥៩.- អ្នកដែលមានសិទ្ធិលុបចោល**

១-ចំពោះសកម្មភាពដែលអាចលុបចោលបាន ដោយមូលហេតុថា មានវិការៈក្នុងការបង្ហាញឆន្ទៈដែលបានកំណត់ ចាប់ពីមាត្រា ៣៤៦ (ការភាន់ច្រឡំ) ដល់មាត្រា ៣៥១ (អំពើកេងយកចំណេញហួសហេតុ) នៃក្រមនេះ អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះ អាចលុបចោលនូវសកម្មភាពនោះបាន ។ សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈ ឬ អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ។

២-ចំពោះការលុបចោល ដោយមូលហេតុគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ អនីតិភាព ឬ ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពផ្សេងទៀត សាមីខ្លួន អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈនៃជននោះ អាចលុបចោលនូវសកម្មភាពបាន ។ សន្តតិជន ឬ អច្ច័យលាភីសកលរបស់សាមីខ្លួន ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ។

ឬ ឱ្យរំលាយកិច្ចសន្យាទេ ។ ក្នុងករណីដែលម្ចាស់បំណុលរំលាយកិច្ចសន្យា ហើយទាមទារសំណងនៃការខូចខាតដែលជាការជំនួសកម្មវត្ថុនៃកិច្ចសន្យា ចំនួនទឹកប្រាក់នៃសំណងដែលភាគីទាំងសងខាងបានព្រមព្រៀងគ្នាដោយគិតជាមុន អំពីការខូចខាតដែលកើតឡើងដោយការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចនោះ មិនត្រូវចងភ្ជាប់ភាគីទេ ។

៥-ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ត្រូវសន្មតថាជាការកំណត់ជាមុននូវចំនួននៃសំណង ។

**មាត្រា ៤០៤.-** គោលការណ៍នៃការសងការខូចខាតជាប្រាក់

ចំពោះសំណងនៃការខូចខាតដែលកើតឡើងដោយការមិនអនុវត្តកាតព្វកិច្ច កូនបំណុលត្រូវសងជាប្រាក់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីទាំងសងខាងបានកំណត់ផ្សេងពីនេះដោយការសន្យាពិសេស ។

**មាត្រា ៤០៥.-** ឧបាទេសកម្មនៃអ្នកសង

ប្រសិនបើម្ចាស់បំណុលបានទទួលនូវសំណងនៃការខូចខាតដោយការសងតម្លៃនៃវត្ថុ ឬ សិទ្ធិដែលជាអត្ថន័យនៃសិទ្ធិលើបំណុល កូនបំណុលត្រូវទទួលឋានៈដែលម្ចាស់បំណុលធ្លាប់មានចំពោះវត្ថុ ឬ សិទ្ធិនោះ ដោយស្វ័យប្រវត្តិ ។

**មាត្រា ៤០៦.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណង

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យសងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ក្រោយពីពេលដែលការខូចខាតនោះកើតឡើង ។

## ផ្នែកទី ៤
## ការរំលាយកិច្ចសន្យា

**មាត្រា ៤០៧.-** ការរំលាយដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច

ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីដែលភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ។

**មាត្រា ៤០៨.-** ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ

១-ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ សំដៅទៅលើករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀត ។ ត្រូវចាត់ទុកថាមានការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ក្នុងករណីដូចខាងក្រោមនេះ :

ក- ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ច តាមពេលកំណត់ ដោយកំណត់អំឡុងពេលសមរម្យដើម្បីឱ្យអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ ។

ខ-ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់នោះ ។

គ-ភាគីមិនអាចអនុវត្តករណីយកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួនបានទេ ។

ឃ-ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន ។

២-ភាគីដែលបំពានកិច្ចសន្យា មិនអាចរារាំងការរំលាយកិច្ចសន្យាដោយផ្អែកលើបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ដោយយកមូលហេតុថាខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន បានឡើយ ។

**មាត្រា ៤០៩.-** វិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា

១-ភាគីម្ខាងដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យា ដោយបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតបាន ។ ការបង្ហាញឆន្ទៈរំលាយនេះអាចធ្វើឡើងក្រៅតុលាការបាន ។

២-ការបង្ហាញឆន្ទៈរំលាយនេះ មិនអាចដកវិញបានទេ ។

៣-ការបង្ហាញឆន្ទៈរំលាយនេះ អាចដាក់ល័ក្ខខ័ណ្ឌបង្អង់បាន ។

**មាត្រា ៤១០.-** ការរំលាយកិច្ចសន្យាដែលភាគីម្ខាងមានច្រើននាក់

១-ក្នុងករណីដែលភាគីម្ខាងមានច្រើននាក់ការរំលាយកិច្ចសន្យាត្រូវធ្វើឡើងដោយ

## ជំពូកទី ៧
## ការរលត់កាតព្វកិច្ច

**មាត្រា ៤៣៣.-** មូលហេតុនៃការរលត់កាតព្វកិច្ច

កាតព្វកិច្ចត្រូវរលត់ដោយហេតុដូចខាងក្រោមនេះ :

ក-ការសង ការទូទាត់ ការលើកលែង នវកម្ម ឬ ល្បាកុលភាព ដូចបានកំណត់ពីផ្នែកទី ១ (ការសង) ដល់ផ្នែកទី ៥ (ល្បាកុលភាព) នៃជំពូកទី ៧ នេះ ។

ខ-អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចដោយគ្មានកំហុសរបស់កូនបំណុល ដូចបានកំណត់ក្នុងជំពូកទី ៥ (ការទទួលបន្ទុកហានិភ័យ) នៃគន្ថីនេះ ។

គ-ការបំពេញល័ក្ខខ័ណ្ឌនៃការរំលាយដូចបានកំណត់ក្នុងផ្នែកទី ៣ (ល័ក្ខខ័ណ្ឌ កំណត់ពេល និង អំឡុងពេល) នៃជំពូកទី ១ ឬ ការរំលាយកិច្ចសន្យាដូចបានកំណត់ក្នុងផ្នែកទី ៤ (ការរំលាយកិច្ចសន្យា) នៃជំពូកទី ៤ នៃគន្ថីនេះ ។

ឃ-ការផុតអាជ្ញាយុកាលនៃការរលត់ដូចបានកំណត់ក្នុងជំពូកទី ៨ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល) នៃគន្ថីនេះ ។

ង-ការអនុវត្តសិទ្ធិលុបចោលតាមបញ្ញត្តិនៃផ្នែកទី ៣ (មោឃភាព និង ការលុបចោល) ជំពូកទី ២ នៃគន្ថីនេះ។

## ផ្នែកទី ១
## ការសង

### កថាភាគទី ១
### គោលការណ៍ទូទៅស្តីពីការសង

**មាត្រា ៤៣៤.-** អ្នកសង

១-ការសងអាចធ្វើឡើងដោយកូនបំណុលក៏បាន ដោយតតិយជនក៏បាន ។

២-ក្នុងករណីដែលគោលបំណងនៃកាតព្វកិច្ចមិនអាចសម្រេចដោយការសងរបស់តតិយជនបានទេ តតិយជននោះមិនអាចសងបានឡើយ លើកលែងតែមានការយល់ព្រម

ពេលកំណត់សងនៃសិទ្ធិលើបំណុលរបស់ភាគីម្ខាងទៀតនោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលគូភាគីធ្វើការសន្យាពិសេសថា អាចទូទាត់គ្នានូវកាតព្វកិច្ចរៀងៗខ្លួនបានដោយមិនគិតអំពីពេលកំណត់មុន ឬ ក្រោយ ។

**មាត្រា ៤៧២.-** ការកាត់បំណុលដោយការទូទាត់

ក្នុងករណីដែលភាគីម្ខាង ឬ ទាំងសងខាងមានកាតព្វកិច្ចច្រើនដែលអាចទូទាត់បាន អ្នកសុំទូទាត់អាចជ្រើសរើសកាតព្វកិច្ចណាមួយរបស់ខ្លួន និង កាតព្វកិច្ចណាមួយរបស់ភាគីម្ខាងទៀតដើម្បីរំលត់ដោយការទូទាត់នោះបាន ។ បញ្ញត្តិស្តីពីការកាត់បំណុលដោយការសង ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការទូទាត់ដែលគ្មានការជ្រើសរើស ដូចកំណត់ក្នុងវាក្យខណ្ឌទី ១ នៃមាត្រានេះ ។

## ផ្នែកទី ៣
## ការលើកលែង

**មាត្រា ៤៧៣.-** ការលើកលែងកាតព្វកិច្ច

ក្នុងករណីដែលម្ចាស់បំណុលបង្ហាញឆន្ទៈលើកលែងកាតព្វកិច្ចចំពោះកូនបំណុល កាតព្វកិច្ចនោះត្រូវរលត់ ។

**មាត្រា ៤៧៤.-** ការលើកលែងតែមួយផ្នែក

ម្ចាស់បំណុលអាចលើកលែងកាតព្វកិច្ចតែមួយផ្នែកបាន ។

**មាត្រា ៤៧៥.-** ករណីដែលកម្រិតការលើកលែង

ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានរឹបអូសដោយតតិយជន ឬ សិទ្ធិចាត់ចែងរបស់ម្ចាស់បំណុលត្រូវបានកម្រិត ដោយមូលហេតុផ្សេង ម្ចាស់បំណុលមិនអាចលើកលែងកាតព្វកិច្ចបានឡើយ ។

## ផ្នែកទី ៤
## នវកម្ម

**មាត្រា ៤៧៦.—** និយមន័យនៃនវកម្ម

១-នវកម្មសំដៅទៅលើកិច្ចសន្យារវាងម្ចាស់បំណុល និង កូនបំណុលដែលរំលត់កាតព្វកិច្ចដើម និង បង្កើតកាតព្វកិច្ចថ្មី ជំនួសកាតព្វកិច្ចដើមនោះ ។

២-នៅពេលកិច្ចសន្យានវកម្មដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បង្កើតអានុភាព នោះកាតព្វកិច្ចដើមត្រូវរលត់ ។

**មាត្រា ៤៧៧.—** ការមិនរលត់កាតព្វកិច្ចដើម

ប្រសិនបើកាតព្វកិច្ចថ្មីដែលត្រូវបានបង្កើតឡើងដោយនវកម្ម មិនបានបង្កើតអានុភាព ដោយសារមូលហេតុដែលកូនបំណុលនៃកាតព្វកិច្ចចាស់មិនអាចញ្ញាករបាន ឬ ប្រសិនបើ កាតព្វកិច្ចថ្មីនោះជាអលទ្ធភាពក្នុងការអនុវត្តតាំងពីដើម នោះកាតព្វកិច្ចដើមមិនត្រូវរលត់ឡើយ ។

**មាត្រា ៤៧៨.—** ការផ្ទេរប្រាតិភោគ

១-សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក ឬ ប្រាតិភោគផ្សេងទៀតដែលបានបង្កើតឡើង ដើម្បីធានាកាតព្វកិច្ចដើម អាចផ្ទេរដើម្បីធានាកាតព្វកិច្ចថ្មី ក្នុងទំហំនៃកាតព្វកិច្ចដើម ដោយការព្រមព្រៀងគ្នារបស់គូភាគីនៃកិច្ចសន្យានវកម្មបាន ។ ប៉ុន្តែ ប្រាតិភោគដែលត្រូវ បានដាក់ដោយតតិយជន មិនត្រូវផ្ទេរឡើយ លើកលែងតែមានការយល់ព្រមពីតតិយជន នោះ ។

២-ក្នុងឧបសន្យាថ្មីបរិភោគវត្ថុ ត្រូវសន្មតថា មានការព្រមព្រៀងដែលបានកំណត់ នៅវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ។

## ផ្នែកទី ៥
## ល្បាកុលភាព

**មាត្រា ៤៧៩.—** ល្បាកុលភាពរវាងសិទ្ធិលើបំណុល និង កាតព្វកិច្ច

១-ក្នុងករណីដែលសិទ្ធិលើបំណុល និង កាតព្វកិច្ចធ្លាក់ទៅលើបុគ្គលតែម្នាក់ សិទ្ធិលើបំណុល និង កាតព្វកិច្ចនោះត្រូវរលត់ដោយល្បាកុលភាព ។

២-សិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន សិទ្ធិនោះមិនត្រូវរលត់ដោយល្បាកុលភាពឡើយ ។

## ជំពូកទី ៨
## អាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល

**មាត្រា ៤៨០.—** និយមន័យនៃអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល សំដៅទៅលើការរលត់សិទ្ធិលើបំណុលដោយផ្អែកលើការណ៍ដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិ ក្នុងអំឡុងពេលដែលត្រូវបានកំណត់ ។

**មាត្រា ៤៨១.—** ពេលចាប់ផ្តើមគិតអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល ត្រូវគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលនោះបាន ។

**មាត្រា ៤៨២.—** អំឡុងពេលនៃអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលទូទៅ

អាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬ ច្បាប់ឬបទដ្ឋានគតិយុត្តផ្សេង ។

**មាត្រា ៤៨៣.—** អាជ្ញាយុកាលនៃការរលត់សិទ្ធិដែលមានអំឡុងពេលខ្លី

ចំពោះសិទ្ធិលើបំណុលអំពីថ្លៃទំនិញដែលផលិតករ ឬ ពាណិជ្ជករលក់ទៅឱ្យអ្នក

# ឧបសម្ព័ន្ធទី២

# មេរៀនស្តីពី
# ក្រមរដ្ឋប្បវេណី
# និង
# ក្រមនីតិវិធីរដ្ឋប្បវេណី

## ភាគ ១


រៀបរៀងដោយ

គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ

ក្រសួងយុត្តិធម៌

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច



បោះពុម្ពលើកទី ១

នៅ **ភ្នំពេញ** ខែ ធ្នូ ឆ្នាំ ២០១៥

# គន្ថីទី ៤ កាតព្វកិច្ច
## ជំពូកទី ១ បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១ ប្រភពនៃកាតព្វកិច្ច និង និយមន័យនៃទស្សនៈផ្សេងៗ

### ១.កាតព្វកិច្ច

#### ១.១. និយមន័យ

កាតព្វកិច្ច គឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីរនាក់ ដោយឲ្យបុគ្គលម្នាក់ដែលបានកំណត់មានករណីយកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត (មាត្រា ៣០៨ នៃក្រមរដ្ឋប្បវេណី)។

**+ កាតព្វកិច្ច និង ករណីយកិច្ច**

កាតព្វកិច្ច គឺជាប្រភេទមួយនៃករណីយកិច្ច ប៉ុន្តែករណីយកិច្ចទាំងអស់ មិនមែនសុទ្ធតែជាកាតព្វកិច្ចទេ។ ពាក្យកាតព្វកិច្ច ត្រូវបានប្រើក្នុងករណីដែលឆ្លើយតបទៅនឹងសិទ្ធិលើបំណុល ដូចជា អ្នកទិញ មានកាតព្វកិច្ចបង់ប្រាក់ គឺ ឆ្លើយតបនឹងសិទ្ធិទាមទារឲ្យបង់ប្រាក់របស់អ្នកលក់។

ពាក្យករណីយកិច្ច ជួនកាលត្រូវបានប្រើក្នុងករណីមិនឆ្លើយតបចំពោះសិទ្ធិលើបំណុល (សិទ្ធិទាមទារ) ទេ។

ឧទាហរណ៍ អ្នកបើកបរឡាន ម៉ូតូ មានករណីយកិច្ចប្រុងប្រយ័ត្ន នៅពេលបើកបរតាមផ្លូវ មិនឲ្យមានគ្រោះថ្នាក់ដល់បុគ្គលផ្សេងទៀត។

បើយើងចងក្រងជាសំណុំ យើងនឹងឃើញថា សំណុំរបស់កាតព្វកិច្ច គឺនៅក្នុងសំណុំរបស់ករណីយកិច្ច។




**+ កាតព្វកិច្ច និង សិទ្ធិលើបំណុល**

ពុំមានមាត្រាណាចែងអំពីនិយមន័យនៃសិទ្ធិលើបំណុលទេ តែមានមាត្រាចែងអំពីនិយមន័យនៃកាតព្វកិច្ច តែតាមពិតទៅការឲ្យនិយមន័យកាតព្វកិច្ច ក៏ដូចជាការកំណត់ពីសិទ្ធិលើបំណុលដែរ ព្រោះកាតព្វកិច្ច និងសិទ្ធិលើបំណុល គឺមានទំនាក់ទំនងមុខពីរ (កាតព្វកិច្ចរបស់ភាគីម្ខាង ត្រូវគ្នានឹងសិទ្ធិរបស់ភាគីម្ខាងទៀត)។ បុគ្គលម្ខាងដែលទទួលផលប្រយោជន៍ ហៅថា ម្ចាស់បំណុល ឯបុគ្គលម្ខាងទៀត ដែលទទួលបន្ទុក ហៅថា កូនបំណុល (មាត្រា ៣០៨ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។ ម្ចាស់បំណុលមានសិទ្ធិទាមទារឲ្យកូនបំណុលធ្វើ ឬ មិនធ្វើសកម្មភាពអ្វីមួយមកឲ្យខ្លួន។ យើងលើកឧទាហរណ៍ពីកិច្ចសន្យាលក់ទិញដែលជាកិច្ចសន្យាអញ្ញមញ្ញមួយមកសិក្សា។

អ្នកលក់ A ________________ B អ្នកទិញ

បើយើងជាភាគី A ឃើញថា យើងមានសិទ្ធិលើបំណុល ដោយឲ្យភាគី B បង់ប្រាក់ថ្លៃលក់ទិញមកឲ្យខ្លួន។ សិទ្ធិទាមទារនេះ ត្រូវគ្នានឹងករណីយកិច្ចបង់ប្រាក់របស់ភាគី B។ ក្នុងករណីនេះ A ជាម្ចាស់បំណុល រីឯ B វិញ គឺជាកូនបំណុល។

បើយើងជាភាគី B វិញ ឃើញថា យើងមានសិទ្ធិលើបំណុល ដោយឲ្យភាគី A ផ្ទេរកម្មសិទ្ធិ និង ផ្ទេរការកាន់កាប់វត្ថុមកឲ្យខ្លួន។ សិទ្ធិទាមទារនេះ ត្រូវគ្នានឹងករណីយកិច្ចផ្ទេរកម្មសិទ្ធិ និងផ្ទេរការកាន់កាប់របស់ភាគី A។ ក្នុងករណីនេះ B ជាម្ចាស់បំណុល រីឯ A វិញជាកូនបំណុល។

នៅក្នុងកិច្ចសន្យាលក់ទិញ អ្នកលក់ជាម្ចាស់បំណុលផង ជាកូនបំណុលផង ហើយអ្នកទិញក៏ជាម្ចាស់បំណុលផង និង ជាកូនបំណុលផងដែរ។

## **១.២. ភាពខុសគ្នារវាងសិទ្ធិលើបំណុល និង សិទ្ធិប្រត្យក្ស**

ក្រមរដ្ឋប្បវេណី កំណត់ពីសិទ្ធិដែលយើងមានទៅលើវត្ថុ (សិទ្ធិប្រត្យក្ស) និងទៅលើបុគ្គល (សិទ្ធិលើបំណុល)។

| **សិទ្ធិលើបំណុល** | **សិទ្ធិប្រត្យក្ស** |
| --- | --- |
| • សិទ្ធិលើបំណុល ជាសិទ្ធិលើបុគ្គល ជាសិទ្ធិដែលអាចទាមទារឲ្យបុគ្គលណាមួយធ្វើសកម្មភាពអ្វីមួយ ឬ មិនធ្វើសកម្មភាពអ្វីមួយ។ អ្នកដែលមានសិទ្ធិលើបំណុល ហៅថាម្ចាស់បំណុល។<br>• សិទ្ធិលើបំណុលពុំមានភាពដាច់ខាត មិនផ្តាច់មុខ។<br>• ភាពមិនដាច់ខាតរបស់សិទ្ធិលើបំណុល៖ ម្ចាស់បំណុលអះអាងសិទ្ធិទាមទាររបស់ខ្លួនបានតែចំពោះបុគ្គលជាក់លាក់ (កូនបំណុល) តែប៉ុណ្ណោះ មិនអាចអះអាងដល់ជនដទៃឡើយ។ ចំណងចងភ្ជាប់តែរវាងម្ចាស់បំណុល និង កូនបំណុលតែប៉ុណ្ណោះ។ ឧទាហរណ៍ A ឲ្យ B ខ្ចីប្រាក់ (ខ្ចីបរិភោគ) A ពុំអាចទាមទារឲ្យបងប្អូន B សងជំនួសឡើយ។ មានការវិវឌ្ឍន៍ ដោយក្រមរដ្ឋប្បវេណីថ្មីដែលអនុញ្ញាតឲ្យមានការធ្វើអនុប្បទានសិទ្ធិលើបំណុល (មាត្រា ៥០១ នៃក្រមរដ្ឋប្បវេណី) និង ការទទួលកាតព្វកិច្ច (មាត្រា ៥០៧ នៃក្រមរដ្ឋប្បវេណី)។<br>• ភាពមិនផ្តាច់មុខនៃសិទ្ធិលើបំណុល៖ បុគ្គលតែមួយ អាចមានកាតព្វកិច្ចដូចគ្នាច្រើន។ A មានដីមួយកន្លែង តែ A បានលក់ដីនោះឲ្យទៅ B ផង ហើយលក់ទៅឲ្យ C ផង ដោយ B ពុំបានចុះបញ្ជី C បានចុះបញ្ជី។ កម្មសិទ្ធិត្រូវបានផ្ទេរឲ្យ C ប៉ុន្តែ A មានកាតព្វកិច្ចប្រគល់ដីឲ្យ B ផង និងប្រគល់ដីដដែលនោះឲ្យទៅ C | • សិទ្ធិប្រត្យក្ស គឺសំដៅទៅលើសិទ្ធិគ្រប់គ្រងវត្ថុដោយចំពោះ។ កម្មសិទ្ធិករលើវត្ថុណាមួយ អាចគ្រប់គ្រងដោយសេរីលើវត្ថុដែលជារបស់ខ្លួន ដោយមិនមានការជ្រៀតជ្រែកពីអ្នកដទៃ។ កម្មសិទ្ធិករ អាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនដោយសេរីក្នុងទំហំដែលច្បាប់បានកម្រិត (មាត្រា ១៣៨ នៃក្រមរដ្ឋប្បវេណី)។<br>• សិទ្ធិប្រត្យក្ស មានភាពដាច់ខាត ផ្តាច់មុខ។<br>• ភាពដាច់ខាតរបស់សិទ្ធិប្រត្យក្ស៖ កម្មសិទ្ធិករលើវត្ថុអ្វីមួយ អាចអះអាងពីសិទ្ធិរបស់ខ្លួនចំពោះបុគ្គលគ្រប់រូប ដូចជាអាចទាមទារឲ្យប្រគល់វិញ តាមមាត្រា ១៥៥ សិទ្ធិទាមទារឲ្យបញ្ឈប់ និង បង្ការការរារាំងសិទ្ធិលើកម្មសិទ្ធិ តាមមាត្រា ១៥៩ នៃក្រមរដ្ឋប្បវេណី។<br>• ភាពផ្តាច់មុខរបស់សិទ្ធិប្រត្យក្ស៖ វត្ថុមួយមានសិទ្ធិតែមួយ ច្បាប់មិនអនុញ្ញាតឲ្យបង្កើតសិទ្ធិមួយទៀត ដែលមានខ្លឹមសារដូចគ្នាលើវត្ថុតែមួយបានទេ។ បើដីមួយកន្លែងជារបស់ A ដីដដែលនោះ មិនអាចជារបស់ B បានទេ។<br>• គោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់ មាត្រា ១៣១ សិទ្ធិប្រត្យក្សអាចបង្កើតបានតាមក្រមរដ្ឋប្បវេណី និង ច្បាប់ពិសេស។ |

| | |
|---|---|
| ផង។ A អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចចំពោះ B ត្រូវទទួលខុសត្រូវសងការខូចខាត (មាត្រា ៣៩៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។<br><br>ចុះបញ្ជី<br>• សិទ្ធិលើបំណុលអាចបង្កើតឡើងដោយសេរីឲ្យតែមិនផ្ទុយទៅនឹងវិធាននៃច្បាប់ តាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន (មាត្រា ៣ នៃក្រមរដ្ឋប្បវេណី)។ | |

**២. ប្រភពនៃកាតព្វកិច្ច**

កាតព្វកិច្ចកើតឡើងដោយកិច្ចសន្យា (មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណី) ដោយសកម្មភាពឯកតោភាគី (មាត្រា ៣១២ នៃក្រមរដ្ឋប្បវេណី) ដោយការគ្រប់គ្រងដោយឈឺឆ្អាល (មាត្រា ៧២៩ នៃក្រមរដ្ឋប្បវេណី) ដោយសេចក្ដីចម្រើនដោយឥតហេតុ (មាត្រា ៧៣៦ នៃក្រមរដ្ឋប្បវេណី) ដោយអំពើអនីត្យានុកូល (មាត្រា ៧៤២ នៃក្រមរដ្ឋប្បវេណី) និងដោយបញ្ញត្តិច្បាប់។

- កាតព្វកិច្ចកើតឡើងពីកិច្ចសន្យា និង សកម្មភាពឯកតោភាគី គឺ កាតព្វកិច្ចកើតឡើងដោយឆន្ទៈរបស់ភាគី (មាត្រា ៣០៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។
- កាតព្វកិច្ចដែលកើតឡើងដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្ដីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និង ដោយបញ្ញត្តិច្បាប់ គឺជាកាតព្វកិច្ចដែលកំណត់ដោយច្បាប់ ដែលកើតឡើងដោយគ្មានការបង្ហាញឆន្ទៈរបស់ភាគី (មាត្រា ៣០៩ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី)។

**៣. និយមន័យនៃការបង្ហាញឆន្ទៈ កិច្ចសន្យា សកម្មភាពឯកតោភាគី**

**+ ការបង្ហាញឆន្ទៈ** ៖ ការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើតអានុភាពគតិយុត្ត ហៅថា ការបង្ហាញឆន្ទៈ (មាត្រា ៣១០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ សំណើ និង ស្ទីការដើម្បីបង្កើតកិច្ចសន្យា ឬ ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា គឺជាការបង្ហាញឆន្ទៈ។ ផ្ទុយមកវិញ ការពោលពាក្យពេចន៍ស្នេហាប្រាប់គូសង្សារ មិនមែនជាការបង្ហាញឆន្ទៈទេ ព្រោះវាមិនមានបំណងចង់បង្កើតឲ្យមានចំណងគតិយុត្តទេ។

ការបង្ហាញឆន្ទៈ ត្រូវមានអានុភាពចាប់ពីពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈនោះបានទៅដល់ភាគីម្ខាងទៀត (មាត្រា ៣១០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែ មានការបង្ហាញឆន្ទៈខ្លះមិនអាចធ្វើឡើងចំពោះភាគីម្ខាងទៀតទេ ដូចជា អច្ច័យទាន។

- បើគូភាគីអង្គុយនិយាយតទល់មុខគ្នា ការបង្ហាញឆន្ទៈនេះមានអានុភាពភ្លាម ហើយការផ្ញើសារអេឡិចត្រូនិកទៅភាគីម្ខាងទៀត ក៏មានអានុភាពភ្លាមដែរ ព្រោះសារនៃការបង្ហាញឆន្ទៈ បានទៅដល់ភាគីនោះភ្លាមៗ។
- បើការបង្ហាញឆន្ទៈតាមរយៈសំបុត្រប្រៃសណីយ៍ អានុភាពនៃការបង្ហាញឆន្ទៈនោះកើតឡើងពេលសំបុត្របានដាក់ក្នុងប្រអប់សំបុត្ររបស់ភាគីម្ខាងទៀត ឬ នៅពេលដែលសមាជិកគ្រួសារដែលរស់នៅ ជាមួយភាគីម្ខាងទៀតនោះបានទទួលសំបុត្រ ទោះបីជាភាគីម្ខាងទៀតនោះដឹង ឬ មិនដឹងអំពីការទៅដល់នៃសំបុត្រក៏ដោយ។
- ការបង្ហាញឆន្ទៈតាមរយៈទូរស័ព្ទ ក៏មានអានុភាពភ្លាមដែរ។
- ការបង្ហាញឆន្ទៈចំពោះអនីតិជន ឬ ជនស្ថិតនៅក្រោមរបបអ្នកអាណាព្យាបាល ត្រូវធ្វើឡើងចំពោះអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាល។

  ** ក៏ប៉ុន្តែ បើមានវិវាទរហូតប្តឹងទៅតុលាការ ភាគីម្ខាងអះអាងថា ខ្លួនបានទទួលសំបុត្រមែន ឬ បានទទួលទូរស័ព្ទមែន តែពុំបាននិយាយពីការរំលាយកិច្ចសន្យាទេ នោះមាត្រា ៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីដែលចែងអំពីការជូនដំណឹងអំពីការបង្ហាញឆន្ទៈទៅអ្នកឆ្ងាយបានកំណត់អំពីវិធីបញ្ជាក់អំពីការបង្ហាញឆន្ទៈទៅអ្នកឆ្ងាយ។

**+ កិច្ចសន្យា**៖ កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់ មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច (មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណី)។

បើព្រមព្រៀង ៖ កិច្ចសន្យា




មិនត្រូវគ្នា ៖ គ្មានកិច្ចសន្យា

- បង្កើតកាតព្វកិច្ចតាមកិច្ចសន្យា ៖ A មានដី B ចង់ជួល ហើយ A និង B ព្រមព្រៀងបង្កើតកិច្ចសន្យាជួលដោយ A មានកាតព្វកិច្ចប្រគល់ដី ហើយ B មានកាតព្វកិច្ចបង់ប្រាក់ដែលជាថ្លៃឈ្នួល។
- កែប្រែកាតព្វកិច្ចតាមកិច្ចសន្យា ៖ កែប្រែ សំដៅទៅលើការផ្លាស់ប្តូរ ដូចជាផ្លាស់ប្តូរអំឡុងពេលជួល ថ្លៃឈ្នួល ពេលវេលាបង់ថ្លៃឈ្នួល ជាដើម។
- រំលត់កាតព្វកិច្ចតាមកិច្ចសន្យា ៖ ពេលបង្កើត បានកំណត់អំឡុងពេលជួលរយៈពេល ១០ឆ្នាំ តែក្រោយមកភាគី A និង B បានព្រមព្រៀងរំលាយកិច្ចសន្យាមុនអាណត្តិ។

**+ សកម្មភាពឯកតោភាគី** ៖ សកម្មភាពឯកតោភាគី គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬ ដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬ តាមបញ្ញត្តិនៃច្បាប់ (មាត្រា ៣១២ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។

- កិច្ចសន្យា តម្រូវឲ្យមានការព្រមព្រៀងរវាងគូភាគី តែសកម្មភាពឯកតោភាគី មិនតម្រូវឲ្យមានការព្រមព្រៀងពីភាគីម្ខាងទៀតទេ។

- បង្កើតកាតព្វកិច្ចតាមសកម្មភាពឯកតោភាគី ៖ អច្ច័យទាន ជាសកម្មភាពឯកតោភាគីក្នុងការបង្កើតកាតព្វកិច្ច ប៉ុន្តែ កាតព្វកិច្ចត្រូវធ្លាក់ទៅលើសន្តតិជន។ ការទទួលស្គាល់កូន ក៏ជាសកម្មភាពឯកតោភាគីដែរ ពីព្រោះឪពុកមានកាតព្វកិច្ចចិញ្ចឹម និងថែរក្សាកូនដែលជាអនីតិជន ជាដើម។
- ការកែប្រែកាតព្វកិច្ចតាមសកម្មភាពឯកតោភាគី ៖ ការកែប្រែ សំដៅទៅលើការផ្លាស់ប្តូរ។ ឧទាហរណ៍ នៅក្នុងកិច្ចសន្យាលក់ទិញរថយន្ត អ្នកលក់បានសន្យាថានឹងយករថយន្តទៅឲ្យអ្នកទិញដល់ផ្ទះ។ នៅក្នុងកិច្ចសន្យា បានផ្តល់សិទ្ធិឲ្យអ្នកទិញអាចផ្លាស់ប្តូរទីកន្លែងនៃការប្រគល់ក្រៅពីក្រុងភ្នំពេញបាន ប្រសិនបើអ្នកទិញទាក់ទងមកអ្នកលក់នៅមុន ៣ថ្ងៃ។ ប្រសិនបើអ្នកទិញទាក់ទងទៅអ្នកលក់ ដោយសុំឲ្យផ្លាស់ប្តូរទីកន្លែងនៃការដឹកជញ្ជូនមកកន្លែងធ្វើការវិញនោះ នេះគឺជាការកែប្រែកាតព្វកិច្ចតាមសកម្មភាពឯកតោភាគី។
- រំលត់កាតព្វកិច្ចតាមសកម្មភាពឯកតោភាគី ៖ ការលុបចោលកិច្ចសន្យា(មាត្រា ៣៥៨ នៃក្រមរដ្ឋប្បវេណី) ការរំលាយកិច្ចសន្យា(មាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី) គឺជាសកម្មភាពឯកតោភាគី។ ការលើកលែង (មាត្រា ៤៧៣ នៃក្រមរដ្ឋប្បវេណី) ក៏ជាសកម្មភាពឯកតោភាគី។

## ផ្នែកទី២ ប្រភេទ និងបែបយ៉ាងនៃកាតព្វកិច្ច

### ១. ប្រភេទនៃកាតព្វកិច្ច

កាតព្វកិច្ច មានន័យថាជាទំនាក់ទំនងគតិយុត្ត ដែលបុគ្គលជាក់លាក់ម្នាក់ (កូនបំណុល) មានករណីយកិច្ចចំពោះបុគ្គលជាក់លាក់ម្នាក់ទៀត (ម្ចាស់បំណុល) ។ ខ្លឹមសារនៃករណីយកិច្ចអាចមានផ្សេងៗគ្នាដូចជា ការប្រគល់វត្ថុ ឬប្រាក់ ការបំពេញសកម្មភាពមួយចំនួន ឬការមិនបំពេញសកម្មភាពមួយចំនួន ។

ឧ.អ្នកទិញ នៅក្នុងកិច្ចសន្យាលក់ទំនិញ មានករណីយកិច្ចបង់ប្រាក់ឲ្យអ្នកលក់។ ចំណែកឯ អ្នកលក់ មានករណីយកិច្ចផ្ទេរកម្មសិទ្ធិនៃវត្ថុដែលជាកម្មវត្ថុនៃការលក់ទៅឲ្យអ្នកទិញ ។

មូលហេតុនៃកាតព្វកិច្ចជាច្រើនផ្សេងទៀតកើតមាន ដូចមានចែងនៅក្នុងមាត្រា ៣០៩ នៃក្រមរដ្ឋប្បវេណី។

### ១.១. កាតព្វកិច្ចមានគោលបំណងឲ្យធ្វើសកម្មភាព និង កាតព្វកិច្ចមានគោលបំណងមិនឲ្យធ្វើសកម្មភាព (មាត្រា ៣១៣)

#### ក. កាតព្វកិច្ចមានគោលបំណងឲ្យធ្វើសកម្មភាព

កាតព្វកិច្ចមានគោលបំណងឲ្យធ្វើសកម្មភាព គឺអាចធ្វើឡើងតាមរយៈកិច្ចសន្យាអាណត្តិ កិច្ចសន្យាការងារជាដើម ។

ឧ. ការសម្អាតផ្លូវថ្នល់ ការកាប់ដើមឈើ ការសាងសង់ ឬការបំផ្លាញអាគារ ការដឹកជញ្ជូនទំនិញ ។ ល។

#### ខ. កាតព្វកិច្ចមានគោលបំណងមិនឲ្យធ្វើសកម្មភាព

មិនមានឧទាហរណ៍ជាគម្រូណាមួយនៃកាតព្វកិច្ចមានគោលបំណងមិនឲ្យធ្វើសកម្មភាពអ្វីមួយ តាមរយៈកិច្ចសន្យាក្នុងទម្រង់ណាមួយទេ ហើយគេមិនអាច និយាយជាក់លាក់ថា តើកាតព្វកិច្ចដែលមានបំណងលុបចោលសកម្មភាពត្រូវបានទទួលស្គាល់ ឬអត់ទេ ។ ជាលទ្ធផលមាត្រា ៣១៣ នៃក្រមរដ្ឋប្បវេណី ចែងយ៉ាងច្បាស់ថា អាចមានកាតព្វកិច្ចមិនឲ្យធ្វើសកម្មភាពណាមួយ ។

ឧ. មិនឲ្យបើកអាជីវកម្មដូចគ្នា (ផ្លាកសញ្ញា, ម៉ាក), កិច្ចសន្យាធ្វើឡើងរវាងក្រុមហ៊ុន និងតួសម្តែងដែលចែងសកម្មភាពមិនឲ្យតួកុនទៅសម្តែងនៅក្រុមហ៊ុនផ្សេងទៀត។

ឧ. បទបញ្ជាហាមប្រាមរបស់អាជ្ញាធរមូលដ្ឋាន, កិច្ចសន្យាហាមមិនឲ្យលេងព្យាណូនៅពេលយប់ ។

### ១.២. កាតព្វកិច្ចប្រគល់ និង កាតព្វកិច្ចធ្វើសកម្មភាព

#### ក. កាតព្វកិច្ចប្រគល់

កាតព្វកិច្ចប្រគល់ គឺអ្នកលក់មានកាតព្វកិច្ចត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញទៅឲ្យអ្នកទិញ តាមកាលបរិច្ឆេទ និងតាមទីកន្លែងដែលបានកំណត់នៅក្នុងកិច្ចសន្យា ។

ឧ. ករណី កិច្ចសន្យាទិញលក់ឡាន កាតព្វកិច្ចប្រគល់ គឺអ្នកលក់ត្រូវប្រគល់ឡានទៅឲ្យអ្នកទិញ រីឯអ្នកទិញមានកាតព្វកិច្ចត្រូវប្រគល់លុយទៅឲ្យអ្នកលក់ ។

#### ខ. កាតព្វកិច្ចធ្វើសកម្មភាព

កាតព្វកិច្ចធ្វើសកម្មភាព គឺជាប្រភេទនៃកាតព្វកិច្ចដែលមានគោលបំណងឲ្យធ្វើសកម្មភាពក្រៅពីកាតព្វកិច្ចប្រគល់។

ឧ. កិច្ចសន្យាដឹកជញ្ជូនទំនិញដែលអ្នកដឹកជញ្ជូនត្រូវដឹកជញ្ជូនទំនិញឲ្យអតិថិជន, កិច្ចសន្យាអាណត្តិដូចជា មេធាវីត្រូវធ្វើសកម្មភាពការពារក្តីឲ្យកូនក្តី (គូភាគីមានឋានៈស្មើគ្នា) , កិច្ចសន្យាម៉ៅការដូចជាអ្នកម៉ៅការត្រូវសាងសង់អាគារ (គូភាគីមានឋានៈស្មើគ្នា)។

## ១.៣. កាតព្វកិច្ចប្រគល់វត្ថុ ដែលបានកំណត់ជាក់លាក់ និង កាតព្វកិច្ចដែលបានកំណត់ប្រភេទ នៃវត្ថុ

### ក. កាតព្វកិច្ចប្រគល់វត្ថុ ដែលបានកំណត់ជាក់លាក់ (មាត្រា ៣១៤ នៃក្រមរដ្ឋប្បវេណី)

វត្ថុដែលបានកំណត់ជាក់លាក់ គឺជាករណីដែលភាគីពាក់ព័ន្ធនៃកិច្ចសន្យាផ្តោតលើលក្ខណៈសម្គាល់ពិសេសនៃវត្ថុមួយ ហើយបើទោះបីជាមានការប្រគល់វត្ថុជំនួសក៏ដោយ ក៏មិនអាចចាត់ទុកថាជាការអនុវត្តកាតព្វកិច្ចដែរ។ ចំពោះកាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់អ្វីមួយ កូនបំណុលមានករណីយកិច្ចថែរក្សាវត្ថុនោះដោយប្រុងប្រយ័ត្នរហូតដល់ពេលប្រគល់នោះ ។

ឧ. សេះប្រណាំងឈ្មោះ ក, ផ្ទាំងគំនូរទូលក្អមទឹកដោយវិចិត្រករញ៉ើក នឹម, ដី ឬអាគារដែលមានអត្តសញ្ញាណច្បាស់លាស់។ល។

**ខ. កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ (មាត្រា ៣១៥ នៃក្រមរដ្ឋប្បវេណី)** (វិធីសាស្ត្រដើម្បីកំណត់ប្រភេទនៃវត្ថុគឺ ទី១. ត្រូវកំណត់ប្រភេទនៃវត្ថុដែលត្រូវប្រគល់ឲ្យបានច្បាស់លាស់, ទី២. ត្រូវបំពេញសកម្មភាពចាំបាច់ដើម្បីផ្តល់នូវកម្មវត្ថុ ដែលបានកំណត់ហើយនោះ។ ជំហានទាំងពីរនេះ ចាំបាច់ត្រូវតែមាន។)

កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ គឺជាកាតព្វកិច្ចដែលកម្មវត្ថុនោះត្រូវកំណត់ដោយផ្អែកលើប្រភេទ។

ឧ. អង្ករ១០គីឡូក្រាមមកពីខេត្តបាត់ដំបង / គោដោយគ្មានបញ្ជាក់ថាគោណាមួយ / ទូរទស្សន៍ ២០គ្រឿង / ស្រាបៀអង្គរ ១០កំប៉ុង។

- ប្រសិនបើកម្មវត្ថុត្រូវផ្តល់មានគុណភាពច្រើនយ៉ាង កូនបំណុលមានករណីយកិច្ចផ្តល់នូវវត្ថុដែលមានគុណភាពដូចដែលគូភាគីបានកំណត់។ ក្នុងករណីដែលគូភាគីមិនកំណត់គុណភាពទេ កូនបំណុលមានករណីកិច្ចផ្តល់នូវវត្ថុដែលមានគុណភាពមធ្យម (មាត្រា ៣១៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។

- ចំពោះកាតព្វកិច្ច ដែលបានកំណត់ប្រភេទ ក្រោយពេលដែលកូនបំណុលបានកំណត់កម្មវត្ថុ ដែលត្រូវផ្តល់ច្បាស់លាស់ និង ដែលបានបញ្ចប់សកម្មភាពចាំបាច់ដើម្បីផ្តល់នូវកម្មវត្ថុដែលបានកំណត់ហើយនោះ កូនបំណុលមានករណីយកិច្ចផ្តល់នូវវត្ថុនោះតែប៉ុណ្ណោះ (មាត្រា ៣១៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

ឧ. កិច្ចសន្យាទិញទូរទស្សន៍ចំនួន ២០ គ្រឿង ប្រសិនបើអ្នកលក់មានទូរទស្សន៍ចំនួន១០០ គ្រឿង ក្នុងឃ្លាំង អ្នកលក់ត្រូវជ្រើសរើសយកចំនួន២០ គ្រឿង ។ ក្រោយពេលដែលកូនបំណុលបានជ្រើសរើសទូរទស្សន៍ចំនួន ២០ គ្រឿង និងបញ្ចប់ការរៀបចំប្រគល់វត្ថុដល់អ្នកទិញរួចហើយ ករណីយកិច្ចរបស់អ្នកលក់ ត្រូវកំណត់នៅត្រឹមករណីយកិច្ចផ្តល់តាវលិកនូវទូរទស្សន៍ទាំង ២០ គ្រឿងនោះ ។ ជាលទ្ធផល នៃការកំណត់នេះ អ្នកលក់មានករណីយកិច្ចថែរក្សាទូរទស្សន៍ទាំង ២០គ្រឿងនោះ ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ (មាត្រា ៣១៤ នៃក្រមរដ្ឋប្បវេណី) ។

- "សកម្មភាពដែលចាំបាច់ត្រូវបំពេញក្នុងការប្រគល់" ៖ ពេលកំណត់ជាក់លាក់ គឺខុសគ្នាទៅតាមករណីសិក្សានីមួយៗ ហើយជាទូទៅយើងអាចធ្វើការពិចារណាបានដូចខាងក្រោម៖

· កាតព្វកិច្ចដែលកូនបំណុលត្រូវយកទៅប្រគល់ឲ្យ

វត្ថុត្រូវកំណត់ជាក់លាក់នៅពេលដែលយកទៅដល់ និងបានប្រគល់ឲ្យជាក់ស្តែងនៅកំណត់ពេលអនុវត្ត ។

· កាតព្វកិច្ចដែលម្ចាស់បំណុលត្រូវមកយក

វត្ថុត្រូវបានកំណត់ជាក់លាក់ នៅពេលដែលបានបែងចែក រៀបចំសម្រាប់ការប្រគល់ និងបានជូនដំណឹងទៅម្ចាស់បំណុល។ ទោះបីជាមិនបានជូនដំណឹងក៏ដោយ ប្រសិនបើបានបែងចែក និងរៀបចំសម្រាប់ការប្រគល់រួចហើយពេលកំណត់អនុវត្តបានមកដល់ វត្ថុនោះក៏ត្រូវបានកំណត់ជាក់លាក់ដែរ។

### ១.៤. កាតព្វកិច្ចជាប្រាក់ និង កាតព្វកិច្ចមិនមែនជាប្រាក់

#### ក. កាតព្វកិច្ចជាប្រាក់

១. ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ចជាប្រាក់ នោះកូនបំណុលអាចសងជារូបិយវត្ថុផ្សេងៗ តាមការជ្រើសរើសរបស់ខ្លួនបាន ។ ប៉ុន្តែ ម្ចាស់បំណុល និងកូនបំណុលអាចកំណត់ការសងជារូបិយវត្ថុពិសេសក៏បានដែរ (មាត្រា ៣១៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី) ។

ឧ. A បានខ្ចីប្រាក់ ១ លានរៀល ពី B ដែលមានក្រដាស ៥ ម៉ឺនរៀល ចំនួន ២០ សន្លឹក។ នៅពេលសង A អាចសងជាក្រដាស ៥ ម៉ឺនរៀល ចំនួន ២០ សន្លឹក វិញក៏បាន ឬត្រូវសងជាក្រដាស ១០ ម៉ឺនរៀល ចំនួន ១០ សន្លឹក ក៏បាន ឬក្រដាសប្រាក់ផ្សេងពីអ្វីដែលខ្លួនបានទទួលក៏បាន សំខាន់ឲ្យតែតម្លៃលុយដែលត្រូវសងគឺគ្រប់ចំនួនដែលខ្លួនបានខ្ចី ។

២. ក្នុងករណីដែលរូបិយវត្ថុពិសេសដែលកំណត់ជាកម្មវត្ថុនៃកាតព្វកិច្ច លែងជារូបិយវត្ថុស្របច្បាប់នៅពេលអនុវត្តកាតព្វកិច្ច កូនបំណុលអាចសងជារូបិយវត្ថុណាមួយផ្សេងទៀតបាន (មាត្រា ៣១៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។

ឧ. ពេលខ្ចីលុយក្រដាស ៥ ដុល្លារ សេរីចាស់ តែយូរទៅដោយគេលែងប្រើ គេក៏ដូរលុយសេរីថ្មី នោះពេលសង ត្រូវសងលុយសេរីថ្មី មិនមែនលុយសេរីចាស់ទេ ។

៣. បញ្ញត្តិនៃកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការផ្តល់នូវរូបិយវត្ថុបរទេស ត្រូវបានកំណត់ជាកម្មវត្ថុនៃកាតព្វកិច្ច (មាត្រា ៣១៦ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី) ។

ឧ. បើ A មានកាតព្វកិច្ចត្រូវសងប្រាក់ចំនួន ១០០ ដុល្លារ នោះកូនបំណុលអាចសងជារូបិយវត្ថុបរទេសផ្សេងបានដូចជា ក្រដាសប្រាក់ ១ដុល្លារ , ១០ដុល្លារ, ២០ដុល្លារ, ៥០ដុល្លារ ឬ ១០០ដុល្លារ ជាដើម ។

៤. ក្នុងករណីដែលបានកំណត់ចំនួននៃកាតព្វកិច្ចជារូបិយវត្ថុបរទេស កូនបំណុលអាចសងជារូបិយវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ដោយគិតទៅតាមអត្រាប្តូររូបិយប័ណ្ណបរទេស នៅកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ចនោះនៅពេលកំណត់អនុវត្ត (មាត្រា ៣១៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។

ឧ. A ខ្ចីលុយ B ចំនួន ១០០ ដុល្លារ។ លុះដល់ថ្ងៃសង A យកលុយរៀលចំនួន ៤០ ម៉ឺនរៀលឲ្យទៅ B ប៉ុន្តែ B មិនព្រមទទួល ដោយអះអាងថាអត្រាប្តូរប្រាក់នៅភ្នំពេញគឺ ៤១០០ រៀលក្នុងមួយដុល្លារ ដូច្នេះ A ត្រូវសង ៤១ ម៉ឺនរៀល។

៥. បញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់ (មាត្រា ៣៩៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)

នៅពេលដែលកម្មវត្ថុនៃកាតព្វកិច្ច គឺជាការបង់ប្រាក់ នោះកូនបំណុលមិនអាចរួចផុតពីកាតព្វកិច្ចបង់ការប្រាក់ចំពោះការយឺតយ៉ាវឡើយ ទោះបីជាកូនបំណុលអាចបញ្ជាក់ថា ការយឺតយ៉ាវក្នុងការបង់នោះកើតឡើងដោយសារប្រធានសក្តិក៏ដោយ។

ក្នុងករណីដែលកូនបំណុលបានបញ្ជាក់ថាមិនមានកំហុស ចំពោះការមិនអនុវត្តកាតព្វកិច្ច នោះកូនបំណុលអាចរួចផុតពីករណីយកិច្ចបង់ថ្លៃការខូចខាតដែលលើសពីការប្រាក់ដែលយឺតយ៉ាវ ប៉ុន្តែមិនអាចរួចផុតពីករណីយកិច្ចបង់ការប្រាក់ដែលយឺតយ៉ាវនោះទេ ។

ឧ. A បានខ្ចីប្រាក់ពី B ចំនួន ១០០០ ដុល្លារ ប៉ុន្តែនៅថ្ងៃសងប្រាក់ ដោយសារទឹកជំនន់ ធ្វើឲ្យ A មិនអាចសងប្រាក់ទាន់ពេលកំណត់ លុះមួយខែក្រោយមកទើប A អាចសងប្រាក់បាន។ ដូច្នេះ A ត្រូវសងប្រាក់ដើម និងការប្រាក់យឺតយ៉ាវផងដែរ ។

### ខ. កាតព្វកិច្ចដែលមិនអាចជ្រើសរើសបាន

កាតព្វកិច្ចដែលមិនអាចជ្រើសរើសបាន គឺសំដៅលើករណីដែលកម្មវត្ថុនៃកាតព្វកិច្ច ដែលបានចុះកិច្ចសន្យា មិនបានកំណត់អំពីជម្រើសច្រើនប្រភេទដែលអាចអនុវត្តបាន ។

ឧ. ភាគី A មានកាតព្វកិច្ចត្រូវផ្ដល់តាវកាលិកជាឡានម៉ាក Camry ឆ្លាម ផលិតនៅឆ្នាំ១៩៩៧ មួយគ្រឿង ឲ្យភាគី B ។

### ១.៦. អត្រាការប្រាក់ដែលច្បាប់បានកំណត់ និង ការប្រាក់សមាស

### ក. អត្រាការប្រាក់ដែលច្បាប់បានកំណត់

ប្រសិនបើគូភាគីនៃកិច្ចសន្យា បានយល់ព្រមលើអត្រាការប្រាក់នៅក្នុងកិច្ចសន្យាក្នុងទំហំនៃអត្រាការប្រាក់ដែលត្រូវបានកម្រិត (១៨%) (មាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី និងមាត្រា ១៧ កថាខណ្ឌទី ១ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី និងប្រការ ១ នៃប្រកាសស្ដីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតរបស់ក្រសួងយុត្តិធម៌) អត្រាការប្រាក់ដែលត្រូវអនុវត្ត គឺជាអត្រាការប្រាក់នៅក្នុងកិច្ចសន្យា។ ចំពោះការខ្ចីបរិភោគធម្មតា អត្រាការប្រាក់គឺត្រូវបានព្រមព្រៀងដោយគូភាគី ។ ក្នុងករណីដែលភាគីនៃកិច្ចសន្យាបានព្រមព្រៀងថា អត្រាការប្រាក់នឹងត្រូវបង្កើតឡើង ប៉ុន្តែមិនបានសម្រេចអំពីអត្រាការប្រាក់ទេនោះ អត្រាការប្រាក់ត្រូវគិតចំនួន ៥ ភាគរយ ក្នុងមួយឆ្នាំ (មាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណី)។

### ខ. ការប្រាក់សមាស

ការប្រាក់សមាស សំដៅលើការបន្ថែមការប្រាក់លើការប្រាក់ដែលបានបង្កើតរួចហើយ ក្នុងករណីកូនបំណុលមិនព្រមសងការប្រាក់នោះ (មាត្រា ៣១៩ នៃក្រមរដ្ឋប្បវេណី) ។ ដោយសារតែការប្រាក់សមាសបានបន្ថែមបន្ទុកចំពោះកូនបំណុល ការប្រាក់សមាសនេះអាចធ្វើបានលុះត្រាតែបំពេញលក្ខខណ្ឌកំណត់ ។ ការប្រាក់សមាសនេះអាចធ្វើទៅបានតែក្នុងករណីដែលលក្ខខណ្ឌទាំង ២ ខាងក្រោមត្រូវបានបំពេញ។

- ទី ១ មានការយឺតយ៉ាវ មិនបានបង់ការប្រាក់សម្រាប់រយៈពេលចាប់ ពី ១ ឆ្នាំឡើងទៅ។
- ទី២ ម្ចាស់បំណុលបានដាស់តឿនឲ្យសង តែកូនបំណុលមិនព្រមសង (មាត្រា ៣១៩ នៃក្រមរដ្ឋប្បវេណី)។

ប្រសិនបើលក្ខខណ្ឌទាំង២ខាងលើនេះត្រូវបានបំពេញ ម្ចាស់បំណុលអាចបញ្ចូលការប្រាក់ទៅក្នុងប្រាក់ដើម ដោយធ្វើការបង្ហាញឆន្ទៈទៅកូនបំណុល។ ការព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុលក្នុងការបញ្ចូលការប្រាក់ទៅក្នុងប្រាក់ដើមលើសពីបញ្ញត្តិក្នុងមាត្រានេះ (ដូចជា ការព្រមព្រៀងក្នុងការបញ្ចូលការប្រាក់ទៅក្នុងប្រាក់ដើមជារៀងរាល់ខែជាដើម) ត្រូវទុកជាមោឃៈ។

ឧ. A បានខ្ចីប្រាក់ពី B ចំនួន ១០០០ ដុល្លារ ដោយយកការប្រាក់ ៨% ក្នុងមួយឆ្នាំ ប៉ុន្តែ A មិនបាន បង់ការប្រាក់អស់រយៈពេល ១ឆ្នាំ។ ប្រសិនបើ A ខកខានមិនបានបង់ការប្រាក់បន្ទាប់ពីបានទទួលការដាស់តឿនពី B នោះ B អាចបូកការប្រាក់បញ្ចូលទៅក្នុងប្រាក់ដើមបាន។

### ខ. កាតព្វកិច្ចដែលមិនអាចជ្រើសរើសបាន

កាតព្វកិច្ចដែលមិនអាចជ្រើសរើសបាន គឺសំដៅលើករណីដែលកម្មវត្ថុនៃកាតព្វកិច្ច ដែលបានចុះកិច្ចសន្យាមិនបានកំណត់អំពីជម្រើសច្រើនប្រភេទដែលអាចអនុវត្តបាន ។

ឱ. ភាគី A មានកាតព្វកិច្ចត្រូវផ្តល់តាវកាលិកជាឡានម៉ាក Camry ឆ្លាម ផលិតនៅឆ្នាំ១៩៩៧ មួយគ្រឿងឲ្យភាគី B ។

## ១.៦. អត្រាការប្រាក់ដែលច្បាប់បានកំណត់ និង ការប្រាក់សមាស

### ក. អត្រាការប្រាក់ដែលច្បាប់បានកំណត់

ប្រសិនបើគូភាគីនៃកិច្ចសន្យា បានយល់ព្រមលើអត្រាការប្រាក់នៅក្នុងកិច្ចសន្យាក្នុងទំហំនៃអត្រាការប្រាក់ដែលត្រូវបានកម្រិត (១៨%) (មាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី និងមាត្រា ១៧ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងប្រការ ១ នៃប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតរបស់ក្រសួងយុត្តិធម៌) អត្រាការប្រាក់ដែលត្រូវអនុវត្ត គឺជាអត្រាការប្រាក់នៅក្នុងកិច្ចសន្យា។ ចំពោះការខ្ចីបរិភោគធម្មតា អត្រាការប្រាក់គឺត្រូវបានព្រមព្រៀងដោយគូភាគី ។ ក្នុងករណីដែលភាគីនៃកិច្ចសន្យាបានព្រមព្រៀងថា អត្រាការប្រាក់នឹងត្រូវបង្កើតឡើង ប៉ុន្តែមិនបានសម្រេចអំពីអត្រាការប្រាក់ទេនោះ អត្រាការប្រាក់ត្រូវគិតចំនួន ៥ ភាគរយ ក្នុងមួយឆ្នាំ (មាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណី)។

### ខ. ការប្រាក់សមាស

ការប្រាក់សមាស សំដៅលើការបន្ថែមការប្រាក់លើការប្រាក់ដែលបានបង្កើតរួចហើយ ក្នុងករណីកូនបំណុលមិនព្រមសងការប្រាក់នោះ (មាត្រា ៣១៩ នៃក្រមរដ្ឋប្បវេណី) ។ ដោយសារតែការប្រាក់សមាសបានបន្ថែមបន្ទុកចំពោះកូនបំណុល ការប្រាក់សមាសនេះអាចធ្វើបានលុះត្រាតែបំពេញលក្ខខណ្ឌកំណត់ ។ ការប្រាក់សមាសនេះអាចធ្វើទៅបានតែក្នុងករណីដែលលក្ខខណ្ឌទាំង ២ ខាងក្រោមត្រូវបានបំពេញ។

- ទី ១ មានការយឺតយ៉ាវ មិនបានបង់ការប្រាក់សម្រាប់រយៈពេលចាប់ ពី ១ ឆ្នាំឡើងទៅ។
- ទី២ ម្ចាស់បំណុលបានដាស់តឿនឲ្យសង តែកូនបំណុលមិនព្រមសង (មាត្រា ៣១៩ នៃក្រមរដ្ឋប្បវេណី)។

ប្រសិនបើលក្ខខណ្ឌទាំង២ខាងលើនេះត្រូវបានបំពេញ ម្ចាស់បំណុលអាចបញ្ចូលការប្រាក់ទៅក្នុងប្រាក់ដើម ដោយធ្វើការបង្ហាញឆន្ទៈទៅកូនបំណុល។ ការព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុលក្នុងការបញ្ចូលការប្រាក់ទៅក្នុងប្រាក់ដើមលើសពីបញ្ញត្តិក្នុងមាត្រានេះ (ដូចជា ការព្រមព្រៀងក្នុងការបញ្ចូលការប្រាក់ទៅក្នុងប្រាក់ដើមជារៀងរាល់ខែជាដើម) ត្រូវទុកជាមោឃៈ។

ឱ. A បានខ្ចីប្រាក់ពី B ចំនួន ១០០០ ដុល្លារ ដោយយកការប្រាក់ ៨% ក្នុងមួយឆ្នាំ ប៉ុន្តែ A មិនបាន បង់ការប្រាក់អស់រយៈពេល ១ឆ្នាំ។ ប្រសិនបើ A ខកខានមិនបានបង់ការប្រាក់បន្ទាប់ពីបានទទួលការដាស់តឿនពី B នោះ B អាចបូកការប្រាក់បញ្ចូលទៅក្នុងប្រាក់ដើមបាន។